ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ ២០១៣

## របាយការណ៍ជាតិ ស្តីពីលទ្ធផលចុងក្រោយ

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Food and Agriculture Organization of the United Nations
Sweden Sverige
Australian Aid
USAID FROM THE AMERICAN PEOPLE

ខែធ្នូ ឆ្នាំ២០១៥

**មាតិកា** **ទំព័រ**


**បុព្វកថា** ................................................................................................ vi

សមាសភាពនៃគណៈកម្មាធិការជាតិជំរឿនកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣ ..................... vii

សមាសភាពនៃគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម នៅព្រះរាជាណាកប្រកម្ពុជា ឆ្នាំ២០១៣ .............. ix

សមាសភាពនៃគណៈកម្មការឃោសនាជំរឿនកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣ ................. xi

សូចនាករសង្ខេប ................................................................................................ xii

ពាក្យសរសេរកាត់................................................................................................ xvii

**ជំពូកទី១ ទំហំ វិសាលភាព និងការជ្រើសរើសសំណាកគំរូ** .................................................... 1

គោលបំណង ................................................................................................ 1

វិធីសាស្ត្រ ................................................................................................ 2

វិសាលភាពជំរឿន ................................................................................................ 3

ទីតាំងភូមិសាស្ត្រគ្របដណ្តប់ ................................................................................................ 4

អង្កេត និងកាលបរិច្ឆេទយោង ................................................................................................ 5

ការជ្រើសរើសសំណាកគំរូ ................................................................................................ 5

និតិវិធីអង្កេត ................................................................................................ 5

ផែនការឃោសនាផ្សព្វផ្សាយ ................................................................................................ 6

ការរៀបចំជ្រើសរើសគំរូនិងការចុះប្រមូលទិន្នន័យ ................................................................ 6

ការកែច្នៃទិន្នន័យ ................................................................................................ 8

**ជំពូកទី ២ ភូមិសាស្ត្រនិងហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា** ................................................ 9

សណ្ឋានដី ................................................................................................ 9

ប្រភេទដី ................................................................................................ 10

តំបន់ដែលងាយរងសម្ពាធទាប ................................................................................................ 10

សកម្មភាពសេដ្ឋកិច្ច ................................................................................................ 10

ប្រព័ន្ធដំណាំ ................................................................................................ 11

ក្សេត្រសាស្ត្រកែច្នៃនិងហេដ្ឋារចនាសម្ព័ន្ធជនបទ ................................................................ 11

ការទំនាក់ទំនង ................................................................................................ 12

សុខភាពនិងអប់រំបរិក្ខារ ................................................................................................ 12

ប្រភពទឹក ................................................................................................ 13

ការចូលទៅកាន់ផ្លូវជាតិ ................................................................................................ 14

អង្គការសហគមន៍ ................................................................................................ 14

**ជំពូកទី៣  ការកាន់កាប់កសិកម្ម និងការកាន់កាប់ដី ............................................................. 15**
ការកាន់កាប់គ្រួសារកសិកម្ម ........................................................................................... 15
ទំហំនៃ ការកាន់កាប់កសិកម្ម ......................................................................................... 16
ការបែងចែកដីនៃការកាន់កាប់គ្រួសារកសិកម្មទៅជាក្បាលដី ................................................ 18
ការប្រើប្រាស់ក្បាលដីជាចម្បង ................................................................................ 19
កម្មសិទ្ធិដីនៃក្បាលដី ............................................................................................ 20
ការប្រើប្រាស់បរិវេណនៅជុំវិញលំនៅដ្ឋានធ្វើសកម្មភាពកសិកម្មនៅក្នុងការកាន់កាប់កសិកម្ម ................ 21
ការធ្វើកសិកម្មនៅតែជុំវិញបរិវេណលំនៅដ្ឋានប៉ុណ្ណោះនៃការកាន់កាប់គ្រួសារកសិកម្ម ...................... 22
កាកាន់កាប់កសិកម្មគតិយុត្ត (ដីសម្បទានសេដ្ឋកិច្ច) ................................................................ 23
**ជំពូកទី៤ ការដាំដុះដំណាំ ........................................................................................ 26**
ដំណាំធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់ ...................................................................... 26
ការប្រមូលផល ......................................................................................................... 28
ការស្រោចស្រព ........................................................................................................ 31
ដំណាំយកមើម ......................................................................................................... 31
រុក្ខជាតិពពួកសណ្តែក (គ្រាប់ធញ្ញជាតិ) ......................................................................... 33
ដំណាំធញ្ញជាតិប្រេង .................................................................................................. 34
គ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ ..................................................................... 35
ដំណាំឧស្សាហកម្ម ..................................................................................................... 36
ដំណាំបន្លែ .............................................................................................................. 36
ចំការដាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ ....................................................................... 37
ពពួកផ្លែឈើ ....................................................................................................... 37
ដំណាំស្វាយចន្ទី .................................................................................................... 40
ដំណាំយកប្រេង .................................................................................................... 41
ដំណាំគ្រឿងទេសនិងដំណាំក្រអូប ........................................................................... 42
ដំណាំកៅស៊ូ ........................................................................................................ 42
ដំណាំមិនមែនជាអាហារ ........................................................................................ 43
ដំណាំរាយប៉ាយ ដំណាំអចិន្ត្រៃយ៍ .................................................................................. 43
សម្ភារៈកសិកម្មនិងសេវាកម្ម ..................................................................................... 45
ឧបករណ៍និងគ្រឿងម៉ាស៊ីន ..................................................................................... 45
ការប្រើប្រាស់ជីនិងសារធាតុគីមី ............................................................................. 47
គ្រាប់ពូជស្រូវ ........................................................................................................ 49

សេវាផ្សព្វផ្សាយកសិកម្ម ........ 51
ការប្រើប្រាស់ឥណទាន ........ 52
ព័ត៌មានកសិកម្ម ........ 53
ដំណើរការទីផ្សារ ........ 54
ការងារសហគមន៍ ........ 55
**ជំពូកទី ៥ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ........ 56**
ការចិញ្ចឹមបសុសត្វ និងបសុបក្សី ........ 56
ការចិញ្ចឹមគោ ក្របី និងជ្រូក ........ 58
មាន់និងទា ........ 61
បសុសត្វនិងបសុបក្សីដែលបានបញ្ចេញ ........ 63
សត្វបក្សីមានជំងឺ ........ 67
ឧបករណ៍និងសម្ភារៈបរិក្ខា ........ 68
**ជំពូកទី ៦ ការនេសាទនិងវារីវប្បកម្ម ........ 69**
ការនេសាទត្រី ........ 69
វារីវប្បកម្ម ........ 72
**ជំពូកទី ៧ សកម្មភាពសេដ្ឋកិច្ចបន្ថែមនៅក្នុងការកាន់កាប់គ្រួសារកសិកម្ម** ........ 75
អាជីវកម្មខ្នាតតូច ........ 77
សកម្មភាពសេដ្ឋកិច្ចផ្សេងទៀត នៃសមាជិកគ្រួសារកសិកម្ម ........ 77
**ជំពូកទី ៨ គ្រួសារកសិកម្ម និងប្រជាជន ........ 78**
គ្រួសារ ........ 78
ប្រជាជនតាមក្រុមអាយុ ........ 79
អត្រាអ្នកដែលនៅក្នុងបន្ទុកគ្រួសារ ........ 80
ទំនាក់ទំនងជាមួយនឹងមេគ្រួសារ ........ 80
ការអប់រំ ........ 81
ស្ថានភាពគ្រួសារ ........ 81
**ជំពូកទី ៩ សន្តិសុខស្បៀងនៃគ្រួសារកសិកម្ម ........ 82**
សន្តិសុខស្បៀង ........ 85
ហេតុផលមួយចំនួននៃអសន្តិសុខស្បៀង ........ 86
**ឧបសម្ព័ន្ធ ១: វិសាលភាព វិធីសាស្ត្រ និងគុណភាពនៃទិន្នន័យ ........ 87**
សេចក្តីផ្តើម ........ 87
គោលបំណង ........ 88

វិសាលភាពធ្វើជំរឿន ........................................................................................ 88
គ្របដណ្តប់ទីតាំងភូមិសាស្ត្រ ........................................................................................ 90
ពេលវេលាអង្កេត និងរយៈពេលយោង ........................................................................................ 90
ការជ្រើសរើសសំណាកគំរូ ........................................................................................ 91
និតិវិធីក្នុងការធ្វើអង្កេត ........................................................................................ 91
ការគាំទ្រផែនការឃោសនាផ្សព្វផ្សាយ ........................................................................................ 92
ការរៀបចំជ្រើសរើសសំណាកគំរូ និងប្រតិបត្តិការតាមមូលដ្ឋាន ........................................................................................ 92
ការរៀបចំជ្រើសរើសសំណាកគំរូ និងវិធីសាស្ត្រប៉ានស្មាន ........................................................................................ 92
អង្គភាពស្ថិតិ ........................................................................................ 92
វិធីសាស្ត្រការកាន់កាប់កសិកម្មខ្នាតតូច ........................................................................................ 93
ការចាត់ចំណាត់ថ្នាក់ ........................................................................................ 95
ការអនុម័តយុទ្ធសាស្ត្រជ្រើសរើសសំណាកគំរូ ........................................................................................ 95
វិធីសាស្ត្រប៉ាន់ស្មាន ........................................................................................ 96
គណនាមេគុណ ........................................................................................ 97
ទិដ្ឋភាពប្រតិបត្តការ ........................................................................................ 99
ការកែច្នៃទិន្នន័យ ........................................................................................ 101
ភាពត្រឹមត្រូវ និងជឿជាក់លើទិន្នន័យជំរឿនកសិកម្មជាតិនៅកម្ពុជា ........................................................................................ 102
ភាពត្រឹមត្រូវទិន្នន័យពីខាងក្រៅ ........................................................................................ 102
ទស្សនទាន និងនិយមន័យ ........................................................................................ 104
ការប្រៀបធៀបនៃការប៉ានស្មាន ........................................................................................ 104
ប្រភពនៃកំហុស ........................................................................................ 108
កំហុសក្នុងការជ្រើសរើសសំណាកគំរូ ........................................................................................ 108
កំហុសមិនមែនជ្រើសរើសសំណាកគំរូ ........................................................................................ 110
កំហុសតំបន់ដែលមិនបានគ្របដណ្តប់ ........................................................................................ 110
ការវាយតម្លៃជារួមរបស់ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣........................................ 111
**ឧបសម្ព័ន្ធ ២÷តារាងស្ថិតិសង្ខេប ........................................................................................ 128**
តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី២: ទីតាំងភូមិសាស្ត្រ និង ហេដ្ឋារចនាសម្ព័ន្ធ ........................................ 129
តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី៣: ការកាន់កាប់កសិកម្ម ........................................ 153
តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី៤: ផលិតកម្មដំណាំ ........................................ 194
តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី៥: ការចិញ្ចឹមសត្វ ........................................ 308
តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី៦: ការនេសាទ និងវារីវប្បកម្ម ........................................ 352

តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី៧: សេដ្ឋកិច្ចគ្រួសារ ........................................................ 382
តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី៨: ចំនួនគ្រួសារកសិកម្ម .................................................... 396
តារាងស្ថិតិសង្ខេបសម្រាប់ជំពូក ទី៩: សន្តិសុខស្បៀង ........................................................ 419
**ឧបសម្ព័ន្ធ ៣÷បញ្ជីសំណួរជំរឿន និងអង្កេតសំណួរ ............................................................ 466**

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយនឹងបង្ហាញជូនរបាយការណ៍ជាតិស្តីពី លទ្ធផលចុងក្រោយនៃជំរឿនកសិកម្ម នៅកម្ពុជា ឆ្នាំ២០១៣ ដែលរួមមានទិន្នន័យអំពីចំនួនគ្រួសារដែលបានចូលរួមក្នុងសកម្មភាពកសិកម្ម និងទិន្នន័យសំខាន់ៗ មួយចំនួនទៀត។ កាលពីខែសីហា ឆ្នាំ២០១៤ កន្លងទៅ លទ្ធផលបណ្តោះអាសន្ននៃចំនួនគ្រួសារបានចូលរួមក្នុងសកម្មភាពកសិកម្ម និងសូចនាករសំខាន់ៗមួយចំនួនត្រូវបានប្រកាសផ្សព្វផ្សាយ ដោយផ្អែកលើលទ្ធផលពីបញ្ជីសំណួរស្នូល នៃជំរឿនកសិកម្មនៅកម្ពុជា ដែលផ្តល់ដោយមន្ត្រីសម្ភាសន៍។ លទ្ធផលចុងក្រោយនេះ គឺផ្អែកលើការពិនិត្យដ៏ល្អិតល្អន់ នូវព័ត៌មាន និងទិន្នន័យ ពីបញ្ជីសំណួរបន្ថែមនៃជំរឿនកសិកម្ម ដែលប្រើសម្រាប់សម្ភាសន៍លម្អិតគ្រប់គ្រួសារសំណាកគំរូ ទាំងអស់ ដែលបានធ្វើកសិកម្មប្រមាណ ៩៨.០០០ គ្រួសារ នៅពេលធ្វើជំរឿន ។

លទ្ធផលសំខាន់ៗ នៃជំរឿនកសិកម្មនៅកម្ពុជា ដែលបង្ហាញជូនក្នុងរបាយការណ៍នេះ នឹងបម្រើដល់សេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ទិន្នន័យក្នុងផ្នែកស្ថិតិកសិកម្ម។ រីឯលទ្ធផលតាមប្រធានបទផ្សេងៗ នឹងត្រូវបោះពុម្ពផ្សាយនៅពេលខាងមុខ បន្ទាប់ពីធ្វើការវិភាគលម្អិត។ ការប្រកាសផ្សព្វផ្សាយលទ្ធផលចុងក្រោយរបស់ជំរឿនកសិកម្មលើកទី១ នៅកម្ពុជា ឆ្នាំ២០១៣ គឺជាជំហានដំបូងដ៏សំខាន់មួយនៃប្រវត្តិសាស្ត្រស្ថិតិរបស់កម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រធ្វើឲ្យកិច្ចដំណើរការជំរឿនទទួលបានជោគជ័យ។ ខ្ញុំមានការសប្បាយរីករាយ ហើយពេញចិត្តយ៉ាងខ្លាំងក្នុងការបំពេញតួនាទីជាប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្ម។

ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាលរាជធានី ខេត្ត ព្រមទាំងសមាជិកគណៈកម្មាធិការជាតិជំរឿនកសិកម្ម និងគណៈកម្មាធិការជំរឿនកសិកម្មរាជធានី ខេត្ត ដែលបានជួយសហការយ៉ាងខ្លាំងក្លា។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ អ្នកយកព័ត៌មាន វិទ្យុ ទូរទស្សន៍ ដែលបានបំពេញតួនាទីដ៏សំខាន់ក្នុងការផ្សព្វផ្សាយការធ្វើជំរឿននេះ។

តាងនាមឲ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (Australian Aid) និងទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) ចំពោះការជួយគាំទ្រ ទាំងថវិកា និងបច្ចេកទេសដល់ ជំរឿនកសិកម្មនៅកម្ពុជា ឆ្នាំ២០១៣។ ខ្ញុំសូមវាយតម្លៃខ្ពស់ដល់មន្ត្រីទាំងអស់នៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានចូលរួមក្នុងដំណាក់ការនានានៃជំរឿន ចំពោះការខិតខំប្រឹងប្រែង ជួយគាំទ្រ និងធ្វើការងារល្អសំដៅឲ្យដំណើរ ការជំរឿននេះសម្រេចបានដោយជោគជ័យ។

ជោគជ័យមួយភាគធំដែលទទួលបានក្នុងការធ្វើជំរឿនកសិកម្មនេះ គឺអាស្រ័យដោយកិច្ចសហការបានល្អពី ប្រជាជនកម្ពុជាដោយផ្ទាល់ និងមន្ត្រីដែលបានខិតខំធ្វើការងារយ៉ាងសកម្ម រួមមានមន្ត្រីសម្ភាសន៍ មន្ត្រីត្រួតពិនិត្យ ប្រធានភូមិ មន្ត្រីជំរឿនឃុំ សង្កាត់ មន្ត្រីជំរឿនក្រុង ស្រុក ខណ្ឌ ព្រមទាំងមន្ត្រីប្រចាំតំបន់ និងមន្ត្រីជំនួយការរបស់ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ខ្ញុំសូមកោតសរសើរដោយអស់ពីចិត្តដល់ឯកឧត្តម **សន ស៊ីថន** រដ្ឋលេខាធិការក្រសួងផែនការ អតីតអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងលោកជំទាវ **ហង់ លីណា** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងមន្ត្រីទាំងអស់ក្នុងក្រុម ការងារបច្ចេកទេសស្នូល ដែលបានខិតខំធ្វើឲ្យជំរឿននេះទទួលបានជោគជ័យ។

ខ្ញុំសង្ឃឹមថា ក្រសួង ស្ថាប័ន អង្គការ ភ្នាក់ងារអន្តរជាតិ អ្នកស្រាវជ្រាវ អ្នកធ្វើគោលនយោបាយ និង សាធារណៈជននានា នឹងប្រើប្រាស់របាយការណ៍ដ៏មានសារៈសំខាន់នេះ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

រាជធានីភ្នំពេញ
ខែ ធ្នូ ឆ្នាំ២០១៥

**ឆាយ ថន**

# សមាសភាពនៃគណៈកម្មាធិការជាតិជំរឿនកសិកម្ម
# នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣

| | | | |
|---|---|---|---|
| ឯកឧត្តម | **ឆាយ ថន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ | ប្រធាន |
| ឯកឧត្តម | **ច័ន្ទ តុងអ៊ីវ** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ឯកឧត្តម | **សក់ សេដ្ឋា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ឯកឧត្តម | **ហង់ ជួនណារ៉ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ឯកឧត្តម | **អ៊ុន សារឿន** | រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| ឯកឧត្តម | **សម សុគ្គា** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ឯកឧត្តម | **រ័ត្ន សារិន** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ឯកឧត្តម | **យិន គឹមស៊ាន** | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ឯកឧត្តម | **ពិត ចំណាន** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ឯកឧត្តម | **វេង សាខុន** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ឯកឧត្តម | **ថាច់ ផែន** | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ឯកឧត្តម | **សាន វិសាល** | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ឯកឧត្តម | **សន ស៊ីថន** | អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | |
| | | និងជាអនុរដ្ឋលេខាធិការ ក្រសួងផែនការ | លេខាធិការ |

# សមាសភាពនៃគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម
# នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣

| | | | |
|---|---|---|---|
| ឯកឧត្តម | **អ៊ិន សារឿន** | រដ្ឋលេខាធិការ ក្រសួងផែនការ | ប្រធាន (ហូតដល់ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៣) |
| ឯកឧត្តម | **រិន ធីរៈ** | រដ្ឋលេខាធិការ ក្រសួងផែនការ | ប្រធាន (ចាប់ពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣) |
| ឯកឧត្តម | **ទុយ ចំរើន** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ឯកឧត្តម | **ហោ ដារិទ្ធ** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ឯកឧត្តម | **សន ស៊ីថន** | អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ និងជាអនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ (ហូតដល់ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៣) |
| លោកជំទាវ | **ហង់ លីណា** | អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ | អនុប្រធានអចិន្ត្រៃយ៍ (ចាប់ពីថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៣) |
| លោក | **ហុង ណារិត** | ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ឯកឧត្តម | **សេង សឿន** | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ឯកឧត្តម | **ភឿក សារិន** | នាយកខុទ្ទកាល័យ ក្រសួងផែនការ | សមាជិក |
| លោក | **ឃិន សុវលក្ខណ៍** | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| លោក | **ឆាយ សត្យា** | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| លោក | **មិច ភន្នុល** | ប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| លោក | **គឹម ផល្លា** | ប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| លោក | **យ៉ា សាដេត** | ប្រធាននាយកដ្ឋានផែនការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| លោក | **ឡុង សុខា** | ប្រធាននាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| លោក | **ត្លូង សោភា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| លោក | **ចាន់ សុវណ្ណា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ | សមាជិក |
| លោក | **ស្រ៊ន់ ពិធូ** | អនុប្រធាននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| លោក | **ឈុប សុធារិទ្ធ** | អនុប្រធាននាយកដ្ឋានផែនការ និងកិច្ចការច្បាប់ ក្រសួងបរិស្ថាន | សមាជិក |
| លោក | **អ៊ុង បូរាត** | អនុប្រធាននាយកដ្ឋានផែនការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

# សមាសភាពនៃគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម
# នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣ (ត)

| | | | |
|---|---|---|---|
| លោក | **លី ឆាយ** | អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការ<br>អន្តរជាតិ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| លោកស្រី | **មាស សុទ្ធាវី** | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| លោក | **គង់ សៀកលី** | ប្រធានការិយាល័យ នៃក្រសួងបរិស្ថាន | សមាជិក |
| លោក | **ពេជ្រ ពោធិ៍** | អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ | លេខាធិការ |

## សមាសភាពនៃគណៈកម្មការឃោសនាជំរឿនកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣

| | | | |
|---|---|---|---|
| ឯកឧត្តម | **អ៊ិន សារឿន** | រដ្ឋលេខាធិការ ក្រសួងផែនការ | ប្រធាន |
| ឯកឧត្តម | **ថាច់ ផែន** | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | អនុប្រធាន |
| ឯកឧត្តម | **ភឹម គុណាវឌ្ឍន៍** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក ទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន | អនុប្រធាន |
| ឯកឧត្តម | **តន់ យ៉ាន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក វិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន | អនុប្រធាន |
| ឯកឧត្តម | **សន ស៊ីថន** | អគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ និងជាអនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| លោក | **ហុខ ណារិត** | ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| លោកជំទាវ | **ហាង លីណា** | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| លោក | **ត្នង សោភា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| លោក | **អ៊ិន សំបុល** | អនុប្រធាននាយកដ្ឋានផែនការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| លោក | **លី ឆាយ** | អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការ អន្តរជាតិ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ឯកឧត្តម | **សេង សឿន** | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ | លេខាធិការ |

# សូចនាករសង្ខេប

## គ្រួសារកាន់កាប់កសិកម្ម

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣ បានប្រើប្រាស់ទម្រង់តារាងសំណួរចំនួន ០៦ សម្រាប់ធ្វើជំរឿន និងធ្វើអង្កេតទៅលើគ្រួសារ។ ទម្រង់សំណួរចំនួន ២ (ទម្រង់ A និង B) ត្រូវបានប្រើប្រាស់ក្នុងដំណាក់កាលគោល និងជាមូលដ្ឋានគ្រឹះនៃជំរឿន។ ទម្រង់សំណួរ ៤ ផ្សេងទៀត (ទម្រង់ C D E និង F) គឺត្រូវបានប្រើប្រាស់នៅក្នុងដំណាក់កាលបំពេញបន្ថែមហើយទិន្នន័យលម្អិតត្រូវបានប្រមូលដោយផ្អែកលើគ្រួសារសំណាកគំរូ។ ទម្រង់សំណួរមួយទៀត (ទម្រង់ G) គឺត្រូវបានមេភូមិទទួលបំពេញដោយខ្លួនឯង ដើម្បីប្រមូលព័ត៌មានស្តីពី ស្ថានភាព ដីគ្រោះមហន្តរាយ/បញ្ហាផ្សេងៗ អាចកើតមាននៃសកម្មភាពសេដ្ឋកិច្ចជាដើម រួមជាមួយនឹងលទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធកម្រិតថ្នាក់ភូមិ។ គួរកត់សម្គាល់ថា មានចែកដាច់ដោយឡែកសម្រាប់ទម្រង់សំណួរដែលមិនមែនជាគ្រួសារប្រតិបត្តិការកសិដ្ឋានក្នុងវិស័យកសិកម្ម។

នៅក្នុងប្រទេសត្រូវបានចែកជាបីអង្គភាពរដ្ឋបាលដែលក្នុងនោះអង្គភាពរដ្ឋបាលដែលតូចជាងគេត្រូវបានកំណត់ឈ្មោះថា ភូមិ បន្ទាប់មក ឃុំ និងស្រុក។ ប្រទេសកម្ពុជាមានចំនួន ១៤.០៧៣ភូមិត្រូវបាន បែងចែកជា ១.៦២១ ឃុំ និងបានផ្តុំទៅជា ១៩៤ស្រុក/ខណ្ឌ។ គន្លឹះសំខាន់ៗ (ប៉ាន់ស្មាន) មួយចំនួនដែលបានមកពីជំរឿនកសិកម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣មានបង្ហាញដូចខាងក្រោមសម្រាប់ ទូទាំងប្រទេស។

## ដំណាក់កាលគោលៈ ហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា

(ប្រធានភូមិសរុបចំនួន ១២.៦០៤ នាក់ ត្រូវបានធ្វើការសម្ភាសន៍ ទូទាំង ២៥ រាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ទីប្រជុំជននៃរាជធានីភ្នំពេញមិនត្រូវបានធ្វើជំរឿន)

| | |
|---|---|
| ភាគរយនៃភូមិដែលបានដាំដំណាំតែមួយដងក្នុងមួយឆ្នាំ | ៥០% |
| ភាគរយនៃភូមិដែលបានរាយការណ៍ថា មានរោងម៉ាស៊ីនសម្រាប់កិនស្រូវ និងការកែច្នៃកសិឧស្សាហកម្ម | ៨០% |
| ភាគរយនៃភូមិដែលបានរាយការណ៍ថា បានប្រើប្រាស់ទូរស័ព្ទដៃ | ៧៧% |
| ភាគរយនៃភូមិដែលបានរាយការណ៍ថា មានមណ្ឌលសុខភាព ឬគ្លីនិកសុខភាព ឬមន្ទីរពេទ្យ | ២៤% |
| ភាគរយនៃភូមិដែលបានរាយការណ៍ថា ទទួលបានការប្រើប្រាស់ទឹកតាមរយៈទុយោទឹកស្អាត និងអណ្តូង | ៨០% |
| ភាគរយនៃភូមិដែលបានរាយការណ៍ថា មានការប្រើប្រាស់ផ្លូវជាតិដែលនៅជិតបំផុត | ៣៥% |
| ចំនួនភាគរយនៃភូមិ ដែលបានរងការប៉ះពាល់ដោយគ្រោះទឹកជំនន់ក្នុងរយៈពេលប្រាំឆ្នាំមុនពេលធ្វើជំរឿន | ៣៩% |
| ចំនួនភាគរយនៃភូមិ ដែលបានរងការប៉ះពាល់ដោយគ្រោះរាំងស្ងួតនិងអសន្តិសុខស្បៀងអាហារនៅក្នុងរយៈពេលប្រាំឆ្នាំមុនពេលធ្វើជំរឿន | ៣៨% |

| ដំណាក់កាលគោល៖ ការកាន់កាប់កសិកម្ម និងការកាន់កាប់ដី | |
|---|---|
| ចំនួនគ្រួសារដែលបានចុះបញ្ជី (២៥ រាជធានីខេត្ត និងខណ្ឌចំនួន ០៥ នៅរាជធានីភ្នំពេញ) | ២,៦លាន |
| ចំនួនគ្រួសារដែលមានការកាន់កាប់កសិកម្ម (ចូលរួមនៅក្នុងដាំដុះដំណាំទំហំផ្ទៃដីយ៉ាងតិច 0,0៣ ហិកតា និង/ ឬយ៉ាងតិចមាន បសុសត្វប្រភេទធំចំនួន ២ក្បាល និង / ឬ បសុសត្វប្រភេទតូចចំនួន ៣ក្បាល និង / ឬ មានបសុបក្សីចំនួន ២៥ក្បាល) ។ | ២,១លាន |
| ផ្ទៃដីសរុបនៃគ្រួសារកាន់កាប់កសិកម្មទាំងអស់ (រួមទាំងផ្ទៃដីបរិវេណជុំវិញផ្ទះ) | ៣,៣លាន ហ.ត |
| ផ្ទៃដីសរុបនៃការកាន់កាប់កសិកម្មគតិយុត្តទាំង១០១ | 0,៨លាន ហ.ត |
| ចំនួនគ្រួសារដែលបានចុះបញ្ជីកាន់កាប់ដីកសិកម្មជាមួយការធ្វើកសិកម្មដាច់ដោយឡែក | ១,៩លាន |
| ចំនួនគ្រួសារចូលរួមសកម្មភាពកសិកម្ម ដែលបានប្រើប្រាស់តែផ្ទៃដីបរិវេណជុំវិញផ្ទះប៉ុណ្ណោះ | ២៥៣.៤៣៧ |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្ម ក្នុងចំណោមគ្រួសារសរុបដែលបានចុះបញ្ជី | ៨២,0% |
| ភាគរយនៃគ្រួសារដែលបានធ្វើកសិកម្មលើដីបរិវេណជុំវិញផ្ទះក្នុងចំណោមគ្រួសារសរុបដែលបានចុះបញ្ជី | ១១,៩% |
| ភាគរយនៃគ្រួសារដែលបានចូលរួមក្នុងការដាំដុះដំណាំលើដីកសិកម្ម ក្នុងចំណោមគ្រួសារកសិកម្មសរុប | ៨៥,៣% |
| ចំនួនក្បាលដីជាមធ្យមក្នុងគ្រួសារកាន់កាប់កសិកម្មនរួមជាមួយដីកសិកម្មជុំវិញផ្ទះ | ២,៥ |
| ទំហំផ្ទៃដីជាមធ្យមក្នុងមួយក្បាលដីក្នុងគ្រួសារកាន់កាប់ដីកសិកម្មរួមជាមួយដីជុំវិញផ្ទះ | 0,៦ហ.ត |
| មធ្យមផ្ទៃដីនៃគ្រួសារកាន់កាប់ដីកសិកម្មដាច់ដោយឡែកមិនរាប់បញ្ចូលដីកសិកម្មជុំវិញផ្ទះ | ១,៦ហ.ត |
| មធ្យមផ្ទៃដីនៃគ្រួសារកាន់កាប់ដីកសិកម្មដាច់ដោយឡែក រួមបញ្ចូលដីកសិកម្មជុំវិញផ្ទះ | ១,៧ហ.ត |
| មធ្យមផ្ទៃដីនៃគ្រួសារកាន់កាប់ដីកសិកម្មទាំងអស់ (រួមទាំងដីកសិកម្មជុំវិញផ្ទះ) | ១,៥៥ហ.ត |
| ភាគរយនៃចំនួនគ្រួសារកាន់កាប់កសិកម្មដែលមានផ្ទៃដីតិចជាង ១ហិកតាក្នុងចំណោមការកាត់កាប់គ្រួសារកសិកម្មដែលមានដីដាច់ដោយឡែក | ៤៧% |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មផ្ទៃដីតិចជាង ១ហិកតាក្នុងចំណោមផ្ទៃដីនៃការកាត់កាប់គ្រួសារកសិកម្មដែលមានដីដាច់ដោយឡែក | ២៦,៦ % |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលមានផ្ទៃដីទំហំ២០ហិកតា ឬច្រើនជាងក្នុងចំណោមការកាត់កាប់គ្រួសារកសិកម្មដែលមានដីដាច់ដោយឡែក។ | 0,២៤% |
| ភាគរយនៃគ្រួសារកាន់កាប់កសិកម្មដែលមានផ្ទៃដីទំហំ២០ហិកតា ឬច្រើនជាងក្នុងចំណោមផ្ទៃដីនៃការកាត់កាប់គ្រួសារកសិកម្មដែលមានដីដាច់ដោយឡែក។ | ៦,១% |

| ដំណាក់កាលបំពេញបន្ថែម៖ ការដាំដុះដំណាំ<br>(តំណាក់កាលបំពេញបន្ថែមនៃជំរឿនកសិកម្ម គ្រួសារកាន់កាប់សិកម្មដែលមានទំហំសំណាកគំរូប្រមាណ 98.000 គ្រួសារ) | |
|---|---|
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំធញ្ញជាតិ និងធញ្ញជាតិយកគ្រាប់ក្នុងចំណោមផ្ទៃដីសរុបទាំងអស់នៃការកាន់កាប់គ្រួសារកសិកម្ម | ៧៤.២% |
| ភាគរយផ្ទៃដីសរុបដែលបានដាំដំណាំស្រូវ ក្នុងចំណោមផ្ទៃដីសរុបទាំងអស់ នៃការកាន់កាប់គ្រួសារកសិកម្ម | ៧០,៣% |
| ភាគរយនៃផ្ទៃដីសរុបដាំដំណាំស្រូវធម្មតា ក្នុងចំណោមដំណាំធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់ | ៨៣% |
| ភាគរយនៃផ្ទៃដី សរុបដែលបានដាំដំណាំដំឡូងមី ក្នុងចំណោមផ្ទៃដីសរុប | ៩% |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំដំឡូងមី ក្នុងចំណោមផ្ទៃដីសរុបដាំដំណាំយកមើម | ៩៨% |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំយកប្រេងក្នុងចំណោមផ្ទៃដីសរុបនៃការកាន់កាប់គ្រួសារកសិកម្ម | ១.0% |
| ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំបន្លែក្នុងចំណោមផ្ទៃដីសរុបនៃការកាន់កាប់គ្រួសារកសិកម្ម | ១,៣% |
| ភាគរយនៃក្បាលដីបានស្រោចស្រពក្នុងចំណោមក្បាលដីសរុបគ្រួសារកសិកម្មរួមបញ្ចូលដីកសិកម្ម ជុំវិញផ្ទះ | ៣២,២% |
| ភាគរយនៃផ្ទៃដីស្រោចស្រពបានអនុវត្ត ក្នុងចំណោមផ្ទៃដីគ្រួសារកាន់កាប់កសិកម្មសរុប | ២២% |
| ភាគរយផ្ទៃដីអនុវត្តដាំដុះដំណាំស្រូវបានស្រោចស្រព ក្នុងចំណោមផ្ទៃដីបានដាំដុះស្រូវសរុប | ២៧,៩% |
| ភាគរយនៃគ្រួសារកសិកម្មប្រើប្រាស់ជីគីមី | ៧0% |
| ភាគរយនៃគ្រួសារកសិកម្មប្រើប្រាស់ជីសរីរាង្គ | ៥0% |
| ភាគរយនៃគ្រួសារកសិកម្មប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងផ្សិត | ៩% |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរាយការណ៍ថាបានប្រើប្រាស់គ្រាប់ពូជស្រូវផ្ទាល់ខ្លួន | ៧២% |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរាយការណ៍ថាបានប្រើប្រាស់សេវាផ្សព្វផ្សាយដោយរាជរដ្ឋាភិបាល | ៣0% |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរាយការណ៍ថាបានទទួលព័ត៌មានកសិកម្មតាមវិទ្យុ | ៥២% |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរាយការណ៍ថាមានទីផ្សារនៅជិតសម្រាប់លក់ផលិតផលកសិកម្ម | ៧0% |

| ដំណាក់កាលបំពេញបន្ថែម៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី | |
|---|---|
| ចំនួនភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុក និងចិញ្ចឹមបសុសត្វ និង/ឬបសុបក្សី | ៧៥% |
| ចំនួនភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុក និងចិញ្ចឹមបសុសត្វប្រភេទធំ | ៦៦% |
| ចំនួនភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុក និងចិញ្ចឹមបសុសត្វប្រភេទតូច | ២៨% |
| ចំនួនភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុក និងចិញ្ចឹមបសុបក្សី | ៨៥% |

| | |
|---|---|
| ចំនួនភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុក និងចិញ្ចឹមសត្វជ្រូកក្នុងចំណោមគ្រួសារ ចិញ្ចឹមបសុសត្វប្រភេទតូចសរុប | ៩៨% |
| ចំនួនភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុក និងចិញ្ចឹម ២ ទៅ ៩ក្បាលបសុសត្វប្រភេទធំនៃចំនួនគ្រួសារកសិកម្មចិញ្ចឹមសត្វសរុប | ៨៦% |
| ចំនួនភាគរយនៃគ្រួសារកសិកម្មដែលបានរក្សាទុក និងចិញ្ចឹមបសុបក្សីពី ២៥ និង ៤៩៩ នៃគ្រួសារកសិកម្មសរុបបចិញ្ចឹមបសុបក្សី | ៧0% |
| ភាគរយនៃសត្វមាន់ជិទង់សរុប (10 ថ្ងៃឬច្រើនជាងនេះ) | ៥៧% |
| ភាគរយនៃសត្វទាជិទង់សរុប (10 ថ្ងៃឬច្រើនជាងនេះ) | ៨២% |
| ភាគរយនៃគ្រួសារសិកម្មបានរាយការណ៍ដើម្បីរក្សាទុកបសុសត្វនិងបសុបក្សីនៅក្នុងផ្ទះ | ៩៦% |
| ភាគរយនៃសត្វគោ តាមរយៈការបញ្ចេញលក់នៅរស់ដោយផ្ទាល់ | ៧៨% |
| ភាគរយនៃសត្វក្របី តាមរយៈការបញ្ចេញលក់នៅរស់ដោយផ្ទាល់ | ៥៥% |
| ភាគរយនៃសត្វជ្រូក តាមរយៈការបញ្ចេញលក់នៅរស់ដោយផ្ទាល់ | ៩0% |
| ភាគរយនៃសត្វមាន់ តាមរយៈការបញ្ចេញលក់ទាំងរស់ដោយផ្ទាល់នៅទីផ្សារ | ៤៧% |
| **ដំណាក់កាលបំពេញបន្ថែម៖ ការនេសាទនិងវារីវប្បកម្ម** | |
| គ្រួសារកសិកម្មបានចូលរួមក្នុងការនេសាទ និងវារីវប្បកម្ម | **៥២៥.៩៥២** |
| ភាគរយគ្រួសារបានចូលរួមការនេសាទសុទ្ធក្នុងចំណោមគ្រួសារសរុបបានចូលរួមក្នុងការនេសាទ និងវារីវប្បកម្ម | ១១% |
| ភាគរយគ្រួសារកសិកម្មបានចូលរួមនេសាទ និងវារីវប្បកម្ម ក្នុងចំណោមគ្រួសារសរុបបានចូលរួមក្នុងការនេសាទ និងវារីវប្បកម្ម | ១% |
| ភាគរយគ្រួសារកសិកម្មបានចូលរួមការនេសាទជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារក្នុងចំណោមគ្រួសារសរុបបានចូលរួមក្នុងការនេសាទ និងវារីវប្បកម្ម | ៩0% |
| ភាគរយនៃគ្រួសារវារីវប្បកម្មចិញ្ចឹមសត្វ រុក្ខជាតិនៅក្នុងទឹកតាមបែបធម្មជាតិ ឬសិប្បនិម្មិតក្នុងចំណោមគ្រួសារសរុបបានចូលរួមវារីវប្បកម្ម | ៩0% |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរាយការណ៍ថាការប្រើប្រាស់ឧបករណ៍ សំណាញ់ មុងលើក និងមុងរុញសម្រាប់ការនេសាទក្នុងចំណោមគ្រួសារសរុបបានចូលរួមនេសាទ | ៦0% |
| **ដំណាក់កាលបំពេញបន្ថែម៖ សកម្មភាពសេដ្ឋកិច្ចបន្ថែមក្នុងគ្រួសារកសិកម្ម** | |
| ភាគរយនៃគ្រួសារកសិកម្មបានរាយការណ៍ថា ចូលរួមក្នុងសកម្មភាពដែលទាក់ទងនឹងព្រៃឈើក្នុងចំណោមការកាន់កាប់របស់គ្រួសារកសិកម្ម | ៣៨% |

| | |
|---|---|
| ភាគរយនៃគ្រួសារកសិកម្មបានរាយការណ៍ថា ចូលរួមក្នុងសកម្មភាពដែលទាក់ទងនឹងព្រៃឈើគោលបំណងរកអុសនិង/ឬប្រមូលផលបូស្សី ក្នុងចំណោមគ្រួសារកសិកម្មទាក់ទងនឹងព្រៃឈើសរុប | ៩៧% |
| ភាគរយនៃគ្រួសារកសិកម្មបានរាយការណ៍ថា ចូលសកម្មភាពនៅក្នុងអាជីវកម្មខ្នាតតូចការធ្វើពាណិជ្ជកម្មពីការកាន់កាប់របស់គ្រួសារកសិកម្មសរុប | ៥0% |
| **ដំណាក់កាលបំពេញបន្ថែម៖ គ្រួសារកសិកម្មនិងប្រជាជន** | |
| ការប៉ាន់ប្រមាណប្រជាជន | ៨,៥លាន |
| អត្រាភេទ (ចំនួនស្ត្រី នៃ ១.000 បុរស) ក្នុងចំណោមប្រជាជននៃគ្រួសារកសិកម្មជាមួយនឹងការកាន់កាប់ផ្នែកកសិកម្ម | ៩៩៧ |
| ភាគរយនៃបុរសជាមេគ្រួសារ | ៧៨,២% |
| អាយុមធ្យមនៃប្រជាជន | ២៨,៨ឆ្នាំ |
| ភាគរយនៃសមាជិកគ្រួសារនៅក្នុងបន្ទុក (អ្នកដែលមានតិចជាង ១៥ឆ្នាំនិងអ្នកដែលមានអាយុ ៦0ឆ្នាំឡើងទៅ) ក្នុងចំណោមប្រជាជនសរុបនៃគ្រួសារកសិកម្ម | ១៩% |
| ភាគរយនៃសមាជិកដែលបានរៀបការក្នុងចំណោមប្រជាជនសរុបនៃគ្រួសារកសិកម្ម | ៥២% |
| **ដំណាក់កាលបំពេញបន្ថែម៖ សន្តិសុខស្បៀងនៃគ្រួសារកសិកម្ម** | |
| ភាគរយគិតជាមធ្យមនៃគ្រួសារកសិកម្មដែលបានបរិភោគអង្ករ ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍ | ៩៩,៩% |
| ចំនួនថ្ងៃជាមធ្យមក្នុងមួយសប្ដាហ៍នៃគ្រួសារកសិកម្មដែលបានបរិភោគបន្លែ | ៥ ថ្ងៃ |
| ចំនួនថ្ងៃជាមធ្យមក្នុងមួយសប្ដាហ៍នៃគ្រួសារកសិកម្មដែលបានបរិភោគសាច់ និងផលិតផលធ្វើពីសាច់ | ៤ ថ្ងៃ |
| ភាគរយនៃគ្រួសារកសិកម្មដែលបានរាយការណ៍ថា ជួបប្រទះនិងកង្វះស្បៀងអាហារក្នុងអំឡុងពេល ១២ខែ | ១៦% |
| ភាគរយនៃគ្រួសារកសិកម្មដែលបានជួបប្រទះនិងកង្វះស្បៀងអាហារដោយសារមូលហេតុទិន្នផលដំណាំទាប | ៨0% |
| ភាគរយនៃគ្រួសារកសិកម្មរាយការណ៍ថា បានដោះស្រាយបញ្ហាកង្វះស្បៀងអាហារចម្បងគឺ ខ្ចីប្រាក់និងខ្ចីស្បៀងអាហារមុន ដើម្បីទទួលបានអាហារ នឹងសងវិញនៅពេលប្រមូលផល | ៨៩% |

# ពាក្យសរសេរកាត់

| | |
|---|---|
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| DAHP | នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល |
| FAO | ស្បៀងនិងកសិកម្មអង្គការសហប្រជាជាតិ |
| FAOSTAT | ស្ថិតិស្បៀងនិងកសិកម្មអង្គការសហប្រជាជាតិ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MOP | ក្រសួងផែនការ |
| CAC | ជំរឿនកសិកម្មជាតិ នៅព្រះរាជាណាចក្រកម្ពុជា |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| Sida | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |

# ជំពូកទី១
# ទំហំ វិសាលភាព និងការជ្រើសរើសសំណាកគំរូ

ជំរឿនកសិកម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា (ជ ក ក) បានធ្វើឡើងនៅឆ្នាំ ២០១៣ គឺផ្ដោតសំខាន់ទៅលើការប្រមូល និងចងក្រងស្ថិតិដ៏ទូលំទូលាយស្ដីពី ការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី និងវារីវប្បកម្ម។ ទិន្នន័យដែលបានប្រមូល និងចងក្រងស្ថិតិពីការជំរឿននេះត្រូវបានប្រើប្រាស់ក្នុងការរៀបចំ ផែនការ និងកសាងគោលនយោបាយ និងកម្មវិធីសម្រាប់អភិវឌ្ឍ និងការលើកកម្ពស់វិស័យកសិកម្ម និងវារីវប្បកម្ម នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា។ ជំរឿនកសិកម្មគឺជាជំរឿនលើកទី១បានធ្វើនៅព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិ (វ ជ ស) នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក ស ក) គឺជាស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើជំរឿនកសិកម្មជាតិឆ្នាំ២០១៣។ វិទ្យាស្ថានជាតិស្ថិតិ (វ ជ ស) ត្រូវបានប្រគល់សិទ្ធិឱ្យធ្វើជំរឿន ចំណែកឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគឺជាអ្នកប្រើប្រាស់ទិន្នន័យចម្បងដែលផលិតបានពីការធ្វើជំរឿននេះ។

## គោលបំណង

គោលដៅចម្បង នៃការធ្វើជំរឿនកសិកម្មជាតិនៅកម្ពុជាឆ្នាំ២០១៣ គឺដើម្បីផ្ដល់នូវទិន្នន័យស្ដីពីស្ថានភាពកសិកម្មគ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជា ដែលនឹងត្រូវបានប្រើប្រាស់ដោយអ្នករៀបចំផែនការ និងអ្នកបង្កើតគោលនយោបាយ។ ជាពិសេសទិន្នន័យជំរឿននេះនឹងផ្ដល់សារៈប្រយោជន៍ជាច្រើនផ្សេងទៀត÷

១. ការផ្ដល់បញ្ជីមេសម្រាប់ជ្រើសរើសសំណាកគំរូធ្វើអង្កេតកសិកម្ម

២. ការផ្ដល់ទិន្នន័យរដ្ឋបាលលម្អិតតូចបំផុតនៅក្នុងប្រទេសកម្ពុជា

៣. ការផ្ដល់ទិន្នន័យស្ដីពីរចនាសម្ព័ន្ធ នៃការកាន់កាប់ផ្ទៃដីកសិកម្មបច្ចុប្បន្ន ការដាំដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី និងវារីវប្បកម្មនៅក្នុងប្រទេសកម្ពុជា។

ខណៈដែលសំណុំទិន្នន័យដែលបានកំណត់ នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ខេត្តដែលត្រូវបានបង្ហាញនៅក្នុងតារាងស្ថិតិសង្ខេបនៃ ឧបសម្ព័ន្ធនៅក្នុងរបាយការណ៍នេះ សំណុំទិន្នន័យនេះមានទំហំធំ និងលម្អិតដែលមានភាពត្រឹមត្រូវនៅក្នុងកម្រិតឃុំសង្កាត់ដែលអាចរកបានតាមរយៈ វិទ្យាស្ថានជាតិស្ថិតិ។ ការគ្របដណ្ដប់ពេញលេញនៃការធ្វើជំរឿន និងតំណាក់កាលបំពេញបន្ថែមដែលបានបង្កើតតាមការធ្វើអង្កេត នេះអាចត្រូវបានពិនិត្យជាលម្អិតនៃកម្រងសំណួរដែលអាចរកបានពីគេហទំព័ររបស់ វិទ្យាស្ថានជាតិស្ថិតិ ។ ទិន្នន័យទាំងនេះបង្កើតនូវសក្ដានុពល នៃការវិភាគដ៏ទូលំទូលាយនឹងត្រូវបានធ្វើអោយប្រសើរឡើងនៅពេលក្រោយ នៃវិសាលភាពរបាយការណ៍នេះ។

## វិធីសាស្ត្រ

វិធីសាស្ត្រដ៏ទូលំទូលាយសម្រាប់ការធ្វើជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់អត្តសញ្ញាណ និងបានចូលទៅដល់ក្រុមគ្រួសារទាំងឡាយនៅគ្រប់ខេត្តរាជធានីនៅព្រះរាជាណាចក្រកម្ពុជាលើកលែងតំបន់ប្រជុំជនក្នុងរាជធានីភ្នំពេញ។ មន្ត្រីសម្ភាសន៍ជំរឿនត្រូវបានជ្រើសរើសគ្រប់ខេត្ត និងបណ្តុះបណ្តាលឱ្យទទួលបានការយល់ដឹងដ៏ទូលំទូលាយសម្រាប់ការធ្វើជំរឿននេះ។ គ្រួសារចំនួន ២,៦ លាន គ្រួសារស្ថិតនៅក្នុងតំបន់គោលដៅជំរឿន គ្រួសារកាន់កាប់កសិកម្មចំនួន ២,១លានគ្រួសារត្រូវបានកំណត់យោងទៅតាម លក្ខខណ្ឌដែលតម្រូវឱ្យមានផ្ទៃដីដាំដំណាំចំនួន ០,០៣ហិកតា ឬមានចិញ្ចឹមបសុសត្វប្រភេទធំយ៉ាងតិច ២ក្បាល ឬបសុសត្វ ប្រភេទប្រភេទតូចចំនួន ៣ក្បាល ឬយ៉ាងហោចណាស់បសុបក្សីចំនួន ២៥ក្បាល។ ក្នុងចំណោមគ្រួសារចំនួន ២,១លានគ្រួសារនោះមានក្បាលដីកសិកម្មចំនួន ៥,៦៦លានក្បាលដី នៃផ្ទៃដីសរុបចំនួន ៣,៣លានហិកតា។ គ្រួសារកសិកម្មទាំងនេះ បានផ្តល់ព័ត៌មានមូលដ្ឋានស្តីពី គ្រួសារលក្ខណៈទូទៅនៃការកាន់កាប់ដីកសិកម្ម និងសកម្មភាពកសិកម្មរបស់ពួកគាត់ផ្តល់សំណុំទិន្នន័យពេញលេញ សម្រាប់សំណួរសំខាន់ៗដែលបានជ្រើសរើស។ ដើម្បីពង្រីកសំណុំទិន្នន័យ និងឱ្យគ្របដណ្តប់កាន់តែលម្អិតវិធីសាស្ត្រអង្កេតសមមាត្រទៅនឹងប្រជាជនត្រូវបានប្រើប្រាស់ជ្រើសរើសចេញពីបញ្ជីមេដើម្បីប្រមូលទិន្នន័យដែលទាក់ទងនឹងសកម្មភាពគ្រួសារ និងលក្ខខណ្ឌផ្សេងៗ។

សំណុំព័ត៌មានត្រូវបានពង្រីកបន្ថែមទៀតតាមរយៈតារាងសំណួរសម្ភាសមេភូមិ និងសំណួរតាមដានសម្រាប់ការកាន់កាប់ដីមានឯកសារស្របច្បាប់ដែលបានរកឃើញក្នុងពេលជំរឿន។ ដោយសារជំរឿនត្រូវបានធ្វើតាមគ្រួសារ ការកាន់កាប់ដីមានឯកសារស្របច្បាប់មានកម្រិតកំណត់បំផុត ដែលបានរកឃើញក្នុងដំណើរការជំរឿន។ ព័ត៌មានស្តីពីការកាន់កាប់ដី ដែលមានឯកសារស្របច្បាប់មិនត្រូវបានពិចារណាស៊ីជម្រៅដូចវិសាលភាព ដែលបានផ្តល់ឱ្យសម្រាប់សេចក្តីសន្និដ្ឋានក្នុងដំណើរការប្រមូលព័ត៌មាន។ ជំរឿននៅក្នុងដំណាក់ដំបូងគឺជាជំរឿនគ្រួសារកាន់កាប់កសិកម្ម ហើយគ្រួសារតាំងទីលំនៅ នៅទីប្រជុំជនក្នុងរាជធានីភ្នំពេញត្រូវបានដកចេញពីតំបន់ជំរឿន។

នៅពេលដែលក្រុមគ្រួសារត្រូវបានកំណត់ច្បាស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាគ្រួសារកសិកម្ម ការកាន់កាប់ដីកសិកម្មរបស់ពួកគាត់ត្រូវបានប៉ាន់ប្រមាណដោយកំណត់ផ្អែកតាមលក្ខខណ្ឌគ្រួសារមានដីកសិកម្មដាច់ដោយឡែកពីដីលំនៅដ្ឋាន ឬមានដីលំនៅដ្ឋាន និងសកម្មភាពផលិតកម្មត្រូវបានប៉ាន់ប្រមាណថាមានការកាន់កាប់ដីផ្សេងគ្នា។ ប្រជាជនគោលដៅនៅក្នុងជំរឿនត្រូវបានកម្រិតកំណត់ថាមានកាន់កាប់ដីកសិកម្មដាច់ដោយឡែក ចំណែកឯគ្រួសារកសិកម្មដែលមានតែដីលំនៅដ្ឋានប៉ុណ្ណោះមិនត្រូវបានរាប់បញ្ចូលក្នុងបញ្ជីគំរូ។ ការសម្រេចចិត្តនេះត្រូវបានធ្វើឡើង ដើម្បីធ្វើឱ្យដំណើរការធ្វើអង្កេតមានភាពងាយស្រួល និងដើម្បីផ្តោតលើការ

ប្រមូលព័ត៌មានស្តីពីក្រុមគ្រួសារភាគច្រើនដែលតំណាងឱ្យទំហំផលិតកម្ម។ ក្នុងទំហំផលិតកម្មសរុប ១.៨៨លាន ក្រុមគ្រួសារមាន ៥.៤លានក្បាលដី ជាដីកម្មសិទ្ធផ្ទាល់ខ្លួន និង៣.៣ លានហិកតា។

## វិសាលភាពជំរឿន

ជំរឿនកសិកម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា (ជ ក ក) ឆ្នាំ២០១៣ នេះបានប្រើប្រាស់នូវទម្រង់សំណួរប្រាំមួយសម្រាប់ជំរឿន និងអង្កេតគ្រួសារកសិកម្ម។ ទម្រង់សំណួរពីរ (ទម្រង់ A & B) ត្រូវបានគេប្រើប្រាស់នៅក្នុងដំណាក់កាលគោល និងជាមូលដ្ឋានក្នុងការធ្វើជំរឿនដែលមានក្នុងគោលបំណងដើម្បីគ្របដណ្តប់គ្រប់គ្រួសារនៅជាយក្រុងនៃរាជធានីភ្នំពេញ។ ទម្រង់សំណួរបួនផ្សេងទៀត (ទម្រង់ C, D, E និង F) ត្រូវបានគេប្រើប្រាស់នៅក្នុងដំណាក់កាលអង្កេតបំពេញបន្ថែម ហើយទិន្នន័យលម្អិតត្រូវបានប្រមូលដោយផ្អែកលើគ្រួសារគំរូ។ ទម្រង់សំណួរមួយទៀត (ទម្រង់ G) ត្រូវប្រើប្រាស់សួរទៅកាន់មេភូមិដើម្បីប្រមូលព័ត៌មានស្តីពីលក្ខណៈភូមិសាស្ត្រ ភាពលំបាក ឬគ្រោះមហន្តរាយ និងភាពដែលផ្តល់ជាប្រយោជន៍ដល់សកម្មភាពសេដ្ឋកិច្ចជាដើម។ល។ រហូតដល់ហេដ្ឋារចនាសម្ព័ន្ធកម្រិតភូមិ។ ដោយឡែកពីនេះទៀត ទម្រង់សំណួរ G ត្រូវបានគេប្រើប្រាស់ដើម្បីប្រមូលទិន្នន័យសម្រាប់គ្រួសារដែលមិនមែនជាគ្រួសារកសិកម្ម។ កម្រងសំណួរទាំងនេះ គឺអាចរកបាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

វិសាលភាព នៃទម្រង់សំណួរនីមួយៗនេះគឺមានដូចខាងក្រោមៈ

**ទម្រង់ A តារាងចុះបញ្ជីគ្រួសារ÷** ប្រមូលព័ត៌មានភូមិសាស្ត្រ និងព័ត៌មានទាក់ទងនឹងគ្រួសារធ្វើសកម្មភាពកសិកម្ម និងវារីវប្បកម្ម។ ទម្រង់សំណួរនេះ ត្រូវបានគេប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណគ្រួសារកសិកម្មដែលមានការកាន់កាប់ដីកសិកម្មប្រើប្រាស់ក្នុងគោលបំណងកសិកម្មត្រូវបានរាប់បញ្ចូលក្នុងការធ្វើជំរឿន ។

**ទម្រង់ B ព័ត៌មានមូលដ្ឋានអំពីកសិដ្ឋាន÷** ប្រមូលព័ត៌មានភូមិសាស្ត្រ ព័ត៌មានអ្នកផ្តល់ចម្លើយ និងព័ត៌មានរបស់ម្ចាស់កសិដ្ឋាន ភាពស្របច្បាប់របស់ម្ចាស់កសិដ្ឋាន ចរិកលក្ខណៈមូលដ្ឋានរបស់កសិដ្ឋានដូចជាទំហំ និងចំនួនក្បាលដីដែលបានកាន់កាប់ និងទីតាំង ដីជាក់ស្តែង ការប្រើប្រាស់ដីចម្បង និងស្ថានភាពដីនៃក្បាលដីនៅក្នុងកសិដ្ឋាន ដីព្រៃនិងដីព្រៃឈើដទៃទៀត ការប្រើប្រាស់ការស្រោចស្រព ដំណាំអចិន្ត្រៃយ៍ដែលបានដាំ គោលបំណងចម្បងនៃផលិតកម្ម ការចិញ្ចឹមបសុសត្វ និងបសុបក្សីនៅក្នុងកសិដ្ឋាន ការធ្វើវារីវប្បកម្ម និងព័ត៌មានគ្រួសាររបស់ម្ចាស់ដី។

**ទម្រង់ C ការដាំដំណាំ ÷** ប្រមូលព័ត៌មានស្តីពីទីតាំង អ្នកទទួលខុសត្រូវ និងម្ចាស់កសិដ្ឋានព្រមទាំងអ្នកតំណាងម្ចាស់កសិដ្ឋាន ដំណាំរយៈពេលខ្លីដែលបានដាំ និងបានប្រមូលផលរួមបញ្ចូលទាំងដីបានដាំ រយៈពេលដាំ ការដាំដំណាំតាមលក្ខណៈបច្ចេកទេស ដីដែលបានប្រមូលផល ដំណាំអចិន្ត្រៃយ៍រួមទាំងទំហំផ្ទៃដីដំណាំដែលបានដាំជាជួរ និងចំនួនដើមនៃដំណាំអចិន្ត្រៃដែលបានដាំរាយប៉ាយ ការស្រោចស្រព និងព័ត៌មានផ្សេងទៀតទាក់ទងនឹងក្បាលដី សកម្មភាពនៃកសិកម្មនៅជំវិញផ្ទះ ការអនុវត្តកសិកម្ម ឧបករណ៍ បរិក្ខា និងគ្រឿងម៉ាស៊ីនដែលបានបប្រើប្រាស់ក្នុងការកាន់កាប់ កសិកម្ម សេវាកម្មកសិកម្ម ភាពជាកម្មសិទ្ធិរបស់កសិដ្ឋាន និងព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធ។

**ទម្រង់ D ការចិញ្ចឹមបសុសត្វនិងបសុបក្សី÷** ប្រមូលព័ត៌មានស្តីពីទីតាំង អ្នកទទួលខុសត្រូវ ម្ចាស់កសិដ្ឋាន និងតំណាងម្ចាស់កសិដ្ឋាន បសុសត្វ និងបសុបក្សីដែលបានចិញ្ចឹមគិតត្រឹមថ្ងៃជំរឿន ចំនួនបសុសត្វ បសុបក្សីដែលមានក្នុងរយៈពេល១២ខែកន្លងមក ឧបករណ៍ប្រើប្រាស់ គ្រឿងយន្ត អគារ និងភាពដែលអាចរកបានសេវាកម្មកសិកម្ម។

**ទម្រង់ E - សកម្មភាពវារីវប្បកម្ម៖** ប្រមូលព័ត៌មានអំពីទីតាំង អ្នកទទួលខុសត្រូវ និងម្ចាស់វារីវប្បកម្មនិងតំណាងម្ចាស់វារីវប្បកម្ម សកម្មភាពវារីវប្បកម្មលម្អិត រួមបញ្ចូលទាំងប្រភេទនៃការចិញ្ចឹម ទីតាំង តំបន់ដីជាក់ស្តែងដែលធ្វើកសិកម្ម សម្ភារៈបរិក្ខាផលិតកម្ម ប្រភេទទឹកដែលបានប្រើប្រាស់ ប្រភេទវារីវប្បកម្មចម្បង ឧបករណ៍និងគ្រឿងយន្តដែលបានប្រើប្រាស់ ក្រុមគ្រួសារដែលបានចូលរួម កំលាំងពលកម្មដែលបានជួល និងព័ត៌មានផ្សេងទៀតៗដែលទាក់ទង។

**ទម្រង់ F - ព័ត៌មានទាក់ទងស្តីពីគ្រួសារកសិកម្ម៖** ប្រមូលព័ត៌មានស្តីពីពីទីតាំង អ្នកទទួលខុសត្រូវ និងអ្នកកាន់កាប់ដីកសិកម្ម គ្រួសារកសិកម្ម ចំនួនគ្រួសារ ឈ្មោះ សាច់ញាតិមេគ្រួសារ ភេទ អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ កម្រិតសិក្សាដែលបានបញ្ចប់ពេញលេញខ្ពស់បំផុត កម្រិតថ្នាក់សិក្សានាពេលបច្ចុប្បន្ន ភាពលំបាកទាំងផ្លូវកាយ និងផ្លូវចិត្ត សកម្មភាពសេដ្ឋកិច្ចចម្បងនិងបន្ទាប់បន្សំ និងស្ថានភាពការងារនិងភារកិច្ចដែលបានធ្វើនៅក្នុងកសិដ្ឋានក្នុងរយៈពេល ១២ ខែកន្លងមក ការធ្វើដំណាំផ្សេងៗទៀត សន្តិសុខស្បៀង សកម្មភាពសេដ្ឋកិច្ចដទៃទៀត ដូចជាការនេសាទត្រីនិងផលិតផលជលជាតិនៅតាមផ្លូវទឹក នៅក្នុងសមុទ្រឬនៅឆ្ងាយពីសមុទ្រ សកម្មភាពដែលទាក់ទងនឹងព្រៃឈើជាដើម។

**ទម្រង់ G-កម្រងសំណួរភូមិ៖** ប្រមូលព័ត៌មានស្តីពីប្រភេទដី លក្ខណៈចម្បងនៃតំបន់ភូមិសាស្ត្រ ប្រភេទគ្រោះភ័យ ឬគ្រោះមហន្តរាយក្នុងរយៈពេល ៥ ឆ្នាំកន្លងមក សកម្មភាពសេដ្ឋកិច្ចដែលមាន កំលាំងពលកម្មផ្លាស់ប្តូរតាមរដូវកាល រយៈពេលដាំដំណាំ ឧបករណ៍សម្ភារៈ និងមធ្យោបាយកសិកម្មកែច្នៃ គ្រឿងយន្ត និងបរិក្ខា មធ្យោបាយដឹកជញ្ជូន សាលារៀនដែលមាន មធ្យោបាយដែលអាចទំនាក់ទំនងបាន ការថែទាំសុខភាព ការប្រើប្រាស់ទឹក ស្ថានភាពផ្លូវថ្នល់ និងទីផ្សារ វត្តមានបុគ្គលិករបស់អង្គការ ព្រមទាំងវត្តមានអង្គការជាតិ អន្តរជាតិ វប្បធម៌ និងជំនឿសាសនា។

គ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសនៅក្នុងដំណាក់កាលដំបូងដោយប្រើប្រាស់កម្រងសំណួរ A ដើម្បីកំណត់ការចូលរួមរបស់ពួកគាត់នៅក្នុងការកាន់កាប់ដីដែលធ្វើកសិកម្ម។ ក្នុងករណីគ្រួសារណាមួយត្រូវបានរកឃើញបានចូលរួមនៅក្នុងសកម្មភាពធ្វើកសិកម្ម និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់យោងតាមនិយមន័យ នៃការកាន់កាប់កសិកម្ម។ គ្រួសារកសិកម្មនោះត្រូវបានគេសំភាសន៍បន្ថែមដោយប្រើប្រាស់កម្រងសំណួរ B។ ទិន្នន័យលម្អិតអំពីការធ្វើកសិកម្មត្រូវបានប្រមូលដោយប្រើប្រាស់កម្រងសំណួរ F និង C និង / ឬ D និង / ឬកម្រងសំណួរ E នៅក្នុងដំណាក់កាលអង្កេតបំពេញបន្ថែម គ្រួសារគំរូត្រូវបានជ្រើសរើសដោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសគំរូចៃដន្យប្រូបាប៊ីលីតេ។

## ទីតាំងភូមិសាស្ត្រគ្របដណ្តប់

គ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជាទាំងមូលលែងតែខណ្ឌមួយចំនួន៤នៅក្នុងរាជធានីភ្នំពេញ ដែលគេស្គាល់ថាស្ថិតនៅជាយក្រុងដែលត្រូវបានរាប់បញ្ចូលក្នុងការធ្វើជំរឿនជាតិកសិកម្មនៅកម្ពុជាឆ្នាំ២០១៣ រួមជាមួយគ្រឹះស្ថានកសិកម្មខ្នាតធំដែលប្រតិបត្តិដោយក្រុមហ៊ុន សហករណ៍ ស្ថាប័នសាធារណៈ និងផ្នែកឯកជនដែលឱ្យឈ្មោះថា "ដីកសិកម្មគតិយុត្ត" នៅក្នុងវិស័យមិនមែនគ្រួសារ។

ការកាន់កាប់កសិកម្មជាកម្មសិទ្ធិ ដែលបានគ្រប់គ្រង និងដំណើរការដោយគ្រួសារនៅទីប្រជុំជន ឬអង្គភាពមិនបានជួបប្រទះ នៅក្នុងតំបន់ដែលគ្របដណ្តប់ដោយការធ្វើជំរឿន ដូច្នេះវាត្រូវបានរក្សាទុកនៅពេលក្រោយនៃការធ្វើអង្កេត ។ គ្រឹះស្ថានកសិកម្មខ្នាតតូចដែលបានចូលរួមក្នុងកសិដ្ឋានកសិកម្ម ដែលមិនមែនជាគ្រួសារធម្មតា មិនត្រូវបានគ្របដណ្តប់នៅក្នុងការអង្កេតនេះទេ ព្រោះថាគ្រួសារដែលបានរាប់បញ្ចូលនៅក្នុងការអង្កេតនេះមិនត្រូវបានគេចាត់ទុក

ថាលក្ខណៈសេដ្ឋកិច្ចទេ។ ភូមិទាំងអស់ដែលមានការកាន់កាប់កសិកម្មចំនួន (៥ ឬតិចជាង) នោះត្រូវបានគេដកចេញពីបញ្ជីសំណាកគំរូសម្រាប់ដំណាក់កាលបំពេញបន្ថែម។

## អង្កេត និងកាលបរិច្ឆេទយោង

ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣នេះ ត្រូវបានអនុវត្តជាពីរដំណាក់កាល: ដំណាក់កាលស្នូលទីមួយមានន័យថាសម្រាប់ការចុះបញ្ជីនៃគ្រួសារទាំងអស់នៅក្នុងភូមិទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានអនុវត្តក្នុងរយៈពេល ៤៥ថ្ងៃ ពីថ្ងៃទី១៧ ខែមេសាឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ និងបែបបទបន្ថែមត្រូវបានគេយកពីខែវិច្ឆិកា ថ្ងៃទី០១ ដល់ ២២ ឆ្នាំ២០១៣ មានជាងតិចតួចនៃការធ្វើអង្កេតនៅក្នុងដំណាក់កាលបន្ថែមនេះ គឺដោយសារតែបញ្ហាភ្លៀងធ្លាក់និងការធ្វើដំណើរលំបាក សម្រាប់ក្រុមអ្នកអង្កេត ជាពិសេសនៅតាមតំបន់ជួរភ្នំ។

មុនរយៈពេល១២ខែនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ (មានន័យថាពីថ្ងៃទី០១ ខែមេសាឆ្នាំ២០១២ ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៣) ជាទូទៅត្រូវបានប្រើប្រាស់ជាសេចក្ដីយោងសម្រាប់រយៈពេលដែលភាគច្រើននៃទម្រង់ F, C, D និង E ក្នុងជំរឿនជាតិកសិកម្មនៅកម្ពុជាឆ្នាំ ២០១៣។ ទោះជាយ៉ាងណាក៏ដោយ សេចក្ដីយោងតាមរយៈពេលសម្រាប់ធាតុមួយចំនួននេះ គឺខុសគ្នាពីមួយទៅមួយដែលបានបញ្ជាក់ខាងលើ ដូចដែលបានបង្ហាញពីការបែងចែកទិន្នន័យដទៃទៀត និងក្នុងកម្រងសំណួរសំណួរនីមួយៗ។

## ការជ្រើសរើសសំណាកគំរូ

នៅក្នុងដំណាក់កាលស្នូល ការចុះបញ្ជី និងការប្រមូលព័ត៌មានមូលដ្ឋានអំពីសកម្មភាពកសិកម្ម និងវារីវប្បកម្មត្រូវបានអនុវត្តគ្រប់គ្រួសារនៃភូមិទាំងអស់នៅក្នុងប្រទេស។នៅក្នុងដំណាក់កាលបន្ថែមនៃជាការស្ទង់មតិនេះត្រូវបានធ្វើឡើងទាំងពីរ នៅផ្នែកគ្រួសារ និងមិនមែនគ្រួសារ។ អង្គភាពស្ថិតិទាំងនេះត្រូវបានចាត់ចំណាត់ថ្នាក់ជា គ្រួសារធ្វើកសិកម្មនៅក្នុងផ្នែកគ្រួសារ និងអង្គភាពកសិកម្មខ្នាតធំដែលបានប្រតិបត្តិការ ដោយសាជីវកម្ម សហករណ៍ រាជរដ្ឋាភិបាល និងផ្នែកឯកជននៅក្នុងផ្នែកមិនមែនគ្រួសារ។

បញ្ជីភូមិដែលបានចងក្រងសម្រាប់ជំរឿនប្រជាជនឆ្នាំ២០០៨ ត្រូវបានគេប្រើប្រាស់ជាឯកសារមូលដ្ឋានសម្រាប់ការងារចុះបញ្ជីនៃជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣នៅក្នុងដំណាក់កាលស្នូល។ បន្ទាប់មកនៅក្នុងបញ្ជីនៃគ្រួសារកសិកម្មបានរៀបចំចេញពីទិន្នន័យដែលប្រមូលបាននៅក្នុងទម្រង់ B នៅក្នុងដំណាក់កាលស្នូលត្រូវបានប្រើប្រាស់ជាបញ្ជីសំណាកគំរូនៅក្នុងដំណាក់កាលបំពេញបន្ថែម ។ គ្រួសារកសិកម្ម “ខ្នាតធំ” បានត្រូវកំណត់អត្តសញ្ញាណនៅក្នុងដំណាក់កាលនេះពីក្នុងបញ្ជី។ បន្ថែមពីនេះទៀត បញ្ជីកាន់កាប់កសិកម្ម “ពិសេស” និងការកាន់កាប់កសិកម្ម “គតិយុត្តិ” ត្រូវបានរៀបចំនៅកម្រិតរដ្ឋបាល និងបញ្ជីនេះត្រូវបានរាប់បញ្ចូលក្នុងការកាន់កាប់កសិកម្ម “ខ្នាតធំ”បានកំណត់អត្តសញ្ញាណនៅក្នុងការអង្កេតនេះ។

## និតិវិធីអង្កេត

ទិន្នន័យទាំងអស់នៅក្នុងជំរឿនជាតិកសិកម្មនៅកម្ពុជាឆ្នាំ២០១៣ ត្រូវបានប្រមូលតាមវិធីសាស្ត្រ ឃើញ រាប់ (de facto) ដោយមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យដែលបានបណ្ដុះបណ្ដាលហើយធ្វើការសម្ភាសន៍ ដោយផ្ទាល់ទៅលើសមាជិកគ្រួសារកសិដ្ឋានដែលត្រូវសម្ភាសន៍ ។

អ្នកតបសម្ភាសន៍គឺជាសមាជិកគ្រួសារពេញវ័យ (អាយុ 18 ឆ្នាំឡើងទៅ) នៃគ្រួសារនិងយល់ដឹងនៃសកម្មភាពការកាន់កាប់កសិកម្ម។ អ្នកតបសម្ភាសន៍ដែលមានលក្ខណៈគ្រប់គ្រាន់បំផុតគឺម្ចាស់កសិដ្ឋាន។ ទោះបីយ៉ាងណាក៏ដោយ ការអវត្តមានរបស់គាត់ ប្តីប្រពន្ធ កូនប្រុស ឬកូនស្រីដែលមានអាយុពី ១៨ឆ្នាំឡើងទៅដែលអាចផ្តល់ចម្លើយបាន។ គ្មានសមាជិកគ្រួសារណាដែលមានអាយុក្រោម ១៨ ឆ្នាំចុះ ឬក៏ អ្នកជិតខាង ឬក៏គ្រួសារដទៃទៀតដែលបានសម្ភាស៍ ឬសួរនាំសម្រាប់ព័ត៌មាននៃគ្រួសារដែលបានអង្កេតនោះទេ។

ទិន្នន័យនៅក្នុងជំរឿន និងអង្កេតត្រូវបានប្រមូល ដោយប្រើប្រាស់កម្រងសំណួរដែលមានជារចនាសម្ព័ន្ធស្តង់ដារ ដែលបានណែនាំដោយ*សៀវភៅណែនាំមន្ត្រីសម្ភាសន៍* ដែលបានផ្តល់នូវទស្សនៈទានលម្អិត និយមន័យ និងនីតិវិធីដែលត្រូវបានអនុវត្តសម្រាប់ការប្រមូលប្រភេទទិន្នន័យនីមួយៗ។ សេចក្តីព្រាងកម្រងសំណួរ និងសៀវភៅណែនាំត្រូវបានរៀបចំឡើងដោយផ្អែកលើអនុសាសន៍ដែលទទួលបានពីសិក្ខាសាលាស្តីពីអ្នកប្រើប្រាស់-អ្នកផលិតទិន្នន័យ។ កម្រងសំណួរជំរឿននិងសៀវភៅណែនាំត្រូវបានកែលម្អឡើងវិញ និងបានបញ្ចប់ដោយផ្អែកលើលទ្ធផលនៃការធ្វើជំរឿន សាកល្បងជាមួយនិងបទពិសោធ ដែលទទួលបានក្នុងអំឡុងពេលអនុវត្ត។ *សៀវភៅណែនាំមន្ត្រីសម្ភាសន៍* គឺត្រូវបានបន្ថែមដោយការត្រួតពិនិត្យជាសំណុំអំពីភាពស៊ីគ្នានៃទិន្នន័យ ដែលបានអនុវត្តនៅតាមមូលដ្ឋាន ក្នុងដំណាក់កាលការបញ្ចូលទិន្នន័យ និងការកែច្នៃទិន្នន័យឲ្យបានត្រឹមត្រូវនៅក្នុងដំណាក់កាលបន្តបន្ទាប់ទៀត ។

## ***ផែនការផ្សព្វផ្សាយ***

មុនពេលការចុះប្រមូលទិន្នន័យបានចាប់ផ្តើម ការឃោសនាផ្សព្វផ្សាយជំរឿនត្រូវបានធ្វើឡើងដើម្បីទទួលបានការគាំទ្រ និងកិច្ចសហការពីគ្រប់ក្រុមគ្រួសារទាំងអស់នៅទូទាំងប្រទេសដែលបានចូលរួមនៅក្នុងសកម្មភាពកសិកម្ម និងមិនបានចូលរួមការងារកសិកម្ម។ ប្រធានភូមិត្រូវបានចូលរួមដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅក្នុងភូមិ។ យុទ្ធនាការឃោសនាបង្កើនការយល់ដឹងត្រូវបានធ្វើតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាដូចជាទូរទស្សន៍និងវិទ្យុ និងការប្រើប្រាស់បដារ និងប័ណ្ណប្រកាស ផ្ទាំងរូបភាព ការបោះពុម្ពនៅលើថង់ អាវយឺត និងមួកត្រូវបានប្រើប្រាស់ក្នុងការធ្វើជំរឿននិងការអង្កេត។ លិខិតប័ណ្ណ និងអត្ថបទនិពន្ធខ្លីៗ ត្រូវបានរៀបចំដោយមានសេចក្តីពន្យល់ដូចជា÷ “តើជំរឿនកសិកម្មនៅកម្ពុជា គឺជាអ្វី?” “តើស្ថាប័នណាមួយដែលទទួលខុសត្រូវធ្វើជំរឿនកសិកម្មនៅក្នុងប្រទេសកម្ពុជា ?” តើជំរឿនកសិកម្មនៅក្នុងប្រទេសកម្ពុជាមានសារៈសំខាន់ដូចម្តេចដែរ ? “ឯកសារជំរឿនកសិកម្មទាំងនេះគឺអាចរកបាននៅ លើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ។

## ***ការរៀបចំជ្រើសរើសសំណាកគំរូ និងការចុះប្រមូលទិន្នន័យ***

ជាទូទៅការជ្រើសរើសសំណាកចាត់ចំណាត់ថ្នាក់ជាពីរដំណាក់កាល ដែលត្រូវបានសម្រាប់ការធ្វើអង្កេត ។ ដំណាក់កាលទីមួយ (FSU) ការជ្រើសរើសភូមិនៅក្នុងឃុំ ។ ដំណាក់កាលទីពីរ (SSU) គឺជ្រើសរើសគ្រួសារដែលកាន់កាប់កសិកម្មខ្នាតតូចនៅក្នុងភូមិជ្រើសរើសសំណាកគំរូ។ ក្នុងដំណាក់កាលទីមួយ គឺជ្រើសរើសឃុំនីមួយៗតាមប្រព័ន្ធសមាមាត្រប្រូបាប៊ីលីទៅនឹងទំហំ - ទំហំចំនួនគ្រួសារកាន់កាប់កសិកម្ម ។ ដំណាក់កាលទីពីរ គឺជ្រើសរើសដោយចៃដន្យពីចំណុច ចាប់ផ្តើមដែលមានលក្ខណៈជាប្រព័ន្ធ ។ ការជ្រើសរើសសំណាកគំរូដំណាក់កាលទីមួយ គឺត្រូវបានអនុវត្តនៅកម្រិតឃុំ ដោយជ្រើសរើសអត្រាសំណាកគំរូ ចំនួន ៥០ភាគរយ តាមវិធីសាស្ត្រស្ថិតិនៅក្នុងកម្រិតនេះ។ គ្រួសារដែល

កាន់កាប់កសិកម្មខ្នាតតូចគឺត្រូវបានជ្រើសរើសអត្រាសំណាកគំរូ ៥ ភាគរយ រៀងរាល់គ្រប់ ២០ គ្រួសារដែលកាន់កាប់កសិកម្មខ្នាតតូច គ្រួសារ ដែលមានដីកសិកម្មខ្នាតតូចមួយនៃការជ្រើសរើសជាគ្រួសារគំរូ (សូមមើលសេចក្តីលម្អិតនៃការរចនាគំរូនិងនីតិវិធីការប៉ាន់ស្មានក្នុងឧបសម្ព័ន្ធទី១) ។ ទិន្នន័យទាំងមូលនៅក្នុងដំណាក់កាលស្នូលនៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ ត្រូវបានគេប្រមូលបានពី ២,៦ លានគ្រួសារ លើភូមិចំនួន ១៤.០៧៣ ឃុំ ១.៦២១ ស្រុក ១៩៤ និងខេត្ត២៤ ដោយមន្ត្រីសម្ភាសន៍ដែលទទួលបានការបណ្តុះបណ្តាល ដោយបានជ្រើសរើសចេញពីសិស្ស និងនិស្សិតបញ្ចប់ការសិក្សា និងភ្នាក់ងារសុខភាពសត្វភូមិលើមូលដ្ឋាននៃការធ្វើតេស្តជម្រុះ។ បន្តបន្ទាប់ទៀត ទិន្នន័យនេះត្រូវបានអនុញ្ញាតឲ្យបំបែកសម្រាប់ខេត្តត្បូងឃ្មុំដែលជាខេត្តបង្កើតថ្មីមានលេខរៀងទី ២៥ ។

ការចុះប្រតិបត្តិការតាមមូលដ្ឋាន រួមមានទាំងការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ ការប្រមូលទិន្នន័យនិងត្រួតពិនិត្យ ។ បុគ្គលិកថ្នាក់កណ្តាល និង ថ្នាក់មូលដ្ឋានដែលមកពី វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជួលអ្នកធ្វើការប្រមូលទិន្នន័យចំនួន ៤.០០០នាក់ ដែលបានបណ្តុះបណ្តាលមុនពួកគេធ្វើការប្រមូលទិន្នន័យនិងការត្រួតពិនិត្យ។ ចាប់តាំងការធ្វើជំរឿនកសិកម្មជាតិកម្ពុជា ត្រូវបានបង្កើតជាពីរដំណាក់កាល ដោយធ្វើការបណ្តុះបណ្តាលសម្រាប់ដំណាក់កាលនីមួយៗ។ មានពីរកម្រិតដែលថ្មីនៃការបណ្តុះបណ្តាលទាំងពីរដំណាក់កាលបឋម និងដំណាក់កាលបំពេញបន្ថែមដែលត្រូវបានធ្វើឡើងដោយឡែកពីគ្នា។ ទាំងពីរកម្រិតនៃការបណ្តុះបណ្តាលសម្រាប់ដំណាក់កាលនីមួយៗគឺ (ក)បណ្តុះបណ្តាលគ្រូបង្គោលដែលមានមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅថ្នាក់កណ្តាលជាប្រធាន និងតំណាងខេត្ត (ខ) បណ្តុះបណ្តាមន្ត្រីសម្ភាស៍ និង ក្រុមមន្ត្រីត្រួតពិនិត្យ ។ មន្ត្រីមូលដ្ឋានទាំងអស់នោះរួមបញ្ចូលទាំងមន្ត្រីត្រួតពិនិត្យនៅគ្រប់កម្រិតដែលត្រូវបានបណ្តុះបណ្តាលបន្ថែមយ៉ាងល្អលើមូលដ្ឋានគ្រឹះ និយមន័យ និងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ។

ខណៈដែលទិន្នន័យនៅក្នុងដំណាក់សំខាន់នៃជំរឿនកសិកម្មជាតិកម្ពុជាឆ្នាំ២០១៣ ត្រូវបានប្រមូលលើគ្រួសារចំនួន ២,៦ លានគ្រួសារ ក្នុងដំណាក់កាលបន្ថែម -តម្រូវការពាក់ព័ន្ធជំនាញបន្ថែម និង ការបណ្តុះបណ្តាល-បុគ្គលិកពាក់ព័ន្ធជ្រើសរើសពី និស្សិត និងនិស្សិតបញ្ចប់ការសិក្សា និងយុវជនដែលមានការអប់រំក្នុងស្រុកនៃអ្នកធ្វើការខាងបសុសត្វស្រុក។ នេះជាកម្រងសំណួរភូមិ (ទម្រង់-G) ត្រូវបានគេគ្រប់គ្រង ដើម្បីឱ្យប្រធានភូមិនៅក្នុងភូមិទាំងអស់ក្នុងកំឡុងពេលធ្វើជំរឿននេះ។

ភាពត្រឹមត្រូវនៃលទ្ធផលចុងក្រោយនៃជំរឿនកសិកម្មជាតិកម្ពុជា អាស្រ័យលើគុណភាពល្អនៃការប្រមូលទិន្នន័យពីគ្រួសារដែលត្រូវបានរៀបចំជាបញ្ជី។ បើទោះបីជាយ៉ាងណាការបណ្តុះបណ្តាលត្រូវបានធ្វើបានយ៉ាងល្អ និងដំណើរការទិន្នន័យត្រូវបានបង្កើតដោយមានប្រសិទ្ធិភាព ប្រសិនបើការគ្រប់គ្រងគុណភាពដែលត្រូវបានអនុវត្តក្នុងអំឡុងពេលប្រមូលទិន្នន័យបានគ្រប់គ្រាន់ ហើយទិន្នន័យចុងក្រោយនឹងមានភាពមិនល្អ។ ការត្រួតពិនិត្យ និង បណ្តាញទំនាក់ទំនងនៅក្នុងជំរឿនកសិកម្មជាតិកម្ពុជាមានច្រើនកម្រិតដូចបានរៀបរាប់លម្អិតនៅក្នុង សៀវភៅអ្នកគ្រប់គ្រង ។ ឋានានុក្រម នៃការត្រួតពិនិត្យ និង ទំនាក់ទំនងរួមជាមួយនឹងគោលការណ៍ណែនាំទូលំទូលាយមួយដាច់ដោយឡែកនេះត្រូវបានរៀបចំសម្រាប់ប្រធានសាខាខេត្តជំរឿន (PCSs) និងអ្នកគ្រប់គ្រងក្រុម (TSs) ផ្នែកសំខាន់ៗនៃសកម្មភាពផ្សេងគ្នា និងនីតិវិធី

នៃការត្រួតពិនិត្យគុណភាព ដោយពិនិត្យតាមដានឱ្យបានត្រឹមត្រូវពីការរីកចម្រើននៃការចុះបញ្ជី និងការរៀបចំនៃជំរឿនកសិកម្មជាតិកម្ពុជា និងសម្រាប់ការរកឃើញដំបូងនៃបញ្ហានីមួយៗនៃការប្រមូលទិន្នន័យ។

## ការកែច្នៃទិន្នន័យ

នៅពេលដែលទិន្នន័យទាំងមូលសម្រាប់ភូមិមួយដែលត្រូវបានប្រមូលដោយមន្ត្រីសម្ភាសន៍ ពួកគេបានដាក់ជូនកម្រងសំណួរដែលបានបំពេញតារាងសំណួរនោះទៅក្រុមមន្ត្រីត្រួតពិនិត្យតាមលំដាប់ អនុវត្តការត្រួតពិនិត្យលម្អិត និងបានផ្ញើទៅកាន់ស្នាក់ការកណ្តាលខេត្តនៅរៀងរាល់ចុងសប្តាហ៍ ។ មន្ត្រីដែលពាក់ព័ន្ធនៅស្នាក់ការកណ្តាលខេត្តបានត្រួតពិនិត្យតារាងបញ្ជីសំណួរដែលបំពេញហើយម្តងទៀតនិងចុហក្រោយបញ្ជូនទម្រង់ទាំងអស់ទៅស្នាក់ការ កណ្តាលថ្នាក់ជាតិសម្រាប់ការបញ្ចូលទិន្នន័យនិងការបញ្ជាក់ឲ្យត្រឹមត្រូវ។

នៅស្នាក់ការកណ្តាលជំរឿនបញ្ជីសំណួរដែលបានបំពេញដែលបានទទួលលើកដំបូងនៅក្នុងអង្គភាពគ្រប់គ្រងឯកសារដែលជាកន្លែងដែលមានការត្រួតពិនិត្យជាអប្បរមាមួយដែលត្រូវបានធ្វើឡើងនៅក្នុងលក្ខណៈនៃការគ្របដណ្តប់ឱ្យពេញលេញនៃកម្រងសំណួរមុនពេលបញ្ជូនទៅកន្លែងបញ្ចូលទិន្នន័យ និងកែច្នៃបផ្សេងៗ។

ការកែច្នៃទិន្នន័យនិងការគណនានេះត្រូវបានធ្វើដោយប្រើប្រាស់កម្មវិធីកែច្នៃទិន្នន័យ CSPro 5.0។ ភាពត្រឹមត្រូវនៃទិន្នន័យនេះបានចាប់ផ្តើមពីដំណាក់កាលរៀបចំឯកសារ តាមរយៈការបញ្ចូលទិន្នន័យ និងការច្នៃទិន្នន័យជាបន្តបន្ទាប់នៅក្នុងន័យថា កម្មវិធីបញ្ចូលទិន្នន័យត្រូវបានត្រួតពិនិត្យភាពស៊ីសង្វាក់គ្នាដែលមាននៅក្នុងទិន្នន័យ។ ការត្រួតពិនិត្យគឺបានអនុវត្តតាមការពិនិត្យលំអិតដោយដៃ នេះអមដោយការត្រួតពិនិត្យបន្ថែមទៀត ដោយកូនសៀវភៅនៃការវិភាគ ការពិនិត្យដោយបង្ហាញតាមរយៈការប្រាប់ដោយផ្ទាល់ និងចុងក្រោយការកែតម្រូវដោយកុំព្យូទ័រ។

# ជំពូកទី ២
# ភូមិសាស្ត្រនិងហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាមានព្រំប្រទល់ភាគខាងលិចជាប់ប្រទេសថៃ ខាងជើងជាប់ប្រទេសឡាវ និងភាគខាងកើតជាប់ប្រទេសវៀតណាម ហើយបានចែកសណ្ឋានដីជាបួនធំៗ គឺជាតំបន់វាលទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រជាប់ឈូងសមុទ្រថៃ និងតំបន់ភ្នំនិងខ្ពង់រាបខ្ពស់ៗ។ នៅក្នុងតំបន់ទាំងនេះ មានទីតាំងភូមិសាស្ត្រ និងសណ្ឋានដីច្រើនប្រភេទផ្សេងៗគ្នាដែលជាកត្តាសំខាន់ក្នុងការកំណត់ប្រភេទដំណាំសមស្របដែលអាចដាំដុះនៅក្នុងភូមិនៃប្រទេសកម្ពុជា។ ការទាបជាងកម្រិតខេត្តនិងក្រុងនៅក្នុងប្រទេស ត្រូវបានចែកជាបីអង្គភាពរដ្ឋបាល ក្នុងនោះ អង្គភាពរដ្ឋបាលដែលតូចជាងគេត្រូវបានកំណត់ឈ្មោះថា ភូមិ បន្ទាប់មក ឃុំ និងស្រុក។

ប្រទេសកម្ពុជាមានចំនួន ១៤.០៧៣ ភូមិ ត្រូវបានបែងចែកជា ១.៦៣៣ ឃុំ និងបានផ្តុំទៅជា ១៩៤ ស្រុក/ខណ្ឌ។ មេភូមិសរុបចំនួន ១២,៦០៤នាក់ ត្រូវបានសម្ភាសន៍នៅទូទាំងប្រទេសសម្រាប់ជំរឿនកសិកម្មនៅកម្ពុជា ដែលបានគ្របដណ្តប់គ្រប់ ២៥ រាជធានីខេត្ត ប៉ុន្តែត្រូវបានដកចេញនូវ តំបន់ទីប្រជុំជនមួយចំនួននៃរាជធានីភ្នំពេញ ដោយផ្អែកតាមសណ្ឋានដី និងហេរដ្ឋារចនាសម្ព័ន្ធភូមិ។

## សណ្ឋានដី

តំបន់បឹងទន្លេសាបមានខេត្តចំនួនប្រាំបីរួមមានខេត្ត បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន សៀមរាប ឧត្តរមានជ័យ កំពង់ធំ កំពង់ឆ្នាំង និងពោធិសាត់។ ដោយឡែកខេត្តប៉ៃលិន និងត្តឧត្តរមានជ័យ ជាទីតាំងភូមិសាស្ត្រដែលមានកូនភ្នំ និងខ្ពង់រាប ដែលគ្មានភូមិណាមួយស្ថិតនៅជាប់នឹងតំបន់បឹងនោះទេ។ ទោះយ៉ាងណា ក៏ដោយតាមហេតុផលប្រវត្តិសាស្ត្រ និងរដ្ឋបាលខេត្តទាំងពីរនៅតែត្រូវបានចាត់ទុកថាជាខេត្តដែលស្ថិតនៅជុំវិញតំបន់បឹងទន្លេសាប ដែលពីមុនខេត្តទាំងពីរខាងលើជាផ្នែកមួយនៃខេត្តបាត់ដំបងនិងសៀមរាប។ ប្រមាណ៣០ភាគរយ នៃភូមិនៅក្នុងខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំងស្ថិតនៅជុំវិញបឹងទន្លេសាប។

តំបន់វាលទំនាបមានខេត្តចំនួនប្រាំពីររួមមានខេត្ត កំពង់ចាម កណ្តាល រាជធានីភ្នំពេញ ព្រៃវែង ស្វាយរៀង តាកែវ និងត្បូងឃ្មុំ។

ខេត្តចំនួនប្រាំមួយទៀត ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ខ្ពង់រាបនិងជួរភ្នំដូចជាខេត្ត កំពង់ស្ពឺ ព្រះវិហារ រតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង។ ប្រមាណ ៩០ភាគរយ នៃភូមិនៅក្នុងខេត្តព្រះវិហារ ប៉ៃលិន និងមណ្ឌលគិរី ហើយរវាង ៦០ភាគរយ និង ៨០ភាគរយ នៃភូមិនៅក្នុងខេត្តឧត្តរមានជ័យ និងស្ទឹងត្រែង ជាខេត្តដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាប និងជួរភ្នំ។

តំបន់ឆ្នេរមានខេត្តចំនួនបួនរួមមានខេត្ត កំពត កោះកុង ព្រះសីហនុ និងកែប។ ក្នុងចំណោម ខេត្តទាំងបួននេះ ខេត្តកែបមានភាគរយខ្ពស់ជាងគេ គឺ ៨៤ភាគរយនៃភូមិមានទីតាំងស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ បន្ទាប់មកមាន ប្រមាណជាង ៣៩ភាគរយនៃភូមិនៅក្នុងខេត្តកោះកុង និងមាន ២១ភាគរយនៅក្នុងខេត្តព្រះសីហនុ ស្ថិតនៅតំបន់ឆ្នេរ។ ខេត្តកំពតជាខេត្តដែលមានភាគរយទាបជាងគេនៃភូមិស្ថិតនៅតាមឆ្នេរសមុទ្រ។

## ប្រភេទដី

ស្ទើរតែ ៥០ភាគរយ នៃភូមិនៅក្នុងប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ដែលមានប្រភេទដីខ្សាច់ម៉ត់ និងប្រមាណ ១០ ភាគរយមានទីតាំងស្ថិតនៅក្នុងតំបន់មួយដែលមានប្រភេទដីខ្សាច់គ្រើម។ ប្រភេទដីល្បាយខ្សាច់ដែលមានច្រើនគួ ឱ្យកត់សម្គាល់ជាងគេ គឺនៅបណ្តាខេត្តមួយចំនួនដូចជាខេត្ត ស្វាយរៀង កោះកុង សៀមរាប កំពត ព្រៃវែង ឧត្តរមានជ័យ កំពង់ឆ្នាំង ក្រចេះ ព្រះសីហនុ និងពោធិសាត់។ ដោយសារតែខេត្តកែបជាខេត្តដែលនៅជាប់ឆ្នេរសមុទ្រ ដែលមានទាំងប្រភេទដីខ្សាច់ម៉ត់ រួមជាមួយនិងដីខ្សាច់គ្រើម ត្រូវបានរកឃើញប្រមាណ ៧០ភាគរយនៃភូមិ ស្ថិតនៅក្នុងខេត្តនេះ។ ដូចគ្នានេះដែរ ប្រភេទដីខាងលើដែលមានច្រើនជាង ៥០ភាគរយនៃភូមិ ត្រូវបានរកឃើញនៅក្នុងខេត្តកណ្តាល និងភាគខាងជើងនៃខេត្តកំពង់ស្ពឺ ស្ទឹងត្រែង និងខេត្តព្រះវិហារ។ ដីឥដ្ឋដែលសម្បូរជាតិរ៉ែ គឺជាភស្តុតាងមួយដែលបញ្ជាក់ថា ច្រើនជាង ៥០ភាគរយនៃភូមិនៅក្នុងខេត្ត បាត់ដំបង បន្ទាយមានជ័យ ក្រចេះ កែប ព្រះសីហនុ និងប៉ៃលិន។ នៅក្នុងខេត្តរតនគិរី ប្រភេទដីឥដ្ឋត្រូវបានរកឃើញតិចជាង ១៥ភាគរយនៃភូមិទាំងអស់។ ដីល្បាប់ ដីល្បាយខ្សាច់ ដីឥដ្ឋ ជាភស្តុតាងបញ្ជាក់ថា មានភូមិច្រើនជាង ៥០ភាគរយ នៅក្នុងខេត្ត ស្ទឹងត្រែង ព្រះសីហនុ និងកណ្តាល ក៏ដូចជាខេត្តផ្សេងៗទៀតដែរ។

## តំបន់ដែលងាយរងគ្រោះធម្មជាតិ

ប្រទេសកម្ពុជាគឺជាប្រទេសដែលងាយនឹងមានភ្លៀងធ្លាក់ច្រើន គ្រោះទឹកជំនន់ក្នុងរដូវវស្សា និងគ្រោះរាំងស្ងួតនៅរដូវប្រាំង ដែលមានប្រមាណ ៣៩ភាគរយនៃភូមិនៅក្នុងប្រទេសកម្ពុជា ធ្លាប់បានជួបប្រទះគ្រោះទឹកជំនន់ ហើយប្រមាណ ៣៨ភាគរយជួបប្រទះគ្រោះរាំងស្ងួត និងអសន្តិសុខស្បៀង ដែលអាចនឹងប្រឈមមុខកង្វះស្បៀងអាហារ នៅក្នុងប្រាំឆ្នាំមុនពេលធ្វើជំរឿន។

នៅទូទាំងប្រទេសប្រមាណ ២៦ភាគរយនៃភូមិធ្លាប់បានទទួលរងខ្យល់ព្យុះទីហ្វុង ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ខណៈពេលនោះតំបន់ឆ្នេរនៃខេត្តកែបបង្ហាញតួលេខខ្ពស់ជាងគេ មានប្រមាណ ៨០ភាគរយនៃចំនួនភូមិ បានជួបប្រទះស្ថានភាពបែបនេះ។ ហើយទឹកជំនន់ធ្ងន់ធ្ងរបានប៉ះពាល់ដល់ ៧៥ភាគរយនៃភូមិ នៅក្នុងខេត្តទិសខាងជើងភាគខាងលិចនៃខេត្តបន្ទាយមានជ័យ និងទទួលរងគ្រោះទឹកជំនន់នេះរហូតមកដល់បច្ចុប្បន្ន ជារៀងរាល់ឆ្នាំនៅផ្នែកមួយភាគនៃខេត្តដែលស្ថិតនៅជាប់ព្រំប្រទល់ប្រទេសថៃ។ មានចំនួនខ្ពស់ប្រហែលគ្នានៃភូមិ នៅក្នុងខេត្តកំពង់ធំ គឺ ៧៤ភាគរយ បានទទួលរងគ្រោះទឹកជំនន់ ហើយក្នុងភូមិនៅក្នុងខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តព្រៃវែង មានប្រមាណ ៥០ភាគរយនៃភូមិ ដែលបានជួបប្រទះគ្រោះទឹកជំនន់នៅក្នុងរយៈពេលប្រាំឆ្នាំមុនធ្វើជំរឿន។ យោងតាមទិន្នន័យបានបង្ហាញថា ភូមិនៅក្នុងខេត្តស្ទឹងត្រែងប្រមាណ ២៥ភាគរយ និងខេត្តក្រចេះ ២១ភាគរយ ដែលបានប្រឈមទៅនឹងគ្រោះបាក់ដី។

គ្រោះរាំងស្ងួតនិងអសន្តិសុខស្បៀងដែលជះឥទ្ធិពលដល់ភូមិជាច្រើនក្នុងកំឡុងពេលប្រាំឆ្នាំដូចគ្នានេះដែរ ជាពិសេសភូមិ ដែលទទួលរងគ្រោះរួមមានខេត្ត បាត់ដំបង ៨៨ភាគរយ ប៉ៃលិន ៦២ភាគរយ ឧត្តរមានជ័យ ៦០ភាគរយ ស្វាយរៀង ៥៩ភាគរយ ព្រៃវែង ៥៨ភាគរយ ក្រចេះ ៥៧ភាគរយ និងពោធិសាត់ ៥៦ភាគរយ។

## សកម្មភាពសេដ្ឋកិច្ច

ប្រទេសកម្ពុជាគឺជាប្រទេសមួយនៅតែចាត់ទុកកសិកម្មជាវិស័យអាទិភាព។ ការរីកចម្រើននៃសេដ្ឋកិច្ចត្រូវបានពឹងផ្អែកលើការដាំដុះដំណាំ ការចិញ្ចឹមសត្វ មាន់ទា សត្វសមុទ្រ និងការនេសាទតាមដងទន្លេ ជលផល និងការប្រមូល

ផលិតផលព្រៃឈើ។ នៅតំបន់ដីភ្នំខ្ពស់និងខ្ពង់រាបនៃខេត្តមណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ៥០ ភាគរយនៃចំនួនភូមិ ធ្វើការប្រមូលផលធម្មជាតិពីព្រៃឈើក្នុងស្រុក ។ ប្រមាណជា ៦៦ ភាគរយនៃភូមិនៅក្នុងខេត្តកែប ខេត្តកោះកុង និងខេត្តព្រះសីហនុចូលរួមសកម្មភាពនេសាទសមុទ្រ និងប្រមាណ ៤០ ភាគរយនៃភូមិ នៅខេត្តក្រចេះ ខេត្តសៀមរាប ខេត្តកោះកុង និងខេត្តកំពង់ធំ បានរួមចំណែកនៅក្នុងការធ្វើវារីវប្បកម្មដែលជាទម្រង់ថ្មីមួយនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់ទាំងនោះ។ ប្រជាជនសកម្មសេដ្ឋកិច្ចនៅក្នុងភូមិ ក៏បានធ្វើការនៅក្នុងវិស័យឧស្សាហកម្មដទៃទៀត និងការងារក្នុងតំបន់ ដើម្បីរកបានប្រាក់ចំណូលបន្ថែមទៀតនៅពេលដែលចាំបាច់ ជាពិសេសនៅក្នុងតំបន់ជុំវិញរាជធានីភ្នំពេញ ដែលមានអ្នកភូមិចំនួន ៤០ ភាគរយ មានចំណូលពីការងារច្រើនជាងមួយ និងខេត្តកែបដែលមានភូមិច្រើនជាង ៦០ ភាគរយក៏មានចំណូលបន្ថែមពីការឆ្លៀតធ្វើការងារនៅពេលវេលាចាំបាច់ណាមួយដែរ។

## ប្រព័ន្ធដំណាំ

ប្រមាណ ៥០ភាគរយនៃភូមិទាំងអស់នៅទូទាំងប្រទេសកម្ពុជា ការដាំដំណាំបានតែមួយដងក្នុងមួយឆ្នាំ ហើយជាតួលេខបានកើនឡើងរហូតដល់ ៨០ភាគរយភូមិនៅក្នុងតំបន់ ខេត្តឧត្តរមានជ័យ ត្បូងឃ្មុំ និងរាជធានីភ្នំពេញ។ តាមបណ្តាខេត្តដែលជាកន្លែងអាចដាំដំណាំបានពីរដងក្នុងមួយឆ្នាំរួមមានខេត្ត ប៉ៃលិន កែប តាកែវ កំពង់ចាម កំពត ព្រៃវែង កណ្តាល ពោធិសាត់ បាត់ដំបង និងកំពង់ធំ ដែលបានប្រមាណ ៩០ភាគរយនៃភូមិជារៀងរាល់ឆ្នាំ។

## គ្រឿងយន្តកសិកម្ម ប្រព័ន្ធធារាសាស្ត្រកែច្នៃ និងហេដ្ឋារចនាសម្ព័ន្ធជនបទ

លទ្ធភាពរកបាននៃឧបករណ៍កសិកម្មការកែច្នៃនិងកន្លែងជាផ្នែកសំខាន់មួយ នៃវដ្តផលិតកម្មសម្រាប់គ្រួសារនៅជនបទជាពិសេសជនក្រីក្រពឹងផ្អែកលើវិស័យកសិកម្មជលផល និងផលិតផលព្រៃឈើ។ ហើយកសិករនិងអ្នកច្រូតឬអ្នកបោកបែន។ល។ ជាទូទៅកសិករទាំងនោះ ភាគច្រើនបំផុតបានប្រើប្រាស់ឧបករណ៍ សម្រាប់គ្រួសារនៅជនបទនាពេលបច្ចុប្បន្នរោងម៉ាស៊ីនកិនស្រូវ គឺជាគ្រឿងប្រដាប់ប្រដារជួយសម្រួលដល់ការប្រើប្រាស់សំខាន់បំផុតក្នុងគ្រួសាររបស់ពួកគេផងដែរ។ នៅចន្លោះរវាង ៦០ និង ៨០ ភាគរយនៃភូមិបានរាយការណ៍ថា ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនច្រូតស្រូវ និងរោងម៉ាស៊ីនកិនស្រូវ ដែលជាធាតុសំខាន់បំផុត នៅក្នុងការកែច្នៃនៃផលិតផលកសិកម្ម។ ទោះយ៉ាងណាក៏ដោយត្រូវបានគេរកឃើញថា មានម៉ាស៊ីនកិនស្រូវច្រើនជាងម៉ាស៊ីនបោក និងម៉ាស៊ីនច្រូត ដែលអាចប្រើបានប្រមាណ ៨០ ភាគរយនៃភូមិ។

ទំហំនៃប្រព័ន្ធធារាសាស្ត្របានផ្តល់ទឹកក្នុងការធ្វើកសិកម្ម ហើយផ្សេងទៀតស្រោចស្រពដោយភ្លៀងសម្រាប់ជំរុញផលិតកម្មដំណាំកសិកម្ម ឬវាលស្មៅមាននៅត្រឹមតែ ២០ភាគរយនៃភូមិនៅទូទាំងប្រទេស និងភូមិមួយចំនួន នៅក្នុងតំបន់ដាច់ស្រយាលនៃខេត្ត ប៉ៃលិន ព្រះវិហារ រតនគិរី និងស្ទឹងត្រែង មិនមានប្រព័ន្ធស្រោចស្រពនោះឡើយ។ នៅថ្នាក់មូលដ្ឋានភាគច្រើន ប្រព័ន្ធធារាសាស្ត្រជាដំណើរការបានផ្លាស់ប្តូរពីប្រភពមួយសម្រាប់ការដាំដំណាំកសិកម្មផងដែរ។ ប្រភពទឹកទាំងនោះ ធម្មតាជាប្រភពចែកចាយទឹកក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធដូចជា ប្រឡាយបូមទឹក ប្រព័ន្ធទឹកឬប្រព័ន្ធបង្ហូរទឹកធ្វើមូលដ្ឋានីយកម្មបាន។ ការរួមបញ្ចូលទឹកដោយធ្វើហត្ថកម្មដំណាំ ដែលប្រើធុង កំប៉ុងទឹក ឬឧបករណ៍ផ្សេងទៀត។

ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទដូចជា ប្រព័ន្ធប្រឡាយទឹក ការដឹកជញ្ជូន ការអប់រំ ការទំនាក់ទំនង និងគ្រឹះស្ថានសុខាភិបាល គឺជាតម្រូវការដោយផ្ទាល់និងដោយប្រយោល ដោយសហគមន៍កសិកម្ម ដើម្បីអនុវត្តសកម្មភាពរបស់ពួក

គេ។ ជាទូទៅម៉ូតូ គឺជាមធ្យោបាយនៃការដឹកជញ្ជូននៅតាមតំបន់ជនបទ។ ម៉ូតូសន្ទោងត្រូវបានស្គាល់ថាជា "តុកតុក" ហើយម៉ូតូសណ្តោងឈើត្រូវបានស្គាល់នៅក្នុងស្រុកជា "រឺម៉ក" តែងតែមានវត្តមាននៅក្នុងប្រមាណ ២៥ភាគរយនៃភូមិនានា ហើយក៏ជាមធ្យោបាយដ៏សំខាន់នៃការដឹកជញ្ជូនផលិតផលកសិកម្មពីកសិដ្ឋានឆ្ពោះទៅកាន់ទីផ្សារ អ្នកប្រើប្រាស់ និងនៅកន្លែងផ្សេង។ ម៉ូតូសន្ទោងត្រូវបានរកឃើញជាទូទៅច្រើនបំផុត នៅក្នុងតំបន់ជុំវិញរាជធានីភ្នំពេញ ៧៩ភាគរយនៃភូមិខេត្តកែបមានប្រមាណ ៦១ភាគរយ និងខេត្តកណ្តាល ៥៨ភាគរយ។ រឺម៉កមានវត្តមានយ៉ាងទូលំទូលាយនៅក្នុងភូមិនៅខេត្ត កែបមាន ៧៨ភាគរយ កំពតមាន ៤៦ភាគរយ រាជធានីភ្នំពេញមាន ៤៦ភាគរយ កណ្តាលមាន ៤៣ភាគរយ និងព្រះសីហនុមាន ៤៣ភាគរយ។ ជាទូទៅខេត្តដែលស្ថិតនៅតាមឆ្នេរសមុទ្រនិងតាមដងទន្លេ មានទូកគឺជាមធ្យោបាយនៃការដឹកជញ្ជូនភូមិទៅភូមិមួយទៀត ប្រមាណ ៨០ភាគរយ នៅក្នុងខេត្តខេត្តកោះកុង ដែលប្រើប្រាស់ទូកមធ្យោបាយដឹកជញ្ជូនហើយខេត្តមួយចំនួនដូចជា ក្រចេះមាន ៥៩ភាគរយ ព្រះសីហនុមាន ៥៩ភាគរយ ស្ទឹងត្រែងមាន ៥៨ភាគរយ និងកែបមានតែ ៥០ភាគរយប៉ុណ្ណោះ។ ហើយក្រៅពីមធ្យោបាយដឹកជញ្ជូនខាងលើការរួមមានរថយន្ត (ជាកម្មសិទ្ធិឬជួល)។

## ការទំនាក់ទំនង

ទូរស័ព្ទដៃត្រូវបានគេប្រើប្រាស់ប្រមាណ ៧៧ភាគរយនៃភូមិនៅទូទាំងប្រទេស។ យ៉ាងហោចណាស់មានចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃត្រូវបានរកឃើញនៅក្នុងខេត្តបាត់ដំបង មានចំនួនប្រមាណ ៣៨ភាគរយនៃភូមិពីការប្រើប្រាស់ទូរស័ព្ទដៃ។ បណ្តាញទូរស័ព្ទអចល័តត្រូវបានគេប្រើជាមធ្យោបាយនៃការទំនាក់ទំនង ប្រមាណជាង ១៣ភាគរយនៃភូមិនៅទូទាំងប្រទេស។ របាយករណ៍បានបង្ហាញថា ភូមិនានាក្នុងខេត្តកំពង់ចាមនិងខេត្តត្បូងឃ្មុំ អត្រានៃការប្រើប្រាស់បណ្តាញទូរស័ព្ទអចល័តខ្ពស់បំផុត ខណៈពេលដែលខេត្តក្រចេះមានការប្រើប្រាស់តិចតួច ស្មើនឹង ២ភាគរយនៃទូរស័ព្ទក្នុងភូមិ ជាលក្ខណៈប្រពៃណី។ ចំពោះបណ្តាញនិងការប្រើប្រាស់អ៊ីនធឺណិតនៅក្នុងភូមិមានចំនួន ៥ ភាគរយប៉ុណ្ណោះនៅទូទាំងប្រទេស ហើយការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតនៅចន្លោះពី ១១ ភាគរយ ទៅ ១៩ ភាគរយនៃភូមិនៅក្នុងដូចជាខេត្តកណ្តាល មណ្ឌលគីរី ប៉ៃលិន និងកែប។ ហើយប្រមាណតែ ២ ភាគរយនៃភូមិនៅទូទាំងប្រទេសកម្ពុជា ដែលបានប្រើសេវាកម្មប្រៃសណីយ៍ជាមធ្យោបាយនៃការទំនាក់ទំនង។

## សុខភាពនិងអប់រំបរិក្ខារ

ភូមិមួយចំនួនដែលមានមណ្ឌលសុខភាពបានបង្ហាញថា កង្វះខាតសម្ភារៈបរិក្ខារពេទ្យនៅទូទាំងប្រទេស និងជាចំណុចចាប់អារម្មណ៍ក្នុងតំបន់មួយចំនួនរបស់ពួកគេ។ យោងលើចំនួនសរុបនៃភូមិដែលបានឆ្លើយតប ការរាយការណ៍ថា ១៣ភាគរយ ជាមណ្ឌលសុខភាព ៨ ភាគរយ ជាគ្លីនិកសុខភាព និងប្រមាណ ៣ ភាគរយជាមន្ទីរពេទ្យ។ ក្នុងភូមិនានានៃខេត្តដូចជា កែប មណ្ឌលគីរី និងនៅក្នុងតំបន់ជុំវិញរាជធានីភ្នំពេញមានចំនួនសមាមាត្រខ្ពស់បំផុត ដែលបង្ហាញពីវត្តមានរបស់មណ្ឌលសុខភាពនេះ។ គ្រឹះស្ថានអប់រំសុខភាពត្រូវបានគេឃើញមានវត្តមានប្រមាណ ៦៧ ភាគរយនៃភូមិទូទាំងប្រទេស។

*ក្រាហ្វិក២.១ ភូមិដែលរាយការណ៍ថាមានប្រភេទនៃសាលារៀន និងស្ថាប័នអប់រំផ្សេងទៀត*




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

មានប្រភេទសាលារៀនខុសៗគ្នាៗចំនួន 9.338 ស្ថិតនៅក្នុងភូមិចំនួន 9.506 នៅទូទាំងប្រទេស ។ ក្នុងចំណោមសាលារៀនទាំង 9.338 របស់រាជរដ្ឋាភិបាលនៅទូទាំងប្រទេសនោះ 6.583 ជាសាលារៀនបឋមសិក្សា (ស្ថិតនៅក្នុង 70% នៃភូមិទាំងអស់) 1.601 ជាសាលារៀនកម្រិតកណ្តាល (ស្ថិតនៅក្នុង 17%នៃភូមិទាំងអស់) 445 ជាសាលារៀនថ្នាក់កម្រិតខ្ពស់ (ស្ថិតនៅក្នុង 5% នៃភូមិទាំងអស់) ហើយ 118 ជាសាលារៀនកម្រិតវិទ្យាល័យ ឬ សាកលវិទ្យាល័យស្ថិតនៅក្នុង 1% នៃភូមិទាំងអស់ ។ លើសពីនោះក៏មានប្រភេទសាលារៀនផ្សេងៗទៀតចំនួន 626 ផងដែរ ដែលស្ថិតនៅក្នុងទូទាំងប្រទេស ។

នៅតាមបណ្តាខេត្ត ខេត្តបាត់ដំបងមានចំនួនសាលាបឋមសិក្សាច្រើនជាងគេបំផុតគឺ 785 សាលារៀន បន្ទាប់មកខេត្តព្រៃវែងមានចំនួន 560 សាលារៀន ខេត្តកំពង់ធំ 501 សាលារៀន ។ រីឯខេត្តផ្សេងៗទៀត មានសាលាកម្រិតបឋមសិក្សាចំនួន ចន្លោះពី 100 សាលារៀនទៅតិចជាង 500 សាលារៀន។ បណ្តាខេត្តដែលមានប្រជាជនតិចដូចជាខេត្តកោះកុង ព្រះសីហនុ មណ្ឌលគិរី ប៉ៃលិន និងកែប មានសាលាបឋមសិក្សាតិចជាង 100 សាលា ។ មានសាលាកម្រិតថ្នាក់កណ្តាលច្រើនជាង 100 សាលារៀនស្ថិតនៅតាមបណ្តាខេត្តដូចជា បាត់ដំបង កំពង់ចាម កំពង់ធំ កំពតកណ្តាល ព្រៃវែង និង សៀមរាប ហើយមានសាលារៀនថ្នាក់វិទ្យាល័យ ចំនួនតិចតួចស្ថិតនៅតាមបណ្តាខេត្តដែលមានប្រជាជនច្រើនដូចជា ខេត្តកំពង់ចាម កណ្តាល និងសៀមរាប ។ សាលារៀនថ្នាក់វិទ្យាល័យ និងសាកលវិទ្យាល័យព្រមទាំងកម្រិតខ្ពស់ជាង និងមជ្ឈមណ្ឌលអប់រំដទៃទៀត ភាគច្រើនស្ថិតនៅក្នុងតំបន់ទីប្រជុំជន ដូចជារាជធានីភ្នំពេញនិងខេត្តសៀមរាប។

## ប្រភពទឹក

ទឹកដែលប្រជាជនអាចទទួលទានបាន មកពីប្រភពទឹកធម្មជាតិនិងអ្នកផលិតទឹកបរិសុទ្ធ និងកែច្នៃទឹកស្អាត។ ប្រភពទឹកធម្មជាតិរួមមាន: បំពង់បង្ហូរទឹកស្អាត បំពង់ឬអណ្តូងទឹក អណ្តូងទឹកការពារ អណ្តូងទឹកមិនមាន

ការការពារ ទឹកបានដោយផ្ទាល់ពី ទន្លេ ស្រះ ព្រែក ស្ទឹង និងទឹកភ្លៀងដែលប្រមូលផ្ដុំនៅក្នុងអាងស្តុកទឹក។ តាមរបាយការណ៍បង្ហាញថាប៉ែតសិបភាគរយនៃភូមិបានប្រើប្រាស់ប្រព័ន្ធទឹកតាមបំពង់ និងអណ្ដូងទឹក ខណៈដែល ៥៥ភាគរយនៃភូមិបានប្រើប្រាស់ប្រព័ន្ធទឹកទន្លេ ស្រះ ព្រែក ស្ទឹង។ ហើយ ៨០ ភាគរយនៃភូមិបានប្រើប្រាស់ទឹកភ្លៀងផងដែរ។ ទឹកបរិសុទ្ធត្រូវបានទិញយកទៅប្រើប្រាស់មានចំនួន ៤៧ភាគរយនៃភូមិទាំងអស់ទូទាំងប្រទេស។

## ការចូលទៅកាន់ផ្លូវជាតិ

ចំនួនភូមិនៅជិតផ្លូវជាតិបំផុតប្រមាណជា ៣៥ភាគរយនៃភូមិទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលបានរាយការណ៍ ហើយចំនួនភូមិដែលមានចម្ងាយពីផ្លូវជាតិបួនគីឡូម៉ែត្រប្រមាណ ៥៣ ភាគរយ។ ក្នុងនោះ ខេត្តចំនួនប្រាំដូចជាខេត្ត ប៉ៃលិន កែប ព្រះសីហនុ កណ្ដាល និងរាជធានីភ្នំពេញ ដែលមានច្រើនជាង ៥០ ភាគរយនៅក្នុងភូមិរបស់ពួកគេដែលអាចធ្វើដំណើរទៅកាន់ផ្លូវជាតិ។ ម្យ៉ាងទៀតចំនួនភូមិដែលមានចម្ងាយ ១០គីឡូម៉ែត្រ ឬច្រើនជាងដែលនៅជិតផ្លូវជាតិបំផុតមានប្រមាណ ៣០ ភាគរយ។ ទីផ្សារដែលអាចរកបានមានចំនួន ១៣ភាគរយ នៃភូមិទូទាំងប្រទេសកម្ពុជា។

*ក្រាហ្វិក២.២ ភាគរយដែលរាយការណ៍ចម្ងាយពីភូមិ ទៅផ្លូវជាតិនៅជិតបំផុត*




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## អង្គការសហគមន៍

អង្គការសមាគមនិងសហករណ៍ដែលតំណាងឱ្យផលប្រយោជន៍ក្នុងតំបន់នៅក្នុងភូមិដូចជាកសិករ អ្នកនេសាទបង្កាត់ពូជសត្វចិញ្ចឹម និងអ្នកចិញ្ចឹមផ្សេងទៀត អង្គការជាស្ត្រីជាច្រើននៅកម្ពុជា ត្រូវបានអ្នកនៅក្នុងភូមិភាគច្រើដែលមាន ៣៤ ភាគរយ នៅក្នុងភូមិបានរាយការណ៍ពីវត្តមានរបស់អង្គការនោះ។ ខេត្តបាត់ដំបងមានចំនួនច្រើនជាងគេបំផុតនៃភូមិ ៩៩ ភាគរយ ដែលបានរាយការណ៍ពីវត្តមាននៃអង្គការស្ត្រី នៅខណៈពេលដែលខេត្តកែបមានតែចំនួន ១១ភាគរយនៃភូមិរាយការណ៍ពីអង្គការដូចគ្នា។ នៅក្នុងខេត្តកែបសមាគមន៍ ដែលតំណាងឱ្យអ្នកនេសាទបច្ចុប្បន្នមានចំនួន ៣៣ភាគរយនៅក្នុងភូមិ។ សហករណ៍ផ្លូវការត្រូវបានរាយការណ៍មានចំនួនតែ៣ភាគរយប៉ុណ្ណោះនៃភូមិនៅទូទាំងប្រទេស។

# ជំពូកទី៣
# ការកាន់កាប់កសិកម្ម និងការកាន់កាប់ដី

ជំរឿនកសិកម្មនៅប្រទេសកម្ពុជាបានឱ្យអត្ថន័យនៃការកាន់កាប់កសិកម្មថា គឺជាអង្គភាពសេដ្ឋកិច្ចស្ថិតក្រោមការគ្រប់គ្រងមួយដែលយ៉ាងហោចណាស់មានមួយក្នុងចំណោមចារិកលក្ខណៈដូចខាងក្រោម÷ មានទំហំផ្ទៃដីយ៉ាងតិច ៣០០ ម៉ែត្រការ៉េ (ឬ ០,០៣ ហិកតា) ដែលបានប្រើប្រាស់ផ្ទៃដីទាំងស្រុង ឬក៏មួយផ្នែកណាមួយសម្រាប់ផលិតកម្មកសិកម្ម និង/ឬ យ៉ាងតិចមានបសុសត្វប្រភេទធំចំនួន២ និង/ឬយ៉ាងតិចមានបសុសត្វប្រភេទតូចចំនួន៣ និង/ឬយ៉ាងតិចមានបសុបក្សីចំនួន ២៥។ ការកាន់កាប់កសិកម្មទាំងនេះ អាចមានតែការដាំដំណាំ ឬអាចមានតែការចិញ្ចឹមបសុសត្វ ឬអាចមានតែការចិញ្ចឹមបសុបក្សី។ លើសពីនេះទៅទៀតក៏អាចមានការកាន់កាប់រួមបញ្ចូលគ្នាទាំងការដាំដំណាំ និងបសុសត្វប្រភេទធំ ឬបសុសត្វប្រភេទតូច ឬបសុបក្សី។ ការកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជាត្រូវបានចែកចេញជាពីរប្រភេទធំៗ គឺការកាន់កាប់កសិកម្មគ្រួសារ និងការកាន់កាបកសិកម្មគតិយុត្តិ។ សហគ្រាសកសិកម្មគតិយុត្តិ គឺជាសហគ្រាសកសិកម្ម ដែលបានគ្រប់គ្រងដោយរដ្ឋ ឬឯកជន មានដូចជា សហករណ៍ ដៃគូសហករណ៍ ស្ថាប័នឯកជន ស្ថាប័នរដ្ឋជាដើម។

## គ្រួសារកាន់កាប់កសិកម្ម

លំនៅដ្ឋានរបស់គ្រួសារដែលកាន់កាប់កសិកម្មត្រូវបានគេដឹងថា មានផ្ទៃដីនៅជុំវិញបរិវេណលំនៅដ្ឋានជាចម្បង។ សកម្មភាពនៃការកាន់កាប់របស់គ្រួសារកសិកម្មនៅកម្ពុជានេះ ត្រូវបានចែកចេញជាបីប្រភេទ÷ ក). សកម្មភាពកសិកម្មនៅក្នុងបរិវេណជុំវិញលំនៅដ្ឋានតែប៉ុណ្ណោះ ខ). សកម្មភាពកសិកម្មនៅលើដីដែលបានចែកដាច់ដោយឡែក ពីបរិវេណជុំវិញលំនៅដ្ឋាន គ). សកម្មភាពកសិកម្មនៅក្នុងបរិវេណជុំវិញលំនៅដ្ឋានរួមជាមួយនឹងការធ្វើកសិកម្មនៅលើដីដាច់ដោយឡែក។

គ្រួសារដែលកាន់កាប់កសិកម្មត្រូវបានរាយការថាមានប្រហែល ១,៨៨លានគ្រួសារ ដែលមានដីកសិកម្មដាច់ដោយឡែកពីបរិវេណជុំវិញលំនៅដ្ឋានរបស់ពួកគាត់ ក្នុងនោះផ្ទៃដីសរុបចំនួន ៣,០៧លានហិកតា ត្រូវបានប្រើប្រាស់សម្រាប់ដាំដំណាំ។ ៩០,៥ភាគរយ នៃ ១,៨៨លានគ្រួសារកាន់កាប់កសិកម្ម ស្មើនឹង ១,៦៨លានការកាន់កាប់បានធ្វើសកម្មភាពកសិកម្មនៅលើដីជុំវិញបរិវេណលំនៅដ្ឋានរបស់ពួកគាត់ផងដែរ ក្នុងទំហំផ្ទៃដីសរុប ០,២លានហិកតា ដូច្នេះការកើនឡើងទំហំផ្ទៃដីសរុបរបស់គ្រួសារកាន់កាប់កសិកម្ម ចំពោះអ្នកកាន់កាប់កសិកម្មមានដីកសិកម្មដាច់ដោយឡែកទាំងនោះ មានផ្ទៃដីរហូតដល់ ៣,២៧លានហិកតា។

លើសពីនេះគ្រួសារកាន់កាប់កសិកម្មចំនួន២៥៣.៤៣៧គ្រួសារ បានធ្វើសកម្មភាពកសិកម្មនៅតែលើដីបរិវេណជុំវិញលំនៅដ្ឋានតែប៉ុណ្ណោះ ផ្ទៃដីដែលបានប្រើប្រាស់កសិកម្មទាំងនេះសរុបមាន ៣៧.៤៣៧ហិកតា។ មានន័យថាគ្រួសារកាន់កាប់កសិកម្មទាំងនេះគ្មាន ដីកសិកម្មដាច់ដោយឡែកទេ។

ដូច្នេះចំនួនគ្រួសារកាន់កាប់កសិកម្ម (មាននិងគ្មានដីកសិកម្មដាច់ដោយឡែក) នៅទូទាំងប្រទេសរួមមានចំនួន ២.១២៩.១៤៩គ្រួសារ ដែលមានទំហំផ្ទៃដីសរុបចំនួន ៣.៣០៤.៧៣៨ ហិកតា។

**តារាង២.១ ចំនួន និងភាគរយនៃគ្រួសារកាន់កាប់កសិកម្ម**

| **រាយឈ្មោះទិន្នន័យ** | **ចំនួន** | **ផ្ទៃដីគិតជាហិកតា** |
|---|---|---|
| គ្រួសារកាន់កាប់កសិកម្មសរុប | 2,129,149 | 3,304,738 |
| ការកាន់កាប់ដែលបានចែកដីកសិកម្ម និងដីបរិវេណជុំវិញលំនៅដ្ឋាន | 1,875,712 | 3,267,302 |
| ការកាន់កាប់ដែលបានធ្វើកសិកម្មនៅតែបរិវេណជុំវិញលំនៅដ្ឋានប៉ុណ្ណោះ | 253,437 | 37,437 |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## ទំហំនៃ ការកាន់កាប់កសិកម្ម

ចំនួន ១.៨៨លាន នៃការកាន់កាប់គ្រួសារ បានរាយការណ៍ថាមានដីកសិកម្មដោយឡែកពីគ្នា និងមានប្រហែល ៤៧ភាគរយ ដែលមានទំហំផ្ទៃដីតិចជាង ១ហិកតា ។ ៤៥ភាគរយមានទំហំផ្ទៃដីចន្លោះពី ១ហិកតា ទៅ ៣,៩៩ហិកតា។ ដូច្នេះ ៩០ភាគរយនៃការកាន់កាប់គ្រួសារកសិកម្មនៅកម្ពុជា មានការចែកដីកសិកម្មដោយឡែក ហើយបានធ្វើសកម្មភាពកសិកម្មរបស់ពួកគេមានផ្ទៃដីតិចជាង ៤ហិកតា។ មានចំនួនភាគរយតិចតួចណាស់ (១,២១ភាគរយ) នៃការកាន់កាប់គ្រួសារកសិកម្មដែលបានរាយការណ៍ថាមានទំហំផ្ទៃដី ១០ហិកតា និងច្រើនជាង។

**ក្រាហ្វិក៣.១ ភាគរយនៃការកាន់កាប់កសិកម្មចែកដីកសិកម្មដោយឡែក ចែកតាមទំហំនៃការកាន់កាប់**




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

មានចំនួនច្រើនជាងគេនៃគ្រួសារកសិកម្មដែលមានដីកសិកម្មដាច់ដោយឡែកបានគេរាយការណ៍នៅតំបន់វាលទំនាប មានរហូតដល់ទៅ ៤៦ភាគរយនៃគ្រួសារកាន់កាប់កសិកម្មសរុបនៅទូទាំងប្រទេសក្នុងនោះមានដូចជា÷ ខេត្តព្រៃវែង (១១ ភាគរយ ឬ ២០០ ០០០ ការកាន់កាប់កសិកម្ម) ខេត្តតាកែវ (១៧០ ០០០ ការកាន់កាប់កសិកម្ម) និងខេត្តកំពង់ចាម (១៣០ ០០០ ការកាន់កាប់កសិកម្ម) បាននាំមុខខ្ពស់ជាងគេ នៅខេត្តចំនួនបីក្នុងតំបន់វាលទំនាបមានចំនួនគ្រួសារបានការបែងចែកដីកសិកម្មដាច់ដោយឡែក។

### ក្រាហ្វិក៣.២ ផ្ទៃដីមធ្យមក្នុងមួយការកាន់កាប់កសិកម្មចែកតាមខេត្ត




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

នៅគ្រប់តំបន់ទូទាំងប្រទេស តំបន់វាលទំនាបបានបង្ហាញថា មានចំនួនច្រើនជាងគេនៃគ្រួសារ ដែលមានដីកសិកម្មដាច់ដោយឡែក។ យ៉ាងនេះក៏ដោយ សម្រាប់ផ្ទៃដីកសិកម្មសរុបដែលបានធ្វើ ដោយគ្រួសាកសិកម្មវិញនៅតំបន់ទន្លេសាបមានទំហំច្រើនលើសពីតំបន់វាលទំនាប។ តំបន់បឹងទន្លេសាបមានចំនួនតិចជាងនៃគ្រួសារ ដែលមានដីកសិកម្មដាច់ដោយឡែកក៏ពិតមែន ប៉ុន្តែគ្រួសារទាំងនោះ បានប្រើប្រាស់ផ្ទៃដីសម្រាប់សកម្មភាពកសិកម្ម មានទំហំធំជាងគ្រួសានៅក្នុងតំបន់វាលទំនាប។ ខេត្តប៉ៃលិន គឺជាខេត្តដែលតូចជាងគេនៅក្នុងតំបន់ទន្លេសាប គិតជាមធ្យមផ្ទៃដីនៃការកាន់កាប់កសិកម្ម (៤,៤១ហិកតា) គឺមានចំនួនខ្ពស់ជាង ឆ្ងាយពីមធ្យមភាគថ្នាក់ជាតិ គឺ ១,៦៤ហិកតា ក្នុងការកាន់កាប់កសិកម្ម។

ទំហំមធ្យមនៃការចែកដីកសិកម្មដោយឡែក ដែលបានប្រើប្រាស់សម្រាប់ ការកាន់កាប់មួយគ្រួសារកសិកម្មបានរាយការណ៍មាន ១,៦៤ហិកតា។ មធ្យមផ្ទៃដីនៃដីកសិកម្មចែកដោយឡែក ដែលបានប្រើប្រាស់ដោយការកាន់កាប់គ្រួសារនៅតំបន់បឹងទន្លេសាប និងតំបន់ខ្ពង់រាបនិងជួរភ្នំមានមធ្យមភាគខ្ពស់ជាងថ្នាក់ជាតិ។ មាន១៦ខេត្តដែលបានរាយការណ៍ពីមធ្យមភាគការកាន់កាប់គ្រួសារកសិកម្មលចែកដីកសិកម្មដោយឡែក មានទំហំធំជាងមធ្យមថ្នាក់ជាតិនៃ១,៦៤ហិកតា។ គ្រួសារកាន់កាប់កសិកម្មមានទំហំធំជាងមធ្យមភាគនៅថ្នាក់ជាតិ ១,៦៤ហិកតា។ មធ្យមភាគទំហំនៃគ្រួសារកាន់កាប់កសិកម្មទាំង១៦ខេត្តនេះ មានតាមលំដាប់ពី ៥,០១ហិកតានៅខេត្តឧត្តមានជ័យ និងចំនួន ៣,០១ហិកតា នៅខេត្តបន្ទាយមានជ័យ ១,៧៥ហិកតានៅខេត្តកំពង់ធំ និងខេត្តត្បូងឃ្មុំ។ នៅតំបន់ភ្នំនិងខ្ពង់រាបស្ទើគ្រប់ខេត្តទាំងអស់ លើកលែងតែខេត្តកំពង់ស្ពឺចេញ ដែលបានរាយការណ៍ មានមធ្យមភាគផ្ទៃដីច្រើនជាង២ហិកតាសម្រាប់គ្រួសារ ដែលបានបែងចែកដីកសិកម្មដោយឡែក។ ខេត្តដែលមានទំហំមធ្យមផ្ទៃដីនៃការកាន់កាប់កសិកម្មរបស់ពួកគេទាបជាងមធ្យមផ្ទៃដីថ្នាក់ជាតិនោះ គឺមានខេត្តកំពង់ស្ពឺ (០,៩៦ ហិកតា) កែប (០,៩១ ហិកតា) តាកែវ (០,៩១ហិកតា) និងកណ្ដាល (០,៨៣ហិកតា)។

គ្រួសារកសិកម្មដែលកាន់កាប់ដីទំហំធំ (មានទំហំផ្ទៃដីចាប់ពី ៥០ហិកតាឡើងទៅ) មានផ្ទៃដីជាមធ្យម (១៩០,៤៧ ហិកតា) មានន័យថាគ្រួសារកសិកម្មទាំងនោះ ជាគ្រួសារកសិកម្មកាន់កាប់ផ្ទៃដីធំបំផុត។

## ការបែងចែកគ្រួសារកាន់កាប់កសិកម្មតាមក្បាលដី

ការកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជាជាទូទៅ ត្រូវបានបង្កើតឡើងជាច្រើនចំណែកនៃផ្ទៃដីហៅថា ក្បាលដី ត្រូវបានកំណត់និយមន័យថា គឺជាចំណែកដីទាំងឡាយណា ដែលស្ថិតនៅក្រោមការកាន់កាប់មួយប្រភេទពោលគឺ សិទ្ធិក្នុងការប្រើប្រាស់ដី សម្រាប់គោលបំណងកសិកម្មដែលហ៊ុំព័ទ្ធទាំងស្រុងដោយដីអ្នកផ្សេងទៀត ឬទឹក ឬផ្លូវ ឬព្រៃឈើ ឬលក្ខណៈពិសេសផ្សេងទៀត មិនបានបង្កើតជាផ្នែកមួយនៃការកាន់កាប់នោះទេ អាចជាវាល ឬដីមួយ ឬច្រើន ដែលនៅជាប់ៗគ្នា។

ក្រាហ្វិក៣.៣ ភាគរយនៃការកាន់កាប់កសិកម្មចែកដីកសិកម្មដោយឡែកតាមចំនួនក្បាលដី (មិនរាប់បញ្ចូលជុំវិញផ្ទះ)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ចំនួន៩០ភាគរយនៃគ្រួសារកាន់កាប់កសិកម្មនៅប្រទេសកម្ពុជា បានរាយការណ៍ថា ធ្វើកសិកម្មនៅក្នុងក្បាលដីចន្លោះពីមួយក្បាលដី ទៅបីក្បាលដី នៅពេលដែល ១,៨៨ លានគ្រួសារបានចែកដីកសិកម្មដោយឡែកពីគ្នា មានរហូតដល់ទៅ ៣.៧៣១.៥៩១ក្បាលដី។ ចំនួនក្បាលដីសរុបឡើងដល់ទៅ ៥,៤លានក្បាលដី នៅពេលដែលដីជុំវិញផ្ទះត្រូវបានរាប់បញ្ចូលជាមួយនឹងដីដែលបានចែកដោយឡែកពីគ្នា។ ៣០ភាគរយនៃក្បាលដីទាំងអស់ គឺជាការធ្វើកសិកម្មនៅជុំវិញផ្ទះរបស់គ្រួសារកាន់កាប់កសិកម្ម។ ជាទូទៅក្បាលដីបរិវេណជុំវិញផ្ទះមានទំហំតូចជាង ធ្វើឱ្យទំហំមធ្យមក្នុងមួយក្បាលដីនៅថ្នាក់ជាតិថយចុះពី ០,៨២ហិកតា ទៅ ០,៦០ហិកតា ពេលក្បាលដីជុំវិញផ្ទះត្រូវបានរាប់បញ្ចូលក្បាលដីធំៗត្រូវបានចែកដោយឡែកទៅជាដីកសិកម្ម។

ការប្រើប្រាស់ក្បាលដីជាចម្បងគឺ សម្រាប់ការដាំដុះដំណាំបណ្តោះអាសន្ន (វដ្តនៃដំណាំតិចជាង១ឆ្នាំ) ឬដាំដំណាំអចិន្ត្រៃយ៍ (វដ្តនៃដំណាំច្រើនជាង១ឆ្នាំ) និងសម្រាប់គោលបំណងផ្សេងទៀត។ ក្បាលដីប្រើប្រាស់សម្រាប់ការដាំដុះដំណាំរដូវរយៈពេលខ្លីបានបង្ហាញថា មានភាគរយតិចជាងពីក្បាលដីដែលបានដាំដំណាំអចិន្ត្រៃយ៍។ ក្បាលដីដែលបានប្រើប្រាស់សម្រាប់ការដាំដំណាំនៅក្នុងសកម្មភាពកសិកម្មគឺមាន ៣,៧ លាន ក្បាលដី (៦៨ភាគរយនៃក្បាលដីសរុបទាំងអស់)។ បន្ថែមលើនេះ មានការដាំដំណាំនៅបរិវេណជុំវិញផ្ទះ ហើយក៏មានផងដែរនូវការធ្វើរួមគ្នាជាមួយនឹងសកម្មភាពកសិកម្មផ្សេងទៀតដូចជាការចិញ្ចឹមបសុសត្វ និង/ឬបសុបក្សី។

### ក្រាហ្វិក៣.៤ ភាគរយនៃក្បាលដី (រួមបញ្ចូលដីជុំវិញផ្ទះ) តាមការប្រើប្រាស់ដីជាចម្បង




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## *ក្បាលដីប្រើប្រាស់ជាចម្បង*

ការប្រើប្រាស់ក្បាលដីជាចម្បងបានបង្ហាញថា ប្រាំពីរក្នុងចំណោមដប់ បានប្រើប្រាស់ក្បាលដីសម្រាប់ការដាំដំណាំរដូវរយៈពេលខ្លី និង/ឬដំណាំអចិន្ត្រៃយ៍។ មួយភាគបីនៃក្បាលដីរាយការណ៍ថា បានប្រើប្រាស់ក្បាលដីចម្បងនៃលំនៅដ្ឋានរបស់គ្រួសារកសិកម្ម ប៉ុន្តែចំណែកដីនៅជុំវិញលំនៅដ្ឋានទាំងនេះ ក៏បានប្រើប្រាស់ផងដែរសម្រាប់ដាំដំណាំ និង/ឬចិញ្ចឹមបសុសត្វ និង/ឬបសុបក្សី។

មានចំនួនភាគរយតិចតួចនៃក្បាលដីដែលបានរាយការណ៍ថា ទុកចោលឱ្យនៅទំនេរក្នុងរយពេលប្រាំឆ្នាំកន្លងមក។ ម្យ៉ាងវិញទៀតក៏មានភាគរយតិចតួចនៃក្បាលដីដែលបានប្រើប្រាស់សម្រាប់កសិកម្មផ្សេងទៀតដូចជាវាលស្មៅសាធារណៈ បម្រាប់ចិញ្ចឹមបសុសត្វនិងបសុបក្សី។ល។

ផ្ទៃដីមធ្យមក្នុងមួយក្បាលដីបានដាំដំណាំរដូវរយៈពេលខ្លី (០,៧៩ហិកតា) ទាបជាងមធ្យមក្នុងមួយក្បាលដីបានដាំដំណាំអចិន្ត្រៃយ៍ (១,២៧ហិកតា) និងក្បាលដីដែលបានដាំរួមបញ្ចូលគ្នាដំណាំរដូវរយៈពេលខ្លី និងដំណាំអចិន្ត្រៃយ៍ (១,៣៤ហិកតា)។ ជាមួយនោះ មានរាប់លានក្បាលដីនៃក្បាលដីដាំដំណាំដំណាំរដូវរយៈពេលខ្លី បើប្រៀបធៀបទៅនឹងក្បាលដីដាំដំណាំអចិន្ត្រៃយ៍ មានមធ្យមភាគក្នុងមួយក្បាលដីនៃដំណាំដំណាំរដូវរយៈពេលខ្លី តូចជាងមធ្យមភាគនៃក្បាលដីដាំដំណាំអចិន្ត្រៃយ៍។

ក្រាហ្វិក៣.៥ ទំហំក្បាលដីគិតជាហិកតាសម្រាប់ក្បាលដីដែលប្រើប្រាស់ក្នុងការកាន់កាប់ដែលចែកដីកសិកម្មដោយឡែក




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

### ***កម្មសិទ្ធិដីនៃក្បាលដី***

គ្រួសារកសិកម្មចំនួន ៩៨ភាគរយបានរាយការណ៍ថា ជាម្ចាស់កម្មសិទ្ធិលើក្បាលដីរបស់ពួកគេ ដែលមានចំនួនផ្ទៃដីសរុបចំនួន ៣,១៧លានហិកតា។ ម្ចាស់ក្បាលដីនៃគ្រួសារទាំងនោះ មានមធ្យមភាគតូចជាងទំហំក្បាលដី ដែលបានជួលដោយបង់ប្រាក់ និង/ឬជាផលដំណាំ និង/ឬមិនបង់ប្រាក់ ឬក៏ស្ថិតនៅក្រោមប្រភេទនៃការកាន់កាប់ផ្សេងទៀត។ មធ្យមភាគផ្ទៃដីក្នុងមួយកម្មសិទ្ធិក្បាលដីមានប្រមាណ ០,៥៩ហិកតា។ មធ្យមភាគផ្ទៃដីធំជាងគេក្នុង១ក្បាលដី បានរាយការណ៍គឺជាក្បាលដីដែលបានជួល ដោយបង់ប្រាក់ និង/ឬជាផលដំណាំ ១,៥៦ហិកតា។ ក្បាលដីជួលដោយមិនបង់ប្រាក់មានមធ្យមភាគក្នុង១ក្បាលដីគឺ០,៧៣ហិកតា និងនៅក្បាលដីដែលស្ថិតនៅក្រោមប្រភេទនៃការកាន់កាប់ផ្សេងទៀតមានមធ្យមភាគ០,៧៩ហិកតា។

នៅតំបន់បឹងទន្លេសាប និងតំបន់ខ្ពង់រាបនិងជួរភ្នំ មានចំនួនម្ចាស់កម្មសិទ្ធិក្បាលដីច្រើនជាងមធ្យមភាគម្ចាស់កម្មសិទ្ធិក្បាលដីនៅថ្នាក់ជាតិ។ ប្រាំបីខេត្តដែលស្ថិតនៅក្នុងពីរតំបន់បានរាយការណ៍ថា មានផ្ទៃដីជាមធ្យមក្នុងមួយក្បាលដីជាកម្មសិទ្ធិច្រើនជាង ១ហិកតានោះគឺខេត្ត ប៉ៃលិន (២,៤៦ហិកតា) ឧត្តរមានជ័យ (១,៨២ហិកតា) រតនគិរី (១,៦៦ហិកតា) មណ្ឌលគិរី (១,៤៣ហិកតា) បាត់ដំបង (១,៣ហិកតា) ស្ទឹងត្រែង (១,២៩ហិកតា) ព្រះវិហារ (១,១៤ហិកតា) និងបន្ទាយមានជ័យមាន ១,១៣ហិកតា។

ក្បាលដីកម្មសិទ្ធិដែលមានផ្ទៃដីជាមធ្យមតិចជាង០,៥ហិកតា បានបង្ហាញថា ភាគច្រើនស្ថិតនៅតំបន់វាលទំនាបដែលមានដូចជាខេត្ត កំពង់ចាម ស្វាយរៀង ព្រៃវែង ភ្នំពេញ និងតាកែវ។ ខេត្តមួយចំនួនទៀតដូចជាខេត្ត កំពង់ស្ពឺ កំពង់ឆ្នាំង កំពត និងកែប ក៏បានរាយការណ៍មានមធ្យមភាគក្បាលដីកម្មសិទ្ធិតិចជាង ០,៥ហិកតា។

## ក្រាហ្វិក ៣.៦ ទំហំក្បាលដីជាមធ្យមចែកតាមខេត្ត




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

### *ដីបរិវេណនៅជុំវិញលំនៅដ្ឋានដែលបានប្រើប្រាស់ធ្វើសកម្មភាពកសិកម្មនៅក្នុងការកាន់កាប់កសិកម្ម*

មានចំនួនន ១,៦៨លានគ្រួសារ ដែលបានចែកដីកសិកម្មដោយឡែកពីគ្នា បានប្រើប្រាស់បរិវេណនៅជុំវិញលំនៅដ្ឋានរបស់ពួកគេសម្រាប់ដាំដំណាំ និង/ឬចិញ្ចឹមបសុសត្វ និង/ឬចិញ្ចឹមបសុបក្សី។ ការធ្វើកសិកម្មនៅជុំវិញលំនៅដ្ឋានទាំងនេះ មានផ្ទៃដីចំសរុបនួន ២១៥.៣២៩ហិកតា ជាមួយនឹងមធ្យមផ្ទៃដី ០,១៣ហិកតាក្នុងមួយការកាន់កាប់កសិកម្មជុំវិញផ្ទះ។ គ្រួសារដែលរស់នៅតំបន់ឆ្នេរ មានចំនួនច្រើនជាងគេ ដែលបានប្រើប្រាស់បរិវេណលំនៅដ្ឋានធ្វើសកម្មភាពកសិកម្ម បន្ទាប់មកគឺនៅតំបន់វាលទំនាប។

ចំនួនគ្រួសារដែលបានធ្វើកសិកម្មនៅជុំវិញលំនៅដ្ឋាន នៅតំបន់វាលទំនាបមានចំនួនច្រើនជាងនៅតំបន់បឹងទន្លេសាប ប៉ុន្តែការប្រើប្រាស់ផ្ទៃដីជាក់ស្តែងនៃការធ្វើកសិកម្មជុំវិញលំនៅដ្ឋាននៅតំបន់បឹងទន្លេសាប គឺមានទំហំធំជាងតំបន់វាលទំនាប។ ហើយតំបន់វាលទំនាបនេះផងដែរ បានរាយការណ៍ថា មានមធ្យមភាគផ្ទៃដីនៃការធ្វើកសិកម្មជុំវិញលំនៅដ្ឋានទាបជាងគេនៅទូទាំងប្រទេស។

ផ្ទៃដីជាក់ស្តែងសរុបនៃការធ្វើកសិកម្មជុំវិញលំនៅដ្ឋាន ការកាន់កាប់គ្រួសារកសិកម្ម ដែលបានចែកដីកសិកម្មដោយឡែកមាន៩១ភាគរយ រាយការណ៍ថា បានដាំដំណាំ និង/ឬចិញ្ចឹមបសុសត្វនិងបសុបក្សី។ ក្នុងចំណោមតំបន់ទាំងអស់

តំបន់ឆ្នេរមាន សមាមាត្រធំជាងគេនូវផ្ទៃដីប៉ាន់ស្មាននៃការធ្វើកសិកម្មជុំវិញលំនៅដ្ឋាន សូម្បីតែសមាមាត្រថ្នាក់ជាតិ។ នៅតំបន់វាលទំនាប ឈរនៅលំដាប់ទីពីរ បន្ទាប់ពីតំបន់ឆ្នេរដែលលើសពីសមាមាត្រថ្នាក់ជាតិ សម្រាប់ផ្ទៃដីប៉ាន់ស្មាននៃការធ្វើសកម្មភាពកសិកម្មនៅជុំវិញលំនៅដ្ឋាន។

### ក្រាហ្វិក៣.៧ ផ្ទៃដីជាមធ្យមនៃដីជុំវិញផ្ទះ (ហត) និងការប៉ាន់ស្មានផ្ទៃដីជាមធ្យម ដែលបានប្រើប្រាស់សម្រាប់ផលិតកម្មកសិកម្ម




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## *ដីជុំវិញបរិវេណលំនៅដ្ឋានដែលបានប្រើប្រាស់សម្រាប់ផលិតកម្មកសិកម្មកសិកម្មដោយមិនបានចែកដីកសិកម្មដោយឡែក*

មានចំនួន២៩៣.៤៣៧ នៃការកាន់កាប់គ្រួសារកសិកម្មបានធ្វើសកម្មភាពកសិកម្ម តែនៅក្នុងបរិវេណជុំវិញលំនៅដ្ឋានប៉ុណ្ណោះ នៅលើផ្ទៃដីសរុប ៤១.៨៧១ហិកតា។ ក្នុងផ្ទៃដីទាំងនោះ មាន៨៩ភាគរយ (៣៧.៤៣៧ហិកតា) ដែលបានប្រើប្រាស់សម្រាប់ដាំដំណាំ និង/ឬ ចិញ្ចឹមបសុសត្វនិងបសុបក្សី ខណៈដែលដីនៅសល់ បានប្រើប្រាស់សម្រាប់សកម្មភាពផ្សេងទៀត ដូចជាឃ្លាំងរក្សាទុកសម្ភារ/គ្រឿងម៉ាស៊ីនកសិកម្ម ជង្រុកផ្ទុកផលដំណាំ និង/ឬ រក្សាទុកបសុសត្វប្រភេទតូចនិងបសុបក្សី នៅខាងក្រោមផ្ទះ។

## ក្រាហ្វិក៣.៨ សមាមាត្រនៃការធ្វើសកម្មភាពកសិកម្មជុំវិញផ្ទះតាមប្រភេទនៃការកាន់កាប់ដី




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ការជួលបរិវេណជុំវិញផ្ទះ ដែលបានប្រើប្រាស់សម្រាប់សកម្មភាពកសិកម្មមានផ្ទៃដីដ៏ធំជាង បើប្រៀបធៀបទៅនឹងចំណែកដីនៅបរិវេណនៅជុំវិញផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ នេះបង្ហាញថា ផ្ទៃដីជុំវិញផ្ទះដែលបានជួលធ្វើសកម្មភាពកសិកម្មជាអតិបរិមា។ ភាគរយនៃការជួលបរិវេណនៅជុំវិញផ្ទះបានប្រើប្រាស់សម្រាប់សកម្មភាពកសិកម្មក៏មានខ្ពស់ជាងភាគរយមធ្យមបានប្រើប្រាស់ដោយបរិវេណនៅជុំវិញផ្ទះដែលជាកម្មសិទ្ធិផ្ទាល់។

## ការកាន់កាប់កសិកម្មគតិយុត្ត

ការកាន់កាប់កសិកម្មគតិយុត្ត ត្រូវបានគ្រប់គ្រង និងបានដំណើរការ ដោយសហគ្រាសឯកជន ឬសហគ្រាសរដ្ឋ ដោយរួមបញ្ចូលទាំងសាជីវកម្ម ដៃគូសហករណ៍ ស្ថាប័នឯកជន រដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធជាដើម។ ក្នុងអំឡុងពេលជំរឿននេះ មាន ១០១ការកាន់កាប់គតិយុត្តិ ដែលចូលរួមនៅក្នុងសកម្មភាពកសិកម្ម រួមមាន ការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សីនិង វារីវប្បកម្ម។ ចំនួននៃការកាន់កាប់កសិកម្មគតិយុត្ត ដែលបានរាយការណ៍គឺមានការពាក់ពន្ធ័តិចតួចក៏ដូចជាការគ្របដណ្តប់នៃការកា ន់កាប់គតិយុត្តិក្នុងអំឡុងពេលធ្វើជំរឿនដោយសារបញ្ហេកទេសពីការប្រមូលទិន្នន័យតាមមូលដ្ឋាន។ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទបានផ្តល់បញ្ជីនៃការកាន់កាប់គតិយុត្តិដែលបានចុះបញ្ជីនិងព័ត៌មានលម្អិត។ មន្ត្រីសម្ភាសន៍ជំរឿនបានធ្វើការទំនាក់ទំនងទៅម្ចាស់កាន់កាប់គតិយុត្តិ ដែលមាននៅក្នុងបញ្ជីទាំងអស់រួមបញ្ចូលទាំងការពិនិត្យនៅកន្លែងនៅតាមបណ្តារខេត្ត និងអាស័យដ្ឋាននៅរាជធានីភ្នំពេញ។ ក្នុងករណីខ្លះធ្វើការទាក់ទងទៅនឹងអ្នកកាន់កាប់ដែលបានចុះបញ្ជី គឺមិនទទួលបានជោគជ័យឡើយ និងករណីផ្សេងទៀតអ្នកកាន់កាប់មិនត្រូវបានរកឃើញ ដើម្បីអនុវត្តន៍សកម្មភាពកសិកម្មស្ថិពីការកាន់កាប់។

អ្នកកាន់កាប់កសិកម្មគតិយុត្តដែលបានកំណត់អត្តសញ្ញាណត្រូវបានចាត់ជាចំណាតថ្នាក់ក្រុមហ៊ុនឯកជនមានកំណត់ស្រប ច្បាប់ (ទាំងឯកជននិងសាធារណៈ)។ នៅសល់កាន់កាប់គតិយុត្តវិស័យកសិកម្មនិងវារីវប្បកម្មផ្សេងទៀតបានចុះបញ្ជីជា ក្រុមហ៊ុនឯកកម្មសិទ្ធិ (មានម្ចាស់តែមួយគត់) សហកម្មសិទ្ធិ និងជាសាខារបស់ក្រុមហ៊ុនបរទេសមួយ។ ប្រភេទផ្សេងទៀត នៃការកាន់កាប់គតិយុត្តិ ដែលអាចរួមមានអង្គការ ជាកម្មសិទ្ធិរបស់រដ្ឋ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនជាដើមផ្ទៃដីសរុប ដែលប្រតិបត្តិការ ដោយ ១០១កាន់កាប់គតិយុត្តិ រួមមាន ៨០៦.៦២៨ហិកតា ឬ មធ្យមភាគក្នុងមួយការកាន់កាប់ គតិយុត្តិស្មើនឹង ៧.៩៨៦ ហិកតា។ ទិន្នន័យបានបង្ហាញថាគ្រាន់តែចំនួនការកាន់កាប់គតិយុត្តប៉ុណ្ណោះគឺ មានចំនួនស្មើនឹង ៤៧ភាគរយនៃចំនួនសរុប ៨០៦.៦២៨ហិកតា។

ក្រាហ្វិក៣.៩ ភាគរយនៃការកាន់កាប់កសិកម្មគតិយុត្ត ចែកតាមទំហំផ្ទៃដី




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ស្ទើរតែ ១០១ការនៃកាន់កាប់គតិយុត្តត្រូវបានដំណើរការក្នុងរយៈពេលតិចជាង ១០ឆ្នាំ។ ប្រមាណ៤៦ភាគរយ បានប្រតិបត្តិការមានចំនួនតិចជាង ៥ឆ្នាំនិង ៤៧ភាគរយទៀតបានប្រតិបត្តិការពី ៥ ទៅ ៩ ឆ្នាំ។ មួយភាគតូចបានប្រតិបត្តិ ការក្នុងរយៈពេល ១០ឆ្នាំ ឬច្រើនជាង។ ចំនួនសរុបនៃក្បាលដីបានរាយការណ៍គឺមានចំនួន ២០២ក្បាលដី នៃការកាន់កាប់ គតិយុត្តិ។

### ក្រាហ្វិក៣.១០ ចំនួនឆ្នាំមធ្យមនៃប្រតិបត្តិការណ៍នៃការកាន់កាប់កសិកម្មគតិយុត្ត ចែកតាមប្រភេទនៃសកម្មភាពកសិកម្ម




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

# ជំពូកទី៤
# ការដាំដុះដំណាំ

ប្រទេសកម្ពុជាមានគ្រួសារជាចម្បងប្រកបករបបធ្វើកសិកម្មគឺ ការដាំដុះ និងការប្រើប្រាស់ទឹក ការប្រមូលផលដំណាំរយៈពេលខ្លី នឹងដំណាំអចិន្ត្រៃយ៍ផ្សេងៗទៀត។ ដំណាំរយៈពេលខ្លី គឺជាប្រភេទដំណាំដែលមានការ ដាំដុះតិចជាងមួយឆ្នាំ បន្ទាប់ពីការប្រមូលផលហើយ គឺមានការដាំដុះឡើងវិញដូចជា ការសាប ព្រោះ និងការដាំជា វដ្តនៃផលិតកម្មដំណាំ។ ដំណាំបន្ទាប់បន្សំបានបង្ហាញនៅក្នុងការធ្វើជំរឿននេះ បង្ហាញស្ថានភាពរីកចម្រើនទៅតាម រដូវកាលក្នុងអំឡុងរយៈពេលឆ្នាំ២០១៣ ហើយមានការពាក់ព័ន្ធនឹងចំណាត់ថ្នាក់ដំណាំដ៏សំខាន់ជាចម្បងទាំង១៤ រួមមាន គ្រប់ធញ្ញជាតិ និងធញ្ញជាតិ បន្លែ ស្រូវ ដំណាំគ្រាប់ ដូងប្រេង ដំណាំយកមើមមានច្រើនប្រភេទ ដំណាំ គ្រឿងទេស រុក្ខជាតិក្រអូបនិងឱសថ ដំណាំឧស្សាហកម្ម និងដំណាំបន្លែ។

ដំណាំអចិន្ត្រៃយ៍គឺជាប្រភេទដំណាំមានការដាំដុះលើសពីមួយឆ្នាំនៃវដ្តលូតលាស់របស់ដំណាំនិងលទ្ធផល ត្រូវបានយោងតាមផលិតភាពកសិកម្ម ដែលមានរយៈពេលក្នុងការកាន់កាប់ដី។ រីឯប្រភេទទាំង១១ជាចម្បង ត្រូវបានប្រើក្នុងការកំណត់អត្តសញ្ញាណដ៏សំខាន់នៃដំណាំអចិន្ត្រៃយ៍ខុសៗគ្នារួមមាន ការដាំដុះដំណាំហូបផ្លែ ដំណាំ យកគ្រាប់អាចបរិភោគបាន ដំណាំយកប្រេង ដំណាំកៅស៊ូ ដំណាំជាគ្រឿងទេស និងដំណាំជាគ្រឿងក្រអូម និង ប្រភេទដំណាំដែលមិនមែនជាអាហារផ្សេងទៀត។

ប្រភេទដំណាំទាំងពីរខាងលើ ជាប្រភេទដំណាំក្នុងលក្ខខណ្ឌនៃតំបន់ បានបង្ហាញនូវទំហំផ្ទៃដីអនុវត្តការដាំដំណាំ ផ្ទៃដីមូលផល និងផ្ទៃដីស្រោចស្រពនៃតំបន់នោះ។ ផ្ទៃដីបានដាំដុះយោងទៅលើដីដែលបានប្រើប្រាស់សម្រាប់ ប្រតិបត្តិការកសិកម្ម បានគណនាជាចំនួនការដាំដំណាំដូចគ្នា ឬក៏ដំណាំផ្សេងៗគ្នាច្រើនដងត្រូវបានដាំដុះអំឡុងពេលកាលបរិច្ឆេទយោង។

## ដំណាំធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់

ប្រភេទទាំងពីរនេះជាដាំណាំដ៏សំខាន់ មានការដាំដុះច្រើនជាងគេនោះដាំដំណាំស្រូវនិងពោត។ ដោយផ្អែកលើការប្រើប្រាស់ដីផ្ទៃដីអនុវត្តសរុបចំនួន ២,៤៥លានហិកតា នៃដំណាំធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់ ដែល បានដាំក្នុងអំឡុងពេលឆ្នាំ ២០១៣ រួមមានប្រមាណ ៨៦ភាគរយ នៃផ្ទៃដីសរុបបានប្រើសម្រាប់ការដាំដុះដំណាំរដូវ រយៈពេលខ្លី។ ជាពិសេសដំណាំស្រូវសរុបចំនួន ៨២ភាគរយនៃផ្ទៃដីសរុបដាំដុះដំណាំរដូវរយៈពេលខ្លីនៅក្នុងប្រទេសកម្ពុជា។

ក្រាហ្វិក៤.១ ផ្ទៃដីដំណាំធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

មានស្រូវបីប្រភេទដែលបានដាំដុះគឺ ស្រូវធម្មតា ស្រូវក្រអូម និងស្រូវដំណើម (អង្ករស្អិត)។ ដំណាំពោតត្រូវបានបែងចែកជាពីរក្រុម ពោតខ្ចី និងពោតស/ក្រហម/ស្វាយ។ ក្នុងចំណោមស្រូវទាំងបីប្រភេទស្រូវធម្មតាមានចំនួនច្រើនជាងគេ គឺបានដាំនៅលើផ្ទៃដីចំនួន ២លានហិកតាសម្រាប់ក្បាលដីចំនួន ៣លានក្បាលដី។

**តារាង៤.១ ចំនួនក្បាលដីនិងផ្ទៃដីដាំដុះដំណាំពូជជាចម្បងនៃធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់**

| ដំណាំចម្បងនៃធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់ | ចំនួនក្បាលដី | ផ្ទៃដីដាំដុះ | មធ្យមផ្ទៃដី/ក្បាលដី |
|---|---|---|---|
| ស្រូវធម្មតា | 2,816,780 | 2,029,418.20 | 0.72 |
| ស្រូវក្រអូប | 301,168 | 280,359.11 | 0.93 |
| ពោត | 85,114 | 125,179.69 | 1.47 |
| ស្រូវដំណើម | 49,355 | 18, 028.16 | 0.37 |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

បន្ទាប់ពីស្រូវធម្មតា គឺមានដំណាំសំខាន់ៗផ្សេងទៀតដូចជាស្រូវក្រអូបបានដាំដុះនៅលើផ្ទៃដីសរុបប្រមាណជាង ២៨០.០០០ហិកតា និងផ្ទៃដីដាំដុះពោតប្រមាណជាង ១២៥.០០០ហិកតា ក្នុងរយៈពេលយោង។

តាមបណ្តាខេត្តចំនួន ១០ បានរាយការណ៍ថា មានការដាំដុះដំណាំស្រូវធម្មតានៅលើផ្ទៃដី ១០០.០០០ហិកតា ឬច្រើនជាងគឺមាន÷ ខេត្តបាត់ដំបង ព្រៃវែង សៀមរាប បន្ទាយមានជ័យ តាកែវ កំពង់ធំ ស្វាយរៀង កំពង់ស្ពឺ កំពត និងខេត្តកំពង់ចាម។ ដោយឡែកខេត្តចំនួន៤ មានផ្ទៃដីសរុបតិចជាង ១០.០០០ហិកតា ដែលបានដាំដំណាំស្រូវធម្មតាមានដូចជា÷ ខេត្តព្រះសីហនុ កោះកុង កែប និងខេត្តប៉ៃលិន។

ការកាន់កាប់កសិកម្មគ្រប់តាមបណ្តាខេត្តនៅទូទាំងប្រទេសក៏បានរាយការណ៍អំពីការដាំស្រូវក្រអូបផងដែរ។ ក្នុងនោះខេត្តចំនួនប្រាំបួនបានដាំដុះស្រូវក្រអូបដែលមានផ្ទៃដីសរុបជាង ១០.០០០ហិកតា មានដូចជា÷ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ធំ ពោធិ៍សាត់ សៀមរាប ព្រះវិហារ ព្រៃវែង កំពង់ស្ពឺ និងខេត្តតាកែវ។ រីឯខេត្តចំនួន៦ផ្សេងទៀតបានដាំដុះស្រូវក្រអូបដែលមានផ្ទៃដីសរុបតិចជាង ១.០០០ហិកតាដូចជា÷ ខេត្តព្រះសីហនុ កំពត រតនគីរី កោះកុង ស្វាយរៀង និងខេត្តកែប។ ចំពោះគ្រួសារកាន់កាប់កសិកម្ម នៅក្នុងខេត្តមណ្ឌលគីរី មិនបានរាយការណ៍ពីការដាំដុះស្រូវក្រអូបឡើយ។

ពូជស្រូវក្រអូបការដាំដុះនូវមានកម្រិត មិនទាន់បានទូលំទូលាយនៅឡើយ តិចជាពូជស្រូវធម្មតា។ មានតែ១៣ខេត្តដែលមានផ្ទៃដីដាំដុះស្រូវក្រអូបច្រើនជាង ១០០ហិកតា ហើយខេត្តទាំង៧ខេត្តនោះ ផ្ទៃដីដាំដុះពូជស្រូវក្រអូបប្រមាណជាង ១.០០០ហិកតា។ ចំណែកឯខេត្តមានផ្ទៃដីដាំដុះស្រូវក្រអូបច្រើនរួមមាន÷ ខេត្តតាកែវ ស្វាយរៀង និងខេត្តព្រៃវែង (នៅក្នុងតំបន់វាលទំនាប)កំពង់ស្ពឺ ព្រះវិហារ និងរតនគីរី (នៅក្នុងខ្ពង់រាបនិងភ្នំ) និងកំពង់ធំ (តំបន់បឹងទន្លេសាប)។ រីឯខេត្តក្រចេះ ព្រះសីហនុ កោះកុង កែប និងខេត្តមណ្ឌលគីរី ដែលមានផ្ទៃ ដីដាំដុះស្រូវក្រអូមមានចំនួនតិចជាង ១០០ហិកតា ក្នុងនោះខេត្តកណ្តាល និងប៉ៃលិន ក៏មិនមានការដាំដែរ។

ផ្ទៃដីដាំដុះពោតទាំង ២៥ រាជធានីខេត្ត ក្នុងនោះ ខេត្តបាត់ដំបងមានផ្ទៃដីដាំពោតសរុបចំនួន ៦០.០០០ហិកតា ហើយជាខេត្តដែលមានទំហំផ្ទៃដីដាំពោតច្រើនជាងគេនៅក្នុងតំបន់។តាមបណ្តាខេត្តផ្សេងៗ ទៀតមានផ្ទៃដីដាំដុះដំណាំ

ពោតទំហំធំដែលរួមមានខេត្ត ប៉ៃលិន (២១.០០០ហិកតា) និងកណ្ដាល (១៤.០០០ ហិកតា)។ ដោយឡែកខេត្ត កែបនិង ឧត្តរមានជ័យមាន ផ្ទៃដីដាំដុះដំណាំពោតមានតិចជាង ១០០ហិកតា។

**ក្រាហ្វិក៤.២ ផ្ទៃដីដាំដុះដំណាំពោត (ស/លឿង/ស្វាយ) ច្រើនទាំង១០ខេត្ត**




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

**ក្រាហ្វិក៤.៣ ចំនួនក្បាលដីនិងផ្ទៃដីដាំដុះដំណាំពូជជាចម្បងនៃធញ្ញជាតិនិងធញ្ញជាតិយកគ្រាប់**




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

**ការប្រមូលផល**

ការប្រមូលផល គឺជាការច្រូតកាត់ផលដំណាំតាមតំបន់ប្រមូលទុកដាក់ទាំងស្រុង ដោយមិនរាប់បញ្ចូលនូវការខូចខាត ឬការប្រមូលផលមិនបាន ដោយជួបគ្រោះធម្មជាតិ ដែលកើតឡើងនៅក្រោយពេលដាំដុះឆ្នាំ ២០១៣។

នៅទូទាំងប្រទេសកម្ពុជាប្រមាណ ៩៥ភាគរយ នៃផ្ទៃដីសរុប ជាមួយនឹងស្រូវធម្មតានិងស្រូវក្រអូបអាចប្រមូលផល។ ប្រភេទស្រូវធម្មតាបានប្រមូលផលច្រើនចំនួន ១,៨លានហិកតា និងជាសមាមាត្រខ្ពស់បំផុតនៃដំណាំស្រូវធម្មតាក្នុងពេលប្រមូលផល គឺនៅក្នុងតំបន់ឆ្នេរសមុទ្រ (៩៦ភាគរយនៃចំនួនសរុបដែលបានប្រមូល ផលដំណាំ)។ នៅតំបន់ខ្ពង់រាបនិងជួរភ្នំ ការប្រមូលផលនៃប្រភេទស្រូវធម្មតាប្រមូលផលបានប្រមាណ ៩៤ភាគ រយនៃផ្ទៃដីដាំដុះក្នុងតំបន់។ នៅក្នុងតំបន់បឹងទន្លេសាប៩០ភាគរយ (ផ្ទៃដីប្រមាណ ៨១២.០០០ហិកតា) នៃដំណាំស្រូវធម្មតាត្រូវបានប្រមូលផល និងនៅក្នុងតំបន់វាលទំនាបផ្ទៃដីប្រមូលផលមានប្រមាណតែ ៨៨ភាគរយ (ផ្ទៃដីប្រមាណចំនួន ៦៦៤.០០០នៃផ្ទៃដីសរុប)។

ផ្ទៃដីចំនួន២៥៥.០០០ហិកតា នៃស្រូវក្រអូបត្រូវបានប្រមូលផល ក្នុងពេលដែលស្រូវក្រអូបប្រមូលផលបានតិចបំផុត នៃធញ្ញជាតិនិងធញ្ញជាតិមានចំនួន១៦.៤២០ហិកតា។ ផ្ទៃដីសរុបចំនួន១០៦.០០០ហិកតា នៃផ្ទៃដី សរុបពោត (ស/លឿង/ស្វាយ) ត្រូវបានប្រមូលផលប្រមាណ៨៥ភាគរយនៃដំណាំដាំដុះ។ ផ្ទៃដីភាគច្រើនដំណាំ ពោតបានប្រមូលផលនៅតំបន់បឹងទន្លេសាប។

ចំនួនប្រាំខេត្ត ភាគច្រើនបានប្រមូលផលពេញលេញប្រភេទស្រូវធម្មតា ដូចជា÷ ខេត្តបាត់ដំបង ដែលមានផ្ទៃដីចំនួន ១៧០.០០០ហិកតា ខេត្តព្រៃវែងផ្ទៃដីចំនួន ១៦២.០០០ហិកតា ខេត្តសៀមរាបផ្ទៃដីចំនួន ១៣៧.០០០ហិកតា ខេត្តតាកែវផ្ទៃដីចំនួន ១២៧.០០០ហិកតា និងខេត្តកំពង់ធំផ្ទៃដីសរុបចំនួន ១២០.០០០ហិកតា។ សមាមាត្រដ៏ធំបំផុតនៃផ្ទៃដីដែលនបានប្រមូលផលធៀបទៅនឹង ផ្ទៃដីសម្រាប់ស្រូវក្រអូប គឺមាននៅក្នុងខេត្តបន្ទាយមានជ័យ ផ្ទៃដីចំនួន ៤១.០០០ ហិកតា ខេត្តពោធិ៍សាត់ផ្ទៃដីចំនួន ៣២.០០០ហិកតា ខេត្តបាត់ដំបងផ្ទៃដីចំនួន ២៥.០០០ហិកតា ខេត្តសៀមរាបផ្ទៃដីចំនួន ២៤.០០០ និងខេត្ត ព្រះវិហារចំនួន (១៩.០០០ហិកតា)។

ផ្ទៃដីដាំដុះពោតត្រូវបានប្រមូលផលទាំងស្រុង នៅតាមបណ្តាខេត្តមួយចំនួនដូចជាខេត្ត បាត់ដំបងផ្ទៃដី ចំនួន ៥៣.០០០ហិកតា និងខេត្តប៉ៃលិនផ្ទៃដីចំនួន១៧.០០០ហិកតា។

ក្រាហ្វិក៤.៤ ផ្ទៃដីប្រមូលផលដំណាំជាចម្បងធញ្ញជាតិនិងធញ្ញជាតិគ្រាប់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ផ្ទៃដីដាំដុះដំណាំធញ្ញជាតិបង្ហាញខាងក្រោមនេះ ដែលមានផ្ទៃដីដាំដុះធំជាងផ្ទៃដីប្រមូលផល។ យ៉ាងហោចណាស់ផ្ទៃដី៩០ភាគរយ នៃដំណាំធញ្ញជាតិដាំត្រូវបានប្រមូលផលក្នុងអំឡុងពេលធ្វើជំរឿន។ គួរកត់សម្គាល់ថា ផ្ទៃដីដំណាំធញ្ញជាតិអាចប្រមូលផលបានក្រោយពេលដាំដុះជាច្រើនខែ។

ផ្ទៃដីប្រមូលផលយ៉ាងហោចណាស់ ៨០ភាគរយ នៃដំណាំដាំដុះស្រូវ និងផ្ទៃដីចំនួន ៧៧ភាគរយនៃផ្ទៃដីដាំដុះពោត (ស/លឿង/ស្វាយ) ត្រូវបានគេប្រមូលផលបានទាំងស្រុងក្នុងអំឡុងពេលធ្វើជំរឿន។

### ក្រាហ្វិក៤.៥ ភាគរយនៃការប្រមូលផលដំណាំតាមប្រភេទដំណាំ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ផ្ទៃដីដាំដុះមួយភាគតូចនៃដំណាំស្រូវនិងពោត បានប្រមូលផលលើសពីរយៈពេលជំរឿនចំណែកផ្នែកផ្សេងទៀត នៃដំណាំនេះ ដែលមិនបានប្រមូលផលដោយមានការខូចខាត។

### ក្រាហ្វិក៤.៦ ផ្ទៃដីប្រមូលផល (ទាំងស្រុង ដោយផ្នែក ឬទទួលបានប្រមូលផល) សម្រាប់ដំណាំជាចម្បងធញ្ញជាតិ និងធញ្ញជាតិគ្រាប់តាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

នៅតំបន់បឹងទន្លេសាបការកាន់កាប់កសិកម្ម ផ្ទៃដីដាំដុះមានចំនួនខ្ពស់បំផុត ជាមួយនឹងការប្រមូលផលស្រូវក្រអូប មានចំនួនសរុបប្រមាណជាង ៨៥៨.០០០ហិកតា។ នៅក្នុងតំបន់នេះ ដែលមានទិន្នន័យខ្ពស់បំផុតបានប្រមូលផលស្រូវក្រអូប និងផ្ទៃដីដាំពោតមានចំនួន ១៨៧ពាន់ហិកតា និងផ្ទៃដីដាំដុះដំណាំផ្សេងៗប្រមាណ ៨៦.០០០ហិកតា។ ជាមួយនោះ នៅក្នុងតំបន់វាលទំនាប ផ្ទៃដីប្រមូលផលស្រូវធម្មតាមានចំនួន ៦៨៦.០០០ហិកតាតាមទិន្នន័យជំរឿន។

ផ្ទៃដីប្រមាណ ៤ភាគរយ (១០៨.០០០) នៃផ្ទៃដីសរុបដាំស្រូវប្រភេទធម្មតាក្នុងនោះ ផ្ទៃដីប្រមូលផលអាចលើសពីការធ្វើជំរឿនកសិកម្ម។ ផ្ទៃដីចំនួន ១៦ម៉ឺនក្បាលដី (0,៥ភាគរយ) បានទទួលរងនូវការបំផ្លាញដោយទឹកភ្លៀងធ្លាក់ខ្លាំងនិងទឹកជំនន់ និងជួបគ្រោះធម្មជាតិផ្សេងៗទៀត។

ផ្ទៃដីដាំដុះស្រូវក្រអូបប្រមាណ ៥.០០០ក្បាលដី (២ភាគរយ) នៃក្បាលដីសរុប អាចប្រមូលផលបានយោងតាមទិន្នន័យធ្វើជំរឿន និងផ្ទៃដីចំនួន ៣.០០០ក្បាលដីផ្សេងទៀត ដែល (១ភាគរយ) មិនបានប្រមូលផល ដោយសារជួបបញ្ហាផ្សេងៗកើតមានដោយសារគ្រោះធម្មជាតិ។

ផ្ទៃដីប្រមាណ ១៤ភាគរយ នៃក្បាលដីសរុប ដែលបានដាំដុះពោត (ស/លឿង/ស្វាយ) ជាផ្ទៃដីប្រមូលផលដំណាំពោតដូចទិន្នន័យពេលក្រោយជំរឿនកសិកម្ម។ ផ្ទៃដីប្រមាណ២ភាគរយ (២.០០០)នៃផ្ទៃដីសរុប ដីផ្សេងទៀតនិងក្បាលដីសរុបដាំដុះពោត មិនអាចប្រមូលផលពោតបានដោយជួបគ្រោះធម្មជាតិដូចជា ទឹកជំនន់ និងមានភ្លៀងធ្លាក់ខ្លាំង។ល។

## ការស្រោចស្រព

ដោយសារតែវត្តមាននៃប្រព័ន្ធធារាសាស្រ្ត តំបន់វាលទំនាបមានផ្ទៃដីចំនួនច្រើនបំផុតនៃក្បាលដីផ្ទៃដីស្រោចស្រព (៤១២.០០០ហិកតា) បានដាំគ្រាប់ធញ្ញជាតិ/ធញ្ញជាតិ។ នៅតំបន់ស្រោចស្រពនៃក្បាលដីជាមួយនឹងដីដាំគ្រាប់ធញ្ញជាតិ/ធញ្ញជាតិ ផ្ទៃដីចំនួន២២ភាគរយនៃផ្ទៃដីសរុបនៃក្បាលដីទាំងអស់ ស្ថិតនៅក្រោមការដំណាំរដូវរយៈពេលខ្លី។ គ្រួសារកាន់កាប់កសិកម្ម ក្នុងតំបន់បឹងទន្លេសាប មានតែពាក់កណ្តាលចំនួនស្ថិតនៅក្នុងប្រព័ន្ធធារាសាស្រ្ត បើប្រៀបធៀបទៅនឹងតំបន់វាលទំនាប នៅតំបន់មានផ្ទៃដីទំហំធំបានដាំដុះដំណាំដំណាំ រដូវរយៈពេលខ្លី តិចជាងវាលទំនាប។ ដូច្នេះ តំបន់បឹងទន្លេសាប ការដាំដុះនិងប្រមូលផល ជាតំបន់ដែលមានទំហំធំជាងគ្រួសារនៅក្នុងតំបន់ផ្សេងទៀត រួមទាំងវាលទំនាប។ តំបន់ខ្ពង់រាបនិងជួរភ្នំ និងតំបន់ឆ្នេរសមុទ្រនៅតំបន់មានផ្ទៃដីតូចបំផុត ដែលបានដាំដុះដំណាំរដូវរយៈពេលខ្លី។

ក្រាហ្វិក៤.៧ ផ្ទៃដីស្រោចស្រពសម្រាប់ធញ្ញជាតិនិងធញ្ញជាតិគ្រាប់តាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែម ឆ្នាំ២០១៤)

## ដំណាំយកមើម

ដំណាំយកមើមមានផ្ទៃដីដាំដុះសរុបចំនួន ២៩៩.០០០ហិកតា និងបានរួមបញ្ចូល ដំឡូងមី ដំឡូងជ្វា ត្រាវនិងមើមក្រអៅឈូក ចូលរួមចំណែកធំបំផុតនៃដំណាំនោះ មានផ្ទៃដីសរុបប្រមាណជិត ២៩៤.០០០ហិកតានៃផ្ទៃដីសរុប។ ទោះជាយ៉ាងណាក្តី ការប្រមូលផលដំឡូងមី គឺផ្ទៃដីទាបជាងចំនួន ២១១.០០០ហិកតា។

ខេត្តចំនួនពីរ បានអនុវត្តធ្វើកសិកម្មដំឡូងមីដូចជាខេត្តបាត់ដំបងចំនួន ៥៥.០០០ហិកតា និងខេត្តត្បូងឃ្មុំចំនួន ៥០.០០០ហិកតា។ ផ្ទៃដីដំណាំដាំដុះដំឡូងមីមានចន្លោះចាប់ពី ១០.០០០ហិកតា ដល់ ៣០.០០០ហិកតា ដូច ជាខេត្តក្រចេះ បន្ទាយមានជ័យ រតនគីរី កំពង់ធំ ប៉ៃលិន កំពង់ចាម ឧត្តរមានជ័យ ព្រះសីហនុ និងខេត្តស្ទឹងត្រែង។ តំបន់ដាំដុះ

ជាមួយនឹងដំឡូងមីធំជាងគេបំផុត (និងជាអ្នកផលិតធំជាងគេបំផុត) គឺជាតំបន់បឹងទន្លេសាប។ ទោះយ៉ាងណាការប្រមូលផលដំឡូងមីនេះ គឺមានប្រមាណ ៦៥ភាគរយ នៃផ្ទៃដីសរុបបានដាំដំណាំនៅតំបន់បឹងទន្លេសាប បើធៀបទៅនឹង ៨៣ភាគរយ នៃដំណាំដំឡូងមី បានប្រមូលផលនៅក្នុងតំបន់វាលទំនាប និងមានប្រមាណ ៧៤ភាគរយ បានប្រមូលផលនៅក្នុងតំបន់ខ្ពង់រាប និងជួរភ្នំ។

ក្រាហ្វិក៤.៨ ខេត្តចំនួន១០ ដែលមានផ្ទៃដីដាំដុះដំឡូងមី (ហិកតា) ខ្ពស់ជាងគេ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែម ឆ្នាំ២០១៤)

ផ្ទៃដីប្រមូលផលដំណាំយកមើមសរុបប្រមាណ ២១៥.០០០ហិកតា ក្នុងនោះ ស្មើនឹង ៩៨ភាគរយ ជាផ្ទៃដីដាំដុះដំណាំដំឡូងមី។

ក្រាហ្វិក៤.៩ ភាគរយនៃក្បាលដីដែលបានដាំដុះដំឡូងមីបានប្រមូលផល




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែម ឆ្នាំ២០១៤)

ក្នុងចំណោមក្បាលដីចំនួន ០៧ក្បាលដី ផ្ទៃដីដាំដុះដំឡូងមីនៃក្បាលដីសរុប ១០ក្បាលដីត្រូវបានប្រមូលផលសរុបចំនួន ១៨៩.០០០ហិកតា។ នៅផ្នែកផ្សេងទៀតប្រមាណ ១១ភាគរយ នៃផ្ទៃដីសរុប អាចប្រមូលផល ដំឡូងមីសរុបចំនួន ២២.០០០ហិកតា។ ជាមួយគ្នានោះផ្ទៃដីដំឡូងមីបានការប្រមូលផលស្មើនឹង ១៩ភាគរយ នៃក្បាលដីដាំដុះសរុបដំណាំ

នេះ។ ដូចនេះ ផ្ទៃដីដាំដុះដំឡូងមីចំនួន ១.៧០០ហិកតា (ស្មើនឹង១ភាគរយ) ជាផ្ទៃដីខូចខាត ដោយសារសត្វល្អិត គ្រោះរាំងស្ងួត និងទឹកជំនន់។

ក្រាហ្វិក៤.១០ ផ្ទៃដីដាំដុះ (ហត) បានប្រមូលផល និងបានស្រោចស្រពដំឡូងមីតាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ចំនួនក្បាលដីដាំដុះដំណាំយកមើមបន្ថែមទៀត ទទួលបាននូវការស្រោចស្រពនិងការដាំដុះនោះ មានចំនួន ១៥៣.០០០ ជាមួយផ្ទៃដីក្នុងតំបន់ស្រោចស្រពចំនួន ១៦.២៥១ហិកតា។ ដំណាំដំឡូងមីគឺ ជាប្រភេទដំណាំ មួយដែលទទួលបានការស្រោចស្រពគ្រប់គ្រាន់លើផ្ទដីសរុបចំនួន ១៥.៤៨៧ហិកតា (៩៥ភាគរយ) នៃផ្ទៃដីសរុប។

ផ្ទៃដីដែលបានដាំដុះដំឡូងមីមានសក្តានុពលខ្ពស់បំផុតជាមួយការប្រមូលផល គឺនៅតំបន់បឹងទន្លេសាប។ បើប្រៀបធៀបគម្លាតរវាងផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលនៅក្នុងតំបន់នេះគឺ មានផ្ទៃដីដែលមានទំហំធំជាងគេធៀបនឹងតំបន់ផ្សេងទៀត។ ផ្ទៃដីប្រមូលផលដំឡូងមីនៅតំបន់បឹងទន្លេសាបសរុបចំនួន ៦៥ភាគរយ នៃផ្ទៃដីដាំដំឡូងមី បើធៀបទៅ នឹងតំបន់វាលទំនាបស្មើនឹង ៨៣ភាគរយ និងខ្ពង់រាបនិងជួរភ្នំស្មើនឹង ៧៤ភាគរយ។

តំបន់វាលទំនាបជាតំបន់ដែលមានការស្រោចស្រពខ្ពស់បំផុតប្រមាណ ៥៩ភាគរយ នៃផ្ទៃដីដំឡូងមី សរុបបានស្រោចស្រព។ ទន្ទឹមនឹងនោះ ដំណាំដំឡូងមី ស្ថិតនៅតំបន់ខ្ពង់រាបនិងជួរភ្នំ ផ្ទៃដីដាំដុះ និងការស្រោចស្រព ក៏ ជាតំបន់មានការដាំដុះនិងការប្រមូលផលល្អប្រសើរដែរ ប្រហាក់ប្រហែលនៅតំបន់បឹងទន្លេសាប។

## រុក្ខជាតិពពួកសណ្តែក (គ្រាប់ធញ្ញជាតិ)

រុក្ខជាតិពពួកសណ្តែក (គ្រាប់ធញ្ញជាតិ) គឺប្រភេទដំណាំគ្រាប់ធញ្ញជាតិដ៏ចម្រុះ ដែលសម្បូរទៅដោយជាតិប្រូតេអ៊ីន។ ធញ្ញជាតិពពួកសណ្តែកទាំងនេះ ត្រូវបានកំណត់ជាប្រភពមានជាតិប្រូតេអ៊ីនដ៏សំខាន់របស់ ប្រជាជន។ ផ្ទៃដីដាំដុះជារួមមានចំនួនប្រមាណ ២២.000ហិកតា នៃរុក្ខជាតិពពួកសណ្តែក។ ផ្ទៃដីដាំដុះសរុប ចំនួន ២១.០០០ហិកតា ជាមួយនោះ ផ្ទៃដីប្រមូលផលចំនួនប្រមាណ ១៨.០០០ហិកតា ជាមួយការស្រោចស្រព ប្រមាណ ៩២ភាគរយ នៃផ្ទៃដីដាំដុះសរុបក្នុងនោះផ្ទៃដីខូចខាតចំនួន ៤.០០០ហិកតា។

ក្រាហ្វិក៤.១១ ខេត្តដែលមានផ្ទៃដីដាំដុះសណ្តែកបាយច្រើនជាងគេ តាមផ្ទៃដីបានដាំដុះ (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

សណ្តែកបាយដែលបានដាំដុះជាចម្បងនៃគ្រួសារកាន់កាប់កសិកម្មនៅក្នុងខេត្តបាត់ដំបង កណ្តាល កំពត កំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង និងសៀមរាប។

## ដំណាំធញ្ញជាតិប្រេង

ដំណាំធញ្ញជាតិប្រេងដូចជា ល្ង សណ្តែកដី ល្ហុងប្រេង ផ្កាឈូករ័ត្ន និងកប្បាស ត្រូវបានដាំលើផ្ទៃដីចំនួន ៣៤.០០០ហិកតា នៃផ្ទៃដីសរុប។ ចំពោះសណ្តែកសៀងផ្ទៃដីសរុបចំនួន ៥៨ភាគរយ នៃផ្ទៃដីសរុប (២០.០០០ ហិកតា ត្រូវបានបែងចែកក្នុងចំណោម ១០.០០០ក្បាលដី)។ ផ្ទៃដីចំនួន ៣១.០០០ហិកតា នៃដំណាំធញ្ញជាតិយកប្រេងផ្ទៃដីប្រមូល ផលប្រមាណ ៤.០០០ហិកតា។ រួមមានខេត្តបាត់ដំបង រតនគីរី និងខេត្តព្រះវិហារផ្ទៃដីដាំដុះសណ្តែកសៀង យ៉ាងហោចណាស់មានចំនួន ៣.០០០ហិកតា ប្រហាក់ប្រហែលគ្នាក្នុងការដាំដុះសណ្តែកសៀងនៅទូទាំងប្រទេស។

ក្នុងចំណោមដំណាំធញ្ញជាតិយកប្រេងនេះ ផ្ទៃដីដាំដុះសណ្តែកសៀងសរុប ចំនួន២០.០០០ហិកតា សម្រាប់ថ្នាក់ជាតិ។

ក្រាហ្វិក៤.១២ ការដាំដុះសណ្តែកសៀងនៅបីខេត្ត (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ខេត្តចំនួនបីដែលបានដាំសណ្តែកសៀងច្រើនជាងគេគឺខេត្តបាត់ដំបង (៩.០០០ ហត) រតនគិរី (៥.០០០ ហត) និងខេត្តព្រះវិហារ (៣.០០០ ហត) ។

## គ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ

គ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ បានចាត់ថ្នាក់ជាដំណាំរដូវរយៈពេលខ្លី មានផ្ទៃដីដាំដុះដំណាំសរុបចំនួន ១៨.០០០ហិកតា ផ្ទៃដីដាំដុះគ្រឿងក្រអូប (ម្ទម) សរុបចំនួន ១០.០០០ហិកតា ផ្ទៃដីដាំដុះដំណាំស្លឹកគ្រៃចំនួន ៤.០០០ហិកតា។ ជាមួយនោះខេត្តព្រៃវែងមានផ្ទៃដីធំនៃផ្ទៃដីចំនួន ៥.០០០ហិកតា ក្នុងនោះ ខេត្តបន្ទាយមានជ័យមានផ្ទៃដីសរុបចំនួន ៣.០០០ហិកតា។ ចំពោះខេត្តបាត់ដំបងនិងខេត្តប្រាំបួនផ្សេងទៀត មានផ្ទៃដីចំនួននៃការដាំដំណាំស្លឹកគ្រៃមានភាពប្រហាក់ប្រហែលយ៉ាងហោចណាស់ ១០០ហិកតា។ ការប្រមូលផលនៃគ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថមានផ្ទៃដីចំនួន ១០.០០០ហិកតា នឹងផ្ទៃដីមានប្រព័ន្ធស្រោចស្រពចំនួន ៨.០០០ហិកតាសម្រាប់ការដាំដុះ។

ផ្ទៃដីដាំដុះម្ទមបានរាយការណ៍ បានដាំដុះច្រើនជាង៤.៥០០ហិកតា និងស្មើតែ ៣៥០០ហិកតា នៅក្នុងខេត្តបន្ទាយមានជ័យ។ ខេត្តបាត់ដំបងបាននាំមុខខេត្តផ្សេងទៀតដែលបានដាំដុះស្លឹកគ្រៃ៩០០ហិកតា។

ក្រាហ្វិក៤.១៣ ផ្ទៃដីដាំដុះម្ទមមានច្រើននៅបីខេត្ត (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ក្រាហ្វិក៤.១៣ក ផ្ទៃដីដាំដុះស្លឹកគ្រៃមានច្រើននៅបីខេត្ត (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ផ្ទៃដីប្រមូលផលនៃដំណាំគ្រឿងទេស គ្រឿងក្រអូម និងរុក្ខជាតិឱសថ បានប្រមូលផលប្រមាណ ១០.០០០ហិកតា ហើយ ៥៣ភាគរយ នៃផ្ទៃដីប្រមូលផលដំណាំម្ទេស និងប្រមាណ ២៣ភាគរយ នៃផ្ទៃដីប្រមូលផលដំណាំ ស្លឹកគ្រៃ។

ផ្ទៃដីសរុបនៃក្បាលដីដាំដុះដំណាំគ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថផ្ទៃដីអាចទទួលបានការ ស្រោចស្រពចំនួន៨.០០០ហិកតា។ ចំពោះក្បាលដីដាំដុះដំណាំម្ទេសផ្ទៃដីស្រោចស្រពបានចំនួន ៥.០០០ហិកតា ផ្ទៃដីដំណាំស្លឹកគ្រៃចំនួន ៩២៦ហិកតា ទទួលបានការស្រោចស្រព។

## ដំណាំឧស្សាហកម្ម

ដំណាំអំពៅនិងថ្នាំជក់ ជាដំណាំអនុវត្តបានរាយការណ៍ ដោយគ្រួសារកាន់កាប់កសិកម្មមានផ្ទៃដីប្រមាណ ជាង ៧.០០០ហិកតា ក្នុងនោះផ្ទៃដីដាំអំពៅប្រមាណជាង៥០ភាគរយ នៃផ្ទៃដីសរុប (៣.១០៣ហិកតា បានដាំ នៅលើក្បាលដីប្រមាណ ៧.០០០ក្បាលដី)។ ដោយឡែកផ្ទៃដីថ្នាំជក់មានចំនួន ៣.០០០ហិកតា ផ្ទៃដី ប្រមាណ ៤.០០០ហិកតា នៃផ្ទៃដីដាំដុះដំណាំឧស្សាហកម្ម បានស្រោចស្រព និងបរិមាណនៃដីដែលបានប្រមូលផល។ អំពៅជាដំណាំឧស្សាហកម្មជាចម្បងនៅក្នុងខេត្តកណ្ដាល (៨៥៤ហិកតា និងថ្នាំជក់មាននៅក្នុង ខេត្តកំពង់ចាម ត្បូងឃ្មុំ និងខេត្តក្រចេះ)។

ផ្ទៃដីប្រមូលផលដំណាំឧស្សាហកម្មកំពុងដាំដុះ/ប្រមូលផលផ្ទៃដីប្រមាណ ៤.០០០ហិកតា ដំណាំអំពៅប្រមាណស្មើនឹង ៦០ភាគរយ ដែលបានផលិតជាស្ករ និងផ្ទៃដីប្រមាណ ៣៦ភាគរយ ដែលបានផលិតថ្នាំជក់។ ក្បាលដីចំនួន ៤ពាន់ហិកតា ដែលកំពុងដាំដុះដំណាំឧស្សាហកម្ម ក្នុងនោះផ្ទៃដីចំនួន ១.៥៥៤ហិកតា នៃផ្ទៃដីដែលទទួលបានការស្រោចស្រពលើដំណាំអំពៅ និងផ្ទៃដីចំនួន ១.៨៣៥ហិកតា នៃដំណាំថ្នាំជក់។

ក្រាហ្វិក៤.១៤ ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល និងផ្ទៃដីស្រោចស្រពដំណាំអំពៅនិងថ្នាំជក់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ដំណាំបន្លែ

ដំណាំបន្លែជាដំណាំដែលបានដាំដុះនៅទូទាំងប្រទេសរួមមានទាំងស្លឹក ដើម ផ្លែ បន្លែយកមើម និងអម្បូរ បន្លែបៃតង ដែលមានផ្ទៃដីដាំដុះសរុបចំនួន ៣៥.០០០ហិកតា ដំណាំបន្លែយកស្លឹកនិងដើមប្រមាណជិត ៦.០០០ហិកតា។

ដំណាំត្រសក់មានផ្ទៃដីដាំដុះធំជាងគេមានប្រមាណ ៧.០០០ហិកតា (៣០ភាគរយនៃដំណាំ ដាំដុះនៅក្នុងខេត្តស្វាយរៀង) រីឯដាំណាំឪឡឹកដាំនៅលើផ្ទៃដី ៦.០០០ហិកតា ម្ទេស និងល្ពៅ ទាំងពីរប្រភេទនេះ ផ្ទៃដីចំនួន ៥.០០០ហិកតា។ ជាមួយនោះ ឪឡឹកបានដាំដុះនៅលើផ្ទៃដីចំនួន ៨០០ហិកតា នៅក្នុងខេត្តកំពង់ធំ ផ្ទៃដីចំនួន ៧២២ហិកតា នៅក្នុងខេត្តកំពង់ស្ពឺ និងផ្ទៃដីចំនួន ៦៧២ហិកតា នៅខេត្តបាត់ដំបង។ បន្លែត្រកួនជា ប្រភេទបន្លែក្នុងទឹកត្រូវបានគេស្គាល់ដំណាំក្នុងស្រុកមានផ្ទៃដីដាំដុះចំនួន ២.៣០៧ហិកតា និងផ្ទៃដីចំនួន ៥០ភាគរយ នៃដំណាំនេះដែលមានការដាំដុះស្ថិតនៅតំបន់វាលទំនាបជាពិសេសខេត្តស្វាយរៀង។

ក្រាហ្វិក៤.១៥ ដំណាំបន្លែ និងបន្លែផ្លែនៅកម្ពុជា (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ការដាំដំណាំមានលក្ខណៈបច្ចេកទេស និងដំណាំអចិន្ត្រៃយ៍

ការដាំដុះដំណាំអចិន្ត្រៃយ៍ (ជាដំណាំដាំលើសពីមួយឆ្នាំនៃវដ្តការរីកលូតលាស់) ដែលបានរួមបញ្ចូលរុក្ខជាតិដើមឈើ និងដើមឈើលម្អរ ដាំមានលក្ខណៈបច្ចេកទេស និងជាលក្ខណៈប្រព័ន្ធដូចជា ដំណាំ ឬរុក្ខជាតិ ដើមឈើ ឬរុក្ខជាតិដែលដាំមានភាពមិនទៀងទាត់មួយ តែការដាំដុះវាយក៏ចាត់ទុកជាចម្ការដែរ។ គួរកត់សម្គាល់ ដំណាំដែលបានចាត់ចំណាត់ថ្នាក់ទាំង១១ បានប្រើក្នុងការកំណត់ដំណាំអចិន្ត្រៃយ៍ផ្សេងគ្នានៅក្នុងប្រទេសកម្ពុជា។ ទោះបីយ៉ាងនេះក្តី ដំណាំអចិន្ត្រៃយ៍មានប្រភេទខ្លះទៀត មិនមានគ្រប់គ្រាន់នៅក្នុងប្រទេសឡើយ។ ដូច្នេះដំណាំអចិន្ត្រៃយ៍សំខាន់គឺមានទិន្នន័យដាំដុះដំណាំប្រភេទនេះ ក្នុងការធ្វើជំរឿនកសិកម្ម។

### *ពពួកផ្លែឈើ*

ផ្លែក្រូចត្រូវបានរកឃើញសម្បូរចំការនៅក្នុងប្រទេសកម្ពុជាពោលគឺ ពពួកក្រូចថ្លុង ក្រូចឆ្មារ និងក្រូចសើច ព្រមទាំងផ្លែឈើផ្សេងទៀតនៃអម្បូរក្រូចឆ្មារនេះ។ ជារួមតំបន់ដែលមានការដាំដុះនេះ ត្រូវបានរាយការណ៍ ផ្ទៃដីដាំផ្លែក្រូចចំនួន ២.៦០០ហិកតា ស្មើនឹង០,៧ភាគរយនៃផ្ទៃដីសរុបរបស់ក្បាលដីដើម្បីដំណាំអចិន្ត្រៃយ៍។ ក្នុងនេះ ក្រុមផ្លែក្រូច និងផ្លែឈើ ដែលបានដាំភាគច្រើនជាទូទៅ ក្រូចដាំក្នុងចម្ការ និងនៅតំបន់បឹងទន្លេសាប ជារួមតំបន់នេះ មិនសូវសម្បូរនិងផលផ្លែក្រូចនៅមានតិចដូចជា: ផ្ទៃដីក្រូចពោធិ៍សាត់ចំនួន១.១២៨ហិកតា ផ្ទៃដីក្រូចថ្លុងចំនួន ៥៩២ហិកតា ផ្ទៃដីក្រូចឆ្មារចំនួន ១៨៥ហិកតា (មានខេត្តចំនួន ៦ទៀតបានរាយការណ៍មានការកើនផ្ទៃដីក្រូចឆ្មារចំនួន ១០០ហិកតា ចំពោះខេត្តបាត់ដំបងវិញប្រមាណ ៥១ភាគរយ នៃផ្ទៃដីសរុបបានដាំផ្លែក្រូចជាចម្ការដំណាំធុនតូចនៅកម្ពុជា។ ជារួមខេត្តបាត់ដំបងត្រូវ

បានទទួលស្គាល់លើប្រភេទដំណាំក្រូច ជាពិសេសដំណាំក្រូចពោធិ៍សាត់ បានដាំជាចម្ការផ្ទៃដីសរុបចំនួន ៧៥៥ហិកតា និងផ្ទៃដីដាំក្រូចថ្លុងចំនួន ៥៥៩ហិកតា។

ផ្លែក្រូចមានចំនួន ៣៦ពូជ នៃផ្លែក្រូចសម្រាប់ការដាំដុះដែលមានផ្ទៃដីសរុបចំនួន ៨៣.០០០ហិកតានៅក្នុងប្រទេសកម្ពុជា។ ផ្ទៃដីដាំដុះដើមស្វាយសរុបចំនួន ៤២.០០០ហិកតា និងផ្ទៃដីចេកជារុក្ខជាតិមានចំណាត់ថ្នាក់ខ្ពស់ លំដាប់ទី២បន្ទាប់ពីក្រូចមានផ្ទៃដី ចំនួន ២៤.០០០ហិកតា។ ខេត្តកំពតមានផ្ទៃដីដាំដុះស្វាយចំនួន ៦.៣០០ហិកតា ហើយបន្ទាប់មកខេត្តកណ្តាលមានផ្ទៃដីចំនួន ៥.២៩៩ហិកតា ខេត្តកំពង់ស្ពឺផ្ទៃដីចំនួន ៤.២០០ហិកតា និងខេត្តកំពង់ចាមផ្ទៃដីសរុបចំនួន ៥.០០០ហិកតា។

ក្រាហ្វិក៤.១៦ ផ្ទៃដីដាំដុះដំណាំពពួកផ្លែក្រូច (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ក្នុងចំណោមដើមក្រូចពោធិ៍សាត់ នៃផ្ទៃដីដាំដុះច្រើននៅក្នុងតំបន់នេះ មានផ្ទៃដីចំនួន ១.៣២៥ហិកតា។ ជាមួយនោះ ដើមក្រូចថ្លុង/ក្រូចឆ្មារ បានដាំដុះលើផ្ទៃដីចំនួន ៦៨៧ហិកតា និងផ្ទៃដីក្រូចផ្សេងទៀតចំនួន ៤៧៣ហិកតា។ នៅតំបន់បឹងទន្លេ សាប ខេត្តមួយចំនួនមានការដាំដុះក្រូចទាំងបីប្រភេទផ្លែក្រូចដូចជា ក្រូចពោធិ៍សាត់ (៨៥ភាគរយ ឬ ចំនួន ១.១២៨ហិកតា) ក្រូចថ្លុង/ផ្លែក្រូចថ្លុង (៨៦ភាគរយ ឬ ចំនួន៥៩៣ហិកតា) និងក្រូចឆ្មារ (៣៩ភាគរយ ឬ ចំនួន ១៨៥ហិកតា)។

ក្នុងរបាយការណ៍នៃការដាំដុះក្នុង០៦ នៃខេត្តចំនួន២៥ មានការរីកចម្រើនដំណាំផ្លែក្រូច មានច្រើនប្រមាណជាង ១០០ហិកតា។ ក្នុងនោះខេត្តបាត់ដំបងមានការកើនឡើងដំណាំអចិន្ត្រៃយ៍ប្រមាណ ៥១ភាគរយនៃផ្ទៃដីដាំដុះក្រូចសរុបនៅទូទាំងប្រទេស។ ជាពិសេសនៅក្នុងតំបន់នេះ មានផលិតដំណាំដាំដុះ ផ្លែក្រូចផ្ទៃដីចំនួន ៧៥៥ហិកតា និងក្រូច/ផ្លែក្រូចថ្លុងផ្ទៃដីដាំចំនួន ៥៥៩ហិកតា។

ក្រាហ្វិក៤.១៧ ការដាំដុះទាំង៦ខេត្តច្រើនជាងគេពពួកដំណាំក្រូច (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

មានចំនួន ៣៦ពូជ នៃផ្លែក្រូចដែលបានដាំដុះមានលក្ខណៈបច្ចេកទេស លើផ្ទៃដីសរុបចំនួន ៨៣.០០០ហិកតា នៅទូទាំងប្រទេស មានផ្ទៃដីប្រមាណ ២៤ភាគរយ នៃផ្ទៃដីសរុបរបស់ក្បាលដីដែលបានប្រើប្រាស់ការដាំដុះដំណាំអចិន្ត្រៃយ៍។ ក្នុង ចំណោម ដំណាំផ្លែឈើដាំដុះទាំងនេះដូចជា ចេក ស្វាយ ខ្នុរ មៀន ទៀប ល្មុត ល្ហុង និងធូរ៉េន ការដាំដុះមានក្បាលដីជាង ១.០០០ហិកតា នៃក្បាលដី។ ដើមស្វាយមានផ្ទៃដីដាំដុះច្រើន សរុបចំនួន ៤២.០០០ហិកតា។ ដើមចេកមានចំណាត់ទីពីរក្នុងនោះផ្ទៃដីដាំដុះសរុបចំនួន ២៤.០០០ហិកតា។

ក្រាហ្វិក៤.១៨ ផ្ទៃដីដុះមានលក្ខណៈបច្ចេកទេសសម្រាប់ដំណាំឈើហូបផ្លែ (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤))

ខេត្តកំពតផ្ទៃដីសរុបចំនួន ៦.៣០០ហិកតា នៃដីសរុបក្នុងការអនុវត្តដាំដុះដំណាំស្វាយ ជាបន្ទាប់ខេត្តកណ្ដាលនិងខេត្តកំពង់ស្ពឺ មានផ្ទៃដីដាំដុះប្រហាក់ប្រហែលគ្នាចំនួន ៥.២០០ហិកតា និងផ្ទៃដីចំនួន ៤.២០០ហិកតាបានដំណាំដើមស្វាយ។

ក្រាហ្វិក៤.១៩ ផ្ទៃដីដាំដុះដំណាំដើមស្វាយមានលក្ខណៈបច្ចេកទេសតាមបណ្ដាខេត្ត (គិតជាហិកតា)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ក្នុងចំណោម៧ខេត្តនៃខេត្តទាំង២៥ របាយការណ៍មានការរីកចម្រើនដំណាំចេក យ៉ាងហោចណាស់ផ្ទៃដីដាំដុះចំនួន ១.០០០ហិកតា។ ក្នុងចំណោម៤ខេត្តនៃខេត្តទាំងនេះ មានដាំនៅក្នុងតំបន់វាលទំនាប។ ដូចជាខេត្តកំពង់ចាមជាមួយបណ្ដាខេត្តផ្សេងទៀត នៅក្នុងតំបន់នៃការដាំដុះមានផ្ទៃដីចំនួន ៥.០០០ហិកតា ជាដំណាំដើមចេក។

ក្រាហ្វិក៤.២០ ផ្ទៃដីដាំដុះដំណាំចេកមានលក្ខណៈបច្ចេកទេសតាមបណ្ដាខេត្តច្រើនជាងគេ (គិតជាហិកតា)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ដំណាំស្វាយចន្ទី

ស្វាយចន្ទីជាប្រភេទដំណាំអាចបរិភោគគ្រាប់ បានដែលមានផ្ទៃដីប្រមាណ១៧ភាគរយ (៦០.០០០ហិកតា) នៃក្បាលដីដាំដុះដំណាំអចិន្ត្រៃយ៍ ជាមួយនឹងការដាំដុះច្រើនជាងគេដូចជា ខេត្តរតនគិរីមានផ្ទៃដីសរុបចំនួន ១៨.០០០ហិកតា ខេត្តកំពង់ធំមានផ្ទៃដីសរុបចំនួន ១៤.០០០ហិកតា ខេត្តកំពង់ចាមផ្ទៃដីសរុបចំនួន ១០.០០០ហិកតា និងខេត្តក្រចេះផ្ទៃដីសរុបចំនួន ៨.០០០ហិកតា។ ដោយឡែកចំពោះខេត្ត ត្បូងឃ្មុំ ស្ទឹងត្រែង និងកោះកុង ក៏មានការដាំដុះដំណាំ ស្វាយចន្ទីជាដំណាំដែលមានសារៈសំខាន់នេះដែរ។

ក្រាហ្វិក៤.២១ ក្នុងចំណោម៧នៃបណ្តាខេត្តដាំស្វាយចន្ទីឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## ដំណាំយកប្រេង

ដំណាំយកប្រេងមានផ្ទៃដីសរុបចំនួន ១៤.៤៩១ហិកតា ស្មើនឹង៤ភាគរយនៃដីសរុបដែលប្រើសម្រាប់ដំណាំអចិន្ត្រៃយ៍ និងមានជាចម្បងដូចជា ដើមដូង ដើមត្នោត និងដើមដូងប្រេង។ ទន្និន័យជំរឿនបានសម្គាល់ថា រវាងដើមដូង និងដើមដូងប្រេងក៏ដូចជាពពួកដើមត្នោត ក្នុងគោលបំណងប្រើប្រាស់ជារួមសម្រាប់ការធ្វើស្ករ និងការកែច្នៃជាប្រេងឆា។ល។ ខេត្តស្វាយរៀងមានផ្ទៃដីស្មើនឹង ៤៤ភាគរយនៃដីសរុប ដែលប្រើប្រាស់សម្រាប់ដំណាំយកប្រេងក្នុងចម្ការនៅក្នុងប្រទេស ផ្ទៃដីដាំដុះដើមដូងសរុបចំនួន ២.៤០០ហិកតា ផ្ទៃដីដើមត្នោតសរុបចំនួន ២.២០០ហិកតា និងផ្ទៃដីដូងប្រេងមានផ្ទៃដីចំនួន ១.៨០០ហិកតា។

ក្រាហ្វិក៤.២២ ផ្ទៃដីដាំដុះដំណាំយកប្រេង (គិតជាហិកតា)




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ដំណាំគ្រឿងទេសនិងដំណាំក្រអូប

ចំពោះដំណាំអចិន្ត្រៃយ៍ ការដាំដុះដំណាំម្រេចខ្មៅមានប្រមាណ ៩០ភាគរយនៃផ្ទៃដីចំនួន ៦.៣០០ហិកតា ដំណាំគ្រឿងទេសនិងដំណាំក្រអូបនៅទូទាំងប្រទេសដូចជាខេត្ត ត្បូងឃ្មុំ ក្រចេះ និងកោះកុង ក្នុងចំណោមខេត្តទាំងបីនេះ បានដាំដុះដំណាំម្រេចខ្មៅច្រើនជាងគេ ក្នុងនោះ ខេត្តត្បូងឃ្មុំមានផ្ទៃដីដាំដុះម្រេចខ្មៅចំនួន ៥.២២៤ហិកតា ស្មើនឹង៩០ភាគរយនៃផ្ទៃដីសរុបដំណាំម្រេច។

ក្រាហ្វិក៤.២៣ ផ្ទៃដីដាំដុះម្រេចខ្មៅច្រើនជាងគេនៅបីខេត្ត




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ដំណាំកៅស៊ូ

ដំណាំកៅស៊ូមានចំនួនស្មើតែ ២៤ភាគរយនៃផ្ទៃដីសរុបដែលបានដាំដំណាំអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា។ ដោយសារដំណាំកៅស៊ូជាប្រភេទដំណាំមានតម្លៃជាងដំណាំផ្សេងៗទៀត កៅស៊ូត្រូវបានដាំដុះជាចម្បងក្នុងការដាំដុះប្រភេទដំណាំឧស្សាហកម្ម ថ្វីបើគ្រួសារកាន់កាប់កសិកម្មក៏បានចូលរួមដាំដុះដំណាំកៅស៊ូផងដែរ។

ខេត្តសំខាន់ៗដែលផលិតកៅស៊ូគឺ ខេត្តត្បូងឃ្មុំ (៤៦.០០០ ហិកតា) ខេត្តកំពង់ចាម (១៣.០០០ ហិកតា) ខេត្តក្រចេះ (១១.០០០ហិកតា ) និងខេត្តរតនគីរី (៥.៤០០ ហិកតា)។

ក្រាហ្វិក៤.២៤ ខេត្តដែលមានផ្ទៃដីដាំដុះដំណាំកៅស៊ូច្រើនជាងគេ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ដំណាំមិនមែនជាអាហារ

ឫស្សីគឺជាដំណាំមិនមែនជាអាហារមានផ្ទៃដីសរុបចំនួន ៣.១០០ហិកតា ប្រភេទដំណាំនេះ បានប្រើប្រាស់ជាច្រើនក្នុងគោលបំណងសម្រាប់ការសាងសង់ផ្ទះ ការចម្អិនអាហារ និងធ្វើជាគ្រឿងសង្ហារឹម ។ល។ ខេត្តដែលមានផ្ទៃដីដំណាំ ឬស្សីដូចជា ខេត្តស្វាយរៀងមានផ្ទៃដីក្នុងការដាំដុះប្រមាណ ៥៧ភាគរយ និងខេត្តត្បូងឃ្មុំ (១៧ ភាគរយ)។

## ដំណាំរាយប៉ាយ ដំណាំអចិន្ត្រៃយ៍

ជារួមដំណាំនេះ ចាត់ជាប្រភេទដំណាំអចិន្ត្រៃយ៍ដាំដុះក្នុងចម្ការតូចៗ នៅរាយប៉ាយជាមួយការដាំដុះនៅទូទាំងប្រទេសផងដែរ។ ប្រភេទដំណាំទាំងនេះ រួមបញ្ចូលទាំងដំណាំលម្អនិងដើមឈើ ដែលមានដាំក្បែង/ជុំវិញផ្ទះ ឬនៅលើដីកសិកម្មដោយឡែកពីគ្នា ហើយបានផ្តល់ប្រយោជន៍ដល់សេដ្ឋកិច្ចគ្រួសារកសិកម្មដែលក្រីក្រ ជាពិសេសអាចប្រើប្រាស់ជាអាហារផ្ទាល់ខ្លួន នឹងការបង្កើតចំណូលរបស់គ្រួសារកសិករ។ ទោះបីជាតំបន់ដី មានការដាំដុះដំណាំរាយគ្នាមិនអាចរាប់បានត្រឹមត្រូវក៏ដោយ ក៏អាចកំណត់បាននូវការព្យាករណ៍ នៃដីអាចដាំដើមឈើមានចំនួន ៣០០.០០០ដើមឈើ រីឯដីដាំដំណាំក្រូចរាយប៉ាយចំនួន ១៣៣.០០០ដើម ចំណែកដីដាំក្រូចឆ្មារនិង ដំណាំក្រូចថ្លុងនមានចំនួន ១១០.០០០ដើម ក្រូចសើចមានចំនួន ១៤.០០០ដើម និងដាំណាំផ្សេងៗទៀតមានចំនួន ៦.០០០ដើម។ បើគិតជាមធ្យមនៃចំនួនដើមក្រូចគឺមាន២០ដើមក្នុងក្បាលដី និងមានការដាំដុះច្រើននៅខេត្តឧត្តរមានជ័យ ដែលមានដាំដើមក្រូចចំនួន៦២ដើមក្នុងក្បាលដី។ ចំពោះខេត្តផ្សេងទៀត គិតជាមធ្យមនៃការដាំដុះក្នុងខេត្តកោះកុងចំនួន៤២ដើមក្នុងក្បាលដី ខេត្តពោធិ៍សាត់ចំនួន៣៥ដើមក្នុងក្បាលដី ខេត្តបាត់ដំបងមានចំនួន២៨ដើមក្នុងក្បាលដី និងខេត្តប៉ៃលិនមានចំនួន២១ដើមក្នុងក្បាលដី។ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ឈើហូបផ្លែដែលមាននៅប្រទេសកម្ពុជា ដូចជាដំណាំចេកបានដាំរាយប៉ាយមានប្រមាណ១០លានដើម ដើមស្វាយចំនួន៨លានដើម ដំណាំម្នាស់មានចំនួន៥លានដើម ដំណាំទៀបមានចំនួន២លានដើម និងដើមខ្នុរមានចំនួន២លានដើម។

ប្រភេទដំណាំអាចបរិភោគគ្រាប់បាន រួមមានប្រមាណ ៣លានដើម នៃដំណាំស្វាយចន្ទី ក្រអៅឈូកមានចំនួន ២លានដើម និងមានដើមស្លាចំនួន ២៨២ដើម។ ដំណាំយកប្រេងដាំដុះបានចំនួន៤៥លានដើម ជាពិសេសនៅក្នុងខេត្តកំពតនិងកំពង់ធំ ក្នុងនោះ ដើមត្នោតមានចំនួន ៨០០.០០០ដើមត្នោត និងដូងប្រេងមានចំនួន ៥០០.០០០ដើម។ ដំណាំគ្រឿងទេសនិងដំណាំក្រអូបមានដាំរាយប៉ាយដូចជា ដើមអំពិលចំនួន ៩៧.០០០ដើម ម្រេចខ្មៅមានចំនួន ៦១.០០០គុម្ព និងដើមឈើហូបផ្លែមានចំនួន ១៥.០០០ដើម។ ដើមកៅស៊ូដាំរាយប៉ាយមានចំនួនសរុប ១,៩លានដើម ដែលស្ថិតនៅក្នុងខេត្តមួយចំនួនដូចជាខេត្ត ត្បូងឃ្មុំ កំពង់ធំ កំពត ក្រចេះ មណ្ឌលគិរី ព្រះសីហនុ និងស្ទឹងត្រែង។

ក្រាហ្វិក៤.២៥ ចំនួនដំណាំឈើហូបផ្លែ រាយប៉ាយនៅក្នុងប្រទេសកម្ពុជា




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ដំណាំដើមក្រូចបានដាំដុះមានភាពរាយប៉ាយ បើគិតជាមធ្យមដែលបានកត់ត្រាក្នុងការធ្វើជំរឿនកសិកម្មនៃប្រទេសកម្ពុជាគឺចំនួន ២០ដើម ក្នុងក្បាលដី។ បណ្តាខេត្តចំនួនប្រាំដែលមានការដាំដុះដើមក្រូចគិតមធ្យមថ្នាក់ជាតិ គួរកត់សម្គាល់ថា ចំនួនមធ្យមខ្ពស់បំផុតនៃដើមឈើបានដាំដុះក្នុងក្បាលដីមានដូចជាខេត្ត ឧត្តរមានជ័យចំនួន ៦២ដើម បន្ទាប់មកខេត្តកោះកុង (៤២ដើមក្នុងក្បាលដី) ខេត្តពោធិ៍សាត់ (៣៥ដើមក្នុងក្បាលដី) ខេត្តបាត់ដំបង(២៨ដើមក្នុងក្បាលដី) និងខេត្តប៉ៃលិន( ២១ដើម ក្នុងក្បាលដី)។ កត់សម្គាល់ដែរថា ចំនួនគ្រួសារកាន់កាប់ដីកសិកម្មនៅតំបន់ដីដំណាំរាយប៉ាយគិតជាមធ្យមខ្ពស់ជាង ចំនួននៃការដាំរាយប៉ាយដំណាំដើមក្រូចដែលអាចធ្វើបាន។

មានចំនួន ៣៨ប្រភេទផ្សេងគ្នា ដែលបាដាំដុះជាក់លាក់លើដាំនឈើហូបផ្លែ ត្រូវបានកត់ត្រានៅក្នុងការធ្វើជំរឿនកសិកម្មនេះ។ ក្នុងចំណោមទាំង ១០លានដើមចេក ត្រូវបានដំណាំដើមចេកនៅគ្រប់ខេត្តទូទាំងប្រទេស ប៉ុន្តែការដាំដុះមានការកើនឡើងនៅក្នុងតំបន់ភូនភ្ន/ភ្នំ នៅក្នុងគុម្ពដោយមានពី ៣-៥ដើមក្នុងគុម្ព។ ប្រសិនបើដើមចេកដាំដុះបានចំនួន ១០លានដើមក្នុងតំបន់ភ្នំ អាចស្មើនឹងពី ២-៣លានគុម្ពចេក។

ដើមស្វាយបានដាំរាយប៉ាយនៅក្នុងប្រទេស ចំនួនសរុបប្រមាណជិត ៨លានដើម ដោយគិតជាមធ្យមមាន ១៦ដើម ក្នុងមួយក្បាលដី។ ដំណាំអចិន្ត្រៃយ៍មាននៅរាយប៉ាយផ្សេងៗទៀត មានរាប់លានដើមដូចជា ដំណាំម្នាស់ចំនួន ៥លានគុម្ព ដើមទៀបមានចំនួន ២លានដើម និងដើមខ្នុរចំនួន ២លានដើម។

ដំណាំម្នាស់បានចំណាត់ថ្នាក់ជាដំណាំអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា ទោះបីនៅក្នុងប្រទេសអាស៊ីផ្សេងទៀត ក៏បានចាត់ទុកដំណាំនេះជាប្រភេទដំណាំអចិន្ត្រៃយ៍។ ដំណាំម្នាស់កើនឡើងនៅក្នុងតំបន់ខ្ពង់រាប "ភ្នំ" ក៏ដូចជាដំណាំចេកដែរ។ ដូច្នេះតំបន់ខ្ពង់រាប/ភ្នំគិតជាមធ្យមនៃដើមម្នាស់មានចំនួនពី ៥ដើមម្នាស់ ហើយមាន ៤លានដើមម្នាស់ ដែលមានរាយប៉ាយគ្នា តែនៅតំបន់ភ្នំមានចំនួន ១លានដើម។

ដំណាំស្វាយចន្ទីជាដំណាំអាចយកគ្រាប់មកបរិភោគបាន និងមានសារៈសំខាន់បំផុតនៅក្នុងប្រទេស យោងតាមរបាយការណ៍ការដាំដុះនៅរាយប៉ាយមានប្រមាណ ៣លានដើម។ ហើយដាំនៅរាយប៉ាទូវដំណាំប្រភេទនេះ ដែលអាចបរិភោគគ្រប់បាន រួមបញ្ចូលទាំងក្រអៅឈូកមានប្រមាណ ២លានគុម្ព និងដំណាំដើមម្លូ (២៨២ពាន់ដើម)។

ក្រាហ្វិក៤.២៦ ប្រភេទដំណាំដើមឈើអាចហូបគ្រាប់/ដើម ក្នុងប្រទេសកម្ពុជា




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ដំណាំយកប្រេងបានដាំរាយប៉ាយមានច្រើនចំនួន ៤,៥លានដើម ឬដើមឈើនៅរាយប៉ាយមានប្រមាណ ១៤ដើមក្នុងមួយក្បាលដី ឬចំនួន ៨០០ពាន់ដើម ឬចំនួន (១០ដើមក្នុងក្បាលដី) និងដូងប្រេងប្រមាណ ៥០០ពាន់ដើម ឬចំនួន (៣៣២ដើមក្នុងក្បាល)។ ដំណាំដូងបានដាំរាយប៉ាយយោងតាមរបាយការណ៍ ខេត្តកំពតការដាំដុះច្រើនជាងគេមានចំនួន (៩៤០.០០០ដើម )បន្ទាប់មកខេត្តកំពង់ធំមានប្រមាណជាង (៥០០ពាន់ដើម)។

ក្រាហ្វិក៤.២៧ ការដាំដុះដំណាំដូងតាមបណ្តាខេត្ត




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

គ្រួសារកាន់កាប់ដីកសិកម្ម បានដាំដុះដំណាំអំពិលចំនួនប្រមាណ ៩៧ពាន់ដើម ការដាំដុះដំណាំម្រេចខ្មៅចំនួន ៦១ពាន់ដើម ក្រសាំងបានចំនួន ១៥ពាន់ដើម ដាំរាយប៉ាយយោងតាមរបាយការណ៍ និងដំណាំគ្រឿងទេសនិងគ្រឿងក្រអូប។ ខេត្តតាកែវមាន២០ភាគរយនៃដើមអំពិលដែលបានដាំរាយប៉ាយសរុប ខណៈខេត្តត្បូងឃ្មុំមានចំនួនច្រើនជាង ៣០ភាគរយនៃដំណាំម្រេចខ្មៅដែលបានដាំរាយប៉ាយ។

ដើមកៅស៊ូដាំរាយប៉ាយសរុបជាទូទៅចំនួន ១,៩លាន ឬគិតជាមធ្យមនៃការដាំដុះកៅស៊ូចំនួន ៤៥ដើមក្នុងក្បាលដីដំណាំកៅស៊ូ។ ជាមួយនោះ ដំណាំកៅស៊ូជាច្រើនមានដាំរាយប៉ាយ យោងតាមរបាយការណ៍នៅតាមបណ្តាខេត្តមួយចំនួនដូចជាខេត្ត ត្បូងឃ្មុំ កំពង់ធំ កំពត ក្រចេះ មណ្ឌលគិរី ព្រះសីហនុ និងស្ទឹងត្រែង។

## សម្ភារៈកសិកម្មនិងសេវាកម្ម

### ឧបករណ៍និងគ្រឿងម៉ាស៊ីន

ប្រទេសកម្ពុជាគ្រួសារកសិកម្ម ដោយប្រកបការងារកសិកម្មនៅតាមបែបប្រពៃណីនៅឡើយ ជាមួយនឹងការប្រើប្រាស់សម្ភារៈបរិក្ខាកសិកម្មជាចម្បងដូចជា ចបកាប់ កណ្តៀវ នង្គ័ល រនាស់ និងរទេះបែបបូរាណជាដើម។ លើសពីនេះទៀត ឧបករណ៍ធុនធ្ងន់និងសម័យទំនើប គ្រួសារកសិកម្មបានប្រើប្រាស់ជាច្រើនរួមមាន ចំនួនគ្រួសារប្រើប្រាស់ម៉ាស៊ីនច្រូតស្រូវចំនួន ៤៤០.០០០គ្រួសារ គ្រួសារប្រើប្រាស់ម៉ាស៊ីនបោកស្រូវចំនួន ៥៥០.០០០គ្រួសារ គ្រួសារប្រើប្រាស់ម៉ាស៊ីនបូមទឹកចំនួន ៤២០.០០០គ្រួសារ គ្រួសារប្រើប្រាស់គោយន្តចំនួន ៦៥០.០០០គ្រួសារ គ្រួសារប្រើប្រាស់ត្រាក់ទ័រចំនួន ១១៦.០០០គ្រួសារ គ្រួសារប្រើប្រាស់ម៉ាស៊ីនកិនស្រូវចំនួន ២៧០.០០០គ្រួសារ (ត្រូវបានប្រើបន្ទាប់ពីការប្រមូលផល) និង

រថយន្ត/ម៉ូតូ/កង់ជាមធ្យោបាយសម្រាប់ការដឹកជញ្ជូនចំនួន ៧០០.០០០គ្រួសារ។ ក្នុងចំណោមអ្នកដែលប្រើប្រាស់គ្រឿងម៉ាស៊ីននិងឧបករណ៍ គ្រួសារកសិកម្មជាម្ចាស់រថយន្តម៉ូតូនិងកង់ ឬក៏មិនមែនជារបស់ផ្ទាល់ខ្លួនក៏ដោយ ក៏មួយចំនួនធំនៃឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីន ដោយបានជួលពីវិស័យឯកជនដើម្បីធ្វើកសិកម្មក្នុងគ្រួសារ ហើយភាគច្រើនម៉ាស៊ីនបូមទឹកគ្រប់គ្រងដោយផ្ទាល់របស់កសិករ។ ចំពោះត្រាក់ទ័រ ម៉ាស៊ីនច្រូតកាត់ ម៉ាស៊ីនបោកស្រូវ និងគោយន្ត បានជួលភាគច្រើនពីឯកជន និងមួយចំនួនតូចនៃឧបករណ៍និងគ្រឿងម៉ាស៊ីន អាចប្រើប្រាស់បានដោយសារការខ្ចីពីរដ្ឋាភិបាល។

## ក្រាហ្វិក៤.២៨ ចំនួនគ្រួសារប្រើប្រាស់ឧបករណ៍/ម្ចាស់គ្រឿងម៉ាស៊ីន/ការខ្ចី/ជួល




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ក្រាហ្វិក៤.២៩ ភាគរយនៃការប្រើប្រាស់ម៉ាស៊ីននិងឧបករណ៍ផ្ទាល់ខ្លួន កាតជួលពីឯកជន និងការខ្ចីពីរដ្ឋាបាល




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

គ្រួសារកាន់កាប់សិកម្មនេះ ជាមួយនឹងនិន្នាការប្រើប្រាស់ឧបករណ៍សម្ភារកសិកម្មបុរាណក្នុងការដាំដុះ និងការប្រមូលផលដំណាំ មានដំណើរការសមស្របជាមួយការការប្រើឧបករណ៍បែបនេះ។ ចបកាប់ប្រើប្រាស់ប្រមាណជាង ១,៥លានគ្រួសារ កណ្ដៀវប្រើប្រាស់ចំនួន ១,៣លានគ្រួសារ នង្គ័លប្រើប្រាស់ចំនួន ០,៧លានគ្រួសារ រនាស់ប្រើប្រាស់

ចំនួន ០,៧លានគ្រួសារ ម៉ាស៊ីនភ្ជួររាស់ប្រើប្រាស់ចំនួន ០,៥លានគ្រួសារ រនាស់ដៃប្រើប្រាស់ចំនួន ០,២លាន និងរទេះគោប្រើប្រាស់ចំនួន ០,៣លានគ្រួសារ ដើម្បីប្រើប្រាស់ក្នុងសកម្មភាពកសិកម្ម។

### ***ការប្រើប្រាស់ជីនិងសារធាតុគីមី***

ការប្រើទាំងជីគីមីនិងជីសរីរាង្គមានកម្រិតខ្ពស់នៅប្រទេសកម្ពុជា មានប្រមាណ ៧០ភាគរយនៃគ្រួសារកសិកម្មយោងរបាយការណ៍ ការប្រើប្រាស់ជីគីមីនេះ (សេណេទិច) និងមានប្រមាណជាង ៥០ភាគរយចូលចិត្តប្រើប្រាស់ជីសរីរាង្គដែលបានមកពីលាមកសត្វនិងកាកសំណល់រុក្ខជាតិ។ ប្រមាណជាង ៣០ភាគរយនៃគ្រួសារសរុប ដែលបានប្រើសារធាតុគីមីបន្ថែម រួមទាំងថ្នាំសម្លាប់សត្វល្អិតនិងថ្នាំសម្លាប់ស្មៅ។ ប្រមាណជាង ៩ភាគរយនៃគ្រួសារកសិកម្ម បានប្រើថ្នាំសម្លាប់សត្វល្អិតឬសម្លាប់ស្មៅ រួមទាំងការប្រើប្រាស់ថ្នាំបំបាត់ជំងឺផ្សិតផងដែរ។ ការប្រើជីគីមីកម្រិតទាបបំផុតនៅក្នុងតំបន់ខ្ពង់រាបនិងជួរភ្នំ បើធៀបទៅនឹងតំបន់ផ្សេងទៀត។ បើគិតជាភាគរយកម្រិតខ្ពស់បំផុតនៃគ្រួសារប្រើប្រាស់ជីសរីរាង្គច្រើន នៅតំបន់ឆ្នេរសមុទ្រ មានប្រមាណ ៦១ភាគរយ និងមានភាគរយទាបជាងគេបំផុតនៅក្នុងតំបន់បឹងទន្លេប្រមាណជិត ៤៤ភាគរយ។ ភាគរយខ្ពស់បំផុតនៅតំបន់វាលទំនាប ដែលមានគ្រួសារប្រើប្រាស់គ្រប់ប្រភេទជីគីមី ថ្នាំសម្លាប់ស្មៅ ថ្នាំសម្លាប់សត្វល្អិតនិងសម្លាប់ផ្សិត។ នៅតាម បណ្តាខេត្តនៃតំបន់ឆ្នេរសមុទ្រ មានភាគរយទាបបំផុតនៃគ្រួសាដែលបានប្រើសារធាតុគីមីលើដំណាំ។ ខេត្តព្រៃវែងមានរបាយការណ៍ពីចំនួនគ្រួសារបានប្រើប្រាស់ជីទាំងពីរនិងសរីរាង្គលើដំណាំខ្ពស់បំផុតនៃ។ ខេត្តតាកែវជាប់ចំណាត់ថ្នាក់ទីពីរ និងទីបីខេត្តកំពង់ចាម ជាខេត្តដែលបានប្រើប្រាស់ជីគីមីខ្ពស់បំផុត បន្ទាប់មកខេត្តកំពង់ស្ពឺនិងកំពត។ រីឯខេត្តស្ទឹងត្រែងចំនួនគ្រួសារ បានប្រើជីមានកម្រិតទាបប្រមាណតិចជាង ១.០០០ នៃការប្រើប្រាស់ជីប្រភេទផ្សេងៗសម្រាប់ដំណាំ។

ក្រាហ្វិក៤.៣០ ចំនួនគ្រួសារកសិកម្មប្រើប្រាស់ជីគីមី ជីសរីរាង្គ និងថ្នាំកសិកម្មផ្សេងៗលើដំណាំតាមតំបន់




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ក្រាហ្វិក៤.៣១ ចំនួននៃគ្រួសារប្រើប្រាស់ជីគីមី ជីសរីរាង្គ និងថ្នាំកសិកម្មផ្សេងៗ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ក្រាហ្វិក៤.៣២ ភាគរយនៃប្រើប្រាស់ជីគីមី ជីសរីរាង្គ និងថ្នាំកសិកម្មផ្សេងៗ នៃគ្រួសារតាមបណ្តាខេត្ត




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ជាទូទៅយោងរបាយការន៍នៃគ្រួសារកសិកម្ម ដែលពេញនិយមប្រើប្រាស់ជីគីមីនិងជីសរីរាង្គនេះ រួមមាន ខេត្តព្រៃវែងមានចំនួនខ្ពស់ជាងគេបំផុត ឬភាគរយនៃគ្រួសារដាំដំណាំបានប្រើប្រាស់ជីទាំងពីរប្រភេទលើដំណាំដើម្បីឱ្យដំណាំមានការរីកលូតលាស់។ បន្ទាប់មកខេត្តតាកែវមានចំណាត់ថ្នាក់ទីពីរនៃគ្រួសារដាំដំណាំ ដែលបានប្រើប្រាស់ជីទាំងពីរប្រភេទនេះ។ ជាមួយនោះខេត្តកំពង់ស្ពឺមានចំណាត់ថ្នាក់ទីបី ដែលភាគរយនៃគ្រួសារប្រើប្រាស់សរីរាង្គប្រើនជាងជីគីមីមានកម្រិតខ្ពស់សមល្មម និងខេត្តស្ទឹងត្រែងយោងរបាយការណ៍ ចំនួនគ្រួសារដែលបានប្រើប្រាស់ជីលើដំណាំមានកម្រិតទាបបំផុត។

## គ្រាប់ពូជស្រូវ

នៅគ្រប់តំបន់ទូទាំងប្រទេស គ្រួសារកសិកម្មបានជ្រើសរើសប្រើប្រាស់ទាំងពីរគឺពូជសុទ្ធក្នុងស្រុកមានទិន្នផលខ្ពស់ និងពូជស្រូវគុណភាពល្អ។ នៅកម្រិតថ្នាក់ជាតិ ១.៥លានគ្រួសារ បានប្រើពូជស្រូវក្នុងស្រុកចំនួន ៤៥៤.០០០គ្រួសារ ជាមួយនឹងការប្រើប្រាស់ពូជប្រភេទផ្តល់ទិន្នផលខ្ពស់នៃគ្រាប់ស្រូវល្អតាមតំបន់។ ជាទូទៅគាតច្រើននៃគ្រួសារប្រកបរបបដាំដុះដំណាំស្រូវនៃគ្រួសារកសិកម្ម បានប្រើពូជស្រូវក្នុងស្រុកដែលផ្តល់ទិន្នផលខ្ពស់ ដូចដែលបានធ្វើអង្កេតនៅតាមតំបន់ទូទាំងប្រទេស។ ចំនួនជាច្រើននៃគ្រួសារកសិកម្មយោងតាមរបារកាណ៍ គ្រួសារបានប្រើគ្រាប់ពូជស្រូវរបស់ខ្លួនមានប្រមាណជាង ១,៥លានគ្រួសារ ដែលបានរក្សាទុកដាក់ដោយខ្លួនឯង មានច្រើនជាងគ្រួសារដែលបានទិញគ្រាប់ពូជស្រូវពីទីផ្សារឬពីអ្នកផលិតផ្សេងទៀតប្រមាណ ០,៥លានគ្រួសារ។

ក្រាហ្វិក៤.៣៣ ចំនួនគ្រួសារប្រើប្រាស់ពូជស្រូវក្នុងស្រុកមានទិន្នផលខ្ពស់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ភាគច្រើននៃគ្រួសារកសិកម្ម ជាមួយការដាំដុះដំណាំផលិតកម្មកសិកម្មនិងការប្រើប្រាស់គ្រាប់ពូជស្រូវរបស់ខ្លួនផ្ទាល់។ យោងរបាយការណ៍អត្រាខ្ពស់បំផុតនៃប្រជាកសិករមានប្រមាណជា៧០ភាគរយនៃគ្រួសារកសិកម្ម បានរប្រើគ្រាប់

ពូជស្រូវដោយខ្លួនឯង នៅប្រទេសកម្ពុជា ជាមួយនឹងអាត្រាមានច្រើនដូចជា នៅតំបន់ឆ្នេរសមុទ្រ តំបន់ខ្ពង់រាបនិងជួរភ្នំ មានប្រមាណពី៨០ភាគរយដល់៨៥ភាគរយ។

### ក្រាហ្វិក៤.៣៤ ចំនួនគ្រួសារកសិកម្មមានធនធានពូជស្រូវពីប្រភពផ្សេងៗ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

### ក្រាហ្វិក៤.៣៥ ភាគរយនៃគ្រួសារកសិកម្មប្រើប្រាស់ធនធានពូជស្រូវតាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

### សេវាផ្សព្វផ្សាយកសិកម្ម

គួរកត់សម្គាល់រួមមានបួនក្រុមដូចជា រដ្ឋាភិបាល ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល និងសមាគមន៍ក្នុងស្រុកបានផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដល់គ្រួសារកសិកម្មក្នុងការលើកកម្ពស់ផលិតភាព ការបង្កើនសន្តិសុខស្បៀង ការកែលម្អជីវភាពរស់នៅតាមជនបទ និងការលើកកម្ពស់វិស័យកសិកម្មជាមធ្យោបាយនៃកំណើនសេដ្ឋកិច្ច។ ជាមួយនោះ គ្រួសារកសិកម្មអាចប្រើប្រាស់សេវាកម្មផ្នែកនេះបន្ថែម ដោយមានការគាំទ្រពីរដ្ឋាភិបាល។

ក្រាហ្វិក៤.៣៦ ចំនួនគ្រួសារកសិកម្មទទួលបានសេវាផ្សព្វផ្សាយកសិកម្មតាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

ក្រាហ្វិក៤.៣៧ ភាគរយនៃគ្រួសារកសិកម្មទទួលបានប្រភពសេវាផ្សព្វផ្សាយខុសគ្នាតាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

នៅកម្រិតថ្នាក់ជាតិមានចំនួនប្រមាណ៣០ភាគរយនៃគ្រួសារ ដែលបានការប្រើសេវាផ្តល់បន្ថែមដោយរដ្ឋាភិបាល។ ហើយមានប្រមាណ១៣ភាគរយនៃគ្រួសារកសិកម្ម ជាមួយការប្រើប្រាស់របស់ក្រុមហ៊ុនឯកជន ដែលជាប្រភពនៃការផ្តល់សេវាផ្នែកនេះបន្ថែម ជាមួយគ្នានោះដែរ ក៏មានមួយភាគតូចដែលបានចូលដំណើរការសេវាផ្នែកបន្ថែមពីអង្គការក្រៅរដ្ឋាភិបាល (NGOs)។

ក្រាហ្វិក៤.៣៨ ភាគរយនៃគ្រួសារកសិកម្មទទួលបានប្រភពសេវាផ្សព្វផ្សាយបន្ថែមពីប្រភពផ្សេងគ្នាតាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

## ការប្រើប្រាស់ឥណទាន

ប្រមាណតិចជាង៥០ភាគរយនៃគ្រួសារកសិកម្ម ដែលបានប្រើប្រាក់កម្ចីនិងឥណទានពីប្រភពផ្សេងៗដែលភាគច្រើនដោយសារតែសេវាបែបនេះ ត្រូវបានគេមិនអាចប្រើនៅក្នុងតំបន់របស់ខ្លួន ឬបើសិនជាមានគ្រួសារក្នុងវិស័យកសិកម្មមិនអាចរកបានរបស់ពួកគេ។ ធនាគារជាប្រភពធនធាន អាចផ្តល់ប្រាក់កម្ចី និងការផ្តល់សេវាឥណទាន។

ជាមួយនឹងគ្រួសារកសិកម្ម របាយការណ៍បានបញ្ជាក់ថា ប្រភពផ្សេងគ្នានៃការផ្តល់ឥណទាន/ប្រាក់កម្ចី ដែលបានប្រើប្រាស់ដើម្បីទិញវត្ថុធាតុដើមសម្រាប់ការដាំដុះដំណាំ។ មានប្រមាណ ៣១ភាគរយ នៃគ្រួសារកសិកម្ម ដែលបានទទួលនូវធនធានឥណទានពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម។ ចំនួនប្រមាណ ២១ភាគរយ នៃគ្រួសារដែលពឹងផ្អែកលើមិត្តភក្តិនិងសាច់ញាតិរបស់ខ្លួនក្នុងការខ្ចីលុយ ជាមួយគ្នានោះដែរមានមួយក្នុងចំណោមប្រាំនៃគ្រួសារដែលបានចូលដំណើរការប្រាក់កម្ចីពីធនាគារ។

### ក្រាហ្វិក៤.៣៩ គ្រួសារកសិកម្មជាមួយប្រភពប្រើប្រាស់ប្រភពនៃឥណទាន




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

សមាមាត្រនៃគ្រួសារកសិកម្មដែលទទួលបានប្រាក់កម្ចី/ឥណទាន ស្ថិតនៅក្នុងតំបន់វាលទំនាបនិងតំបន់បឹងទន្លេសាបគឺខ្ពស់ជាង បើធៀបទៅនឹងតំបន់ផ្សេងទៀត។ ប្រភពសំខាន់នៃមីក្រូ-ហិរញ្ញវត្ថុគឺ ឥណទាន/ប្រាក់កម្ចី មានសម្រាប់គ្រួសារនៅក្នុងទាំងពីរតំបន់។ ប្រភពបន្ទាប់នៃឥណទាន/ប្រាក់កម្ចី ជាគ្រួសារនៅក្នុងតំបន់ទាំងអស់ ដែលបានប្រើប្រាស់កម្ចីពីមិត្តភក្តិ/សាច់ញាតិនិងធនាគារ។ ទោះជាយ៉ាងណាក្តី ដែលជាជម្រើសសម្រាប់គ្រួសារនៅតំបន់បឹងទន្លេសាប ទទួលបានឥណទាន/ប្រាក់កម្ចី ការរកស៊ីចងការប្រាក់។

## *ព័ត៌មានកសិកម្ម*

ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ និងកាសែត) ជាប្រភពសំខាន់ដ៏បំផុតនៃព័ត៌មានកសិកម្ម។ សេវាផ្សព្វផ្សាយផ្នែកបន្ថែម ដែលបានផ្តល់ដោយរដ្ឋាភិបាលដូចជា ការចែករំលែកក្នុងចំណោមកសិករដោយខ្លួនឯង ដែលជាប្រភពព័ត៌មានដ៏សំខាន់មួយផ្សេងទៀត។ គ្រួសារចំនួនប្រមាណ ១.១លានគ្រួសារ ដែលទទួលបានព័ត៌មានកសិកម្មតាមរយៈវិទ្យុ និងប្រមាណ ១លានតាមរយៈទូរទស្សន៍។

### ក្រាហ្វិក៤.៤០ ចំនួនគ្រួសារកសិកម្មប្រើប្រាស់ប្រភពព័ត៌មានកសិកម្មតាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## ដំណើរការទីផ្សារ

ប្រមាណ ៧០ភាគរយ នៃគ្រួសារកសិកម្មនៅកម្ពុជា បានដឹងពីទីតាំងនៃទីផ្សារនៅជិតបំផុតរបស់ខ្លួន សម្រាប់ផលិតផលកសិកម្ម ហើយមានប្រមាណ ២២ភាគរយ នៃគ្រួសារកសិកម្មទាំងនោះមិនបានប្រើប្រាស់ទីផ្សារ ដើម្បីលក់ផលិតផលផ្ទាល់របស់កសិករ។ រីឯទីផ្សារនៅជិតបំផុតក្នុងតំបន់បឹងទន្លេសាប និងតំបន់ខ្ពង់រាប សម្រាប់ផលិតផលកសិកម្មនោះខ្ពស់ជាងនៅតំបន់ឆ្នេរសមុទ្រ។ តែបើគិតពីចម្ងាយទីផ្សារ គឺជាបញ្ហាធំបំផុត សម្រាប់គ្រួសារកសិករនៅតំបន់បឹងទន្លេសាប ខ្ពង់រាប និងជួរភ្នំមានភាគរយនៃគ្រួសារកសិករខ្ពស់បំផុតដែលបានធ្វើដំណើរចាប់ពី ១ម៉ោង ឬ ២ម៉ោងដើម្បីទៅដល់ទីផ្សារនៅជិតបំផុត។ ចំណែកមួយភាគតូចនៃគ្រួសារកសិករនៅក្នុងតំបន់ទាំងពីរនេះដែរ ក៏បានធ្វើដំណើរប្រមាណជាងពីរម៉ោងដើម្បទៅដល់ទីផ្សារដែរ។

ក្រាហ្វិក៤.៤១ ភាគរយនៃគ្រួសារកសិកម្មធ្វើដំណើរទៅទីផ្សារដែលជិតតាមតំបន់




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤))

មានប្រមាណ៥៦ភាគរយនៃគ្រួសារកសិកម្ម ដែលទទួលបានចំណេះដឹងពីវិស័យកសិកម្មនៅលើទីផ្សារនៅជិតបំផុតតាមដែលអាចធ្វើដំណើរទៅទីផ្សារក្នុងអំឡុងពេលតិចជាង៣០នាទី។ ក្នុងចំណោមតំបន់នានាមានច្រើន ឬតិចប្រមាណជាង ៥០ ដល់ ៦០ភាគរយ នៃគ្រួសារបានធ្វើដំណើរក្នុងតំបន់ទៅទីផ្សារ ដែលនៅជិតបំផុតក្នុងរយៈពេលតិចជាង ៣០នាទី។ ប្រមាណ ១ ទៅ ៣នៃគ្រួសារកសិកម្ម ស្ថិតក្នុងតំបន់បានទៅទីផ្សារនៅជិតបំផុត នៅក្នុងរយៈពេលតិចជាងមួយម៉ោង។ ប្រមាណចន្លោះពី ១៣ភាគរយ ដល់ ១៥ភាគរយ ការធ្វើដំណើរពីផ្ទះទៅកាន់ទីផ្សារក្បែរផ្ទះនោះ មានរយៈពេលពី ១ម៉ោង ទៅ ២ម៉ោង ស្ថិតក្នុងតំបន់បឹងទន្លេសាបនិងតំបន់ខ្ពង់រាបនៃតំបន់ទាំងពីរនេះ ដែលមានផលិតកម្មកសិកម្មស្ថិតនៅឆ្ងាយពីទីផ្សារ។ ក្នុងតំបន់ទាំងពីនេះ មានប្រមាណពី ៣ភាគរយ ដល់ ៧ភាគរយនៃគ្រួសារកសិកម្ម បានធ្វើដំណើរពីផ្ទះទៅកាន់ទីផ្សារដែលនៅជិតបំផុតក្នុងរយៈពេលជាង ២ម៉ោង។

ក្នុងចំណោមប្រាំបួនក្នុងដប់គ្រួសារនៃការធ្វើកសិកម្ម ដែលប្រមូលផលដំណាំកសិកម្មរបស់ខ្លួនទៅកាន់ទីផ្សារនៅជិតបំផុត ដោយប្រើប្រាស់ដូចជា រថយន្ត/កង់/ម៉ូតូ/ម៉ូតូកង់បីជាដើម។ ជាមួយនោះមានប្រមាណច្រើនឬតិច ៦ភាគរយ នៃ

គ្រួសារកសិកម្ម បានប្រើមធ្យោបាយផ្សេងទៀត រទេះគោ រទេះក្របី ក្បូន/ទូក។ល។ ប្រមាណ ៤ភាគរយ នៃគ្រួសារបាន ដើរពីផ្ទះទៅកាន់ទីផ្សារនៅជិតបំផុត ដើម្បីលក់ផលិតផលកសិកម្មរបស់ខ្លួន។

## ការខារសហគមន៍

ភាគតិចនៃគ្រួសារកសិកម្មដែលជាសមាជិកកសិកម្មក្នុងសមាគមន៍កសិកម្មយោងតាមរបាយការណ៍។ តែប្រមាណ ៦ភាគរយ នៃគ្រួសារកសិកម្មជាសមាជិករបស់សមាគមន៍កសិកសិកម្ម ហើយ ៤ភាគរយ ជាសមាជិកនៃសហករណ៍កសិកម្ម និងមានតែ ២ភាគរយ បានចូលរួមជាមួយសហគមន៍ប្រើប្រាស់ទឹកនិងកសិកម្ម។ សមាជិកនៃក្រុមមានខ្ពស់បំផុតនៅក្នុង តំបន់បឹងទន្លេសាប ដែលមាន ៨ភាគរយនៃគ្រួសារនៅក្នុងតំបន់ជាសមាជិកនៃសហគមន៍ផ្សេងៗទៀត។

ក្រាហ្វិក៤.៤២ ភាគរយនៃគ្រួសារកសិកម្មចូលរួមជាសមាជិកការងារកសិកម្មតាមតំបន់




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (ដំណាក់កាលបំពេញបន្ថែមឆ្នាំ២០១៤)

# ជំពូកទី ៥
# ការចិញ្ចឹមបសុសត្វ និងបសុបក្សី

## ការចិញ្ចឹមបសុសត្វ និងបសុបក្សី

ការចិញ្ចឹមបសុសត្វនិងបសុបក្សី គឺជាសកម្មភាពកសិកម្មសំខាន់ទីពីរធ្វើឡើងដោយគ្រួសារកសិករ បន្ទាប់ពីការងារដាំដុះដំណាំ។ ដូច្នេះការងារចិញ្ចឹមសត្វនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅនិងផ្តល់នូវប្រាក់ចំណូលដល់គ្រួសារកសិករនៅតាមជនបទ ប្រមាណ ៧៥ភាគរយ (១,៦លាន) នៃគ្រួសារកាន់កាប់ការងារកសិកម្មក្នុងប្រទេសកម្ពុជា បានចិញ្ចឹមបសុសត្វ និងឬបសុបក្សីនៅក្នុងពេលនៃការធ្វើជំរឿនកសិកម្មនេះ។ ចំនួនគ្រួសារចិញ្ចឹមបសុសត្វ និងបសុបក្សីច្រើនបំផុតគឺនៅតំបន់ខ្ពង់រាបនិងជួរភ្នំ (មានប្រមាណ ៨៦ភាគរយ នៃចំនួនគ្រួសារសរុប) បន្ទាប់ពីនេះគឺតំបន់ឆ្នេរ (៨៥ភាគរយ) តំបន់បឹងទន្លេសាប (៧៨ភាគរយ)និ ងតំបន់វាលទំនាប (៧៥ភាគរយ)។ នៅថ្នាក់ខេត្តត្រូវបានរាយការណ៍ចំនួនគ្រួសារដែលចិញ្ចឹមបសុសត្វនិងបសុបក្សីច្រើនជាគេគឺ ខេត្តព្រៃវែងមានចំនួន ១៧៨.០០០គ្រួសារ ស្មើនឹង ១១ភាគរយនៃចំនួនគ្រួសារសរុបក្នុងតំបន់វាលទំនាប។ ដោយឡែក បណ្តាខេត្តដទៃទៀតមានយ៉ាងតិច ១០០.០០០គ្រួសារ តាមរបាយការណ៍មាននៅខេត្តតាកែវ (១៦២.០០០គ្រួសារ) ខេត្តកំពង់ស្ពឺ (១៣៤.០០០គ្រួសារ) ខេត្តស្វាយរៀង (១០៦.០០០គ្រួសារ) ខេត្តកំពង់ធំ (១០៤.០០០គ្រួសារ) និងខេត្តកំពត (១០៣.០០០គ្រួសារ)។

ក្រាហ្វិក ៥.១÷ ចំនួនគ្រួសារកសិកម្មចិញ្ចឹមបសុសត្វនិងបសុបក្សីក្នុងពេលជំរឿន តាមខេត្តឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ប៉ែតសិបប្រាំភាគរយនៃគ្រួសារកសិកម្មទូទាំងប្រទេសបានចិញ្ចឹមបសុបក្សី ៦៦ភាគរយចិញ្ចឹមបសុសត្វធំ និង២៣ភាគរយចិញ្ចឹមបសុសត្វតូច។

### ក្រាហ្វិក ៥.២÷ ភាគរយគ្រួសារចិញ្ចឹមសត្វធំ




### ក្រាហ្វិក ៥.៣÷ គ្រួសារចិញ្ចឹមសត្វធំក្នុងពេលជំរឿន




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

លទ្ធផលជំរឿនបានបង្ហាញថា គ្រួសារកសិកម្មចូលចិត្តចិញ្ចឹមបសុសត្វធំជាងចិញ្ចឹមបសុសត្វតូច និងគ្រួសារជាច្រើនទៀតចូលចិត្តចិញ្ចឹមទាំងបសុសត្វនិងបសុបក្សី។ ក្នុងករណីគ្រួសារចិញ្ចឹមបសុសត្វធំមាន ៨៦ភាគរយ បានចិញ្ចឹមសត្វធំរវាងពី ២ ទៅ ៩ក្បាល មានដូចជា គោ និងក្របី មានគ្រួសារតែ ៣ភាគរយ បានចិញ្ចឹមសត្វធំ ៣ ឬច្រើនជាងនេះ។ នៅតំបន់វាលទំនាបមានចំនួនធំបំផុតនៃគ្រួសារ (ជាង ២០០.០០០គ្រួសារ) ចិញ្ចឹមសត្វតូច មានដូចជា ជ្រូក ពពែ។ល។ ក្នុងចំណោមគ្រួសារទាំងនោះ មានមួយចំនួនបានចិញ្ចឹមសត្វតូចពី ៣ ទៅ ២៩ក្បាល និងមួយចំនួនតូចចិញ្ចឹមសត្វពី ១ទៅ ២ក្បាល។

ប្រមាណជិត ៧០ភាគរយ នៃគ្រួសារចិញ្ចឹមបសុបក្សី បានចិញ្ចឹមមាន់ ទា ចាប់ពី ២៥ ទៅ ៤៩៩ក្បាល។ល។ និង ៣០ភាគរយ ចិញ្ចឹមសត្វបក្សី ចាប់ពី ១ ទៅ ២៤ក្បាល។ មានតែ ០,៥ភាគរយនៃគ្រួសារបានចិញ្ចឹមសត្វស្លាប ៥០០ក្បាល ឬច្រើនជាង។

### ក្រាហ្វិក ៥.៤÷ គ្រួសារចិញ្ចឹមសត្វតូចក្នុងពេលជំរឿន




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

### ក្រាហ្វិក ៥.៥÷ ភាគរយគ្រួសារចិញ្ចឹមសត្វតូច




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## ការចិញ្ចឹមគោ ក្របី និងជ្រូក

ចំពោះបសុសត្វធំភាគច្រើនត្រូវបានគ្រួសារកសិករចិញ្ចឹមដូចជា គោនិងក្របី។ តាមរយៈនៃការចិញ្ចឹមគោ ឃើញថា គ្រួសារកសិករចិញ្ចឹម ៦ដង ច្រើនជាងការចិញ្ចឹមក្របី និងគោ ១០ភាគរយ ជាគោឈ្មោល។ តាមការប៉ាន់ស្មាន មានសត្វគោប្រមាណ ៣,២ លាន ទូទាំងប្រទេស គិតជាមធ្យមមានចំនួនគោក្បាលក្នុងមួយគ្រួសារ។ នៅតំបន់វាលទំនាបមានចំនួនស្មើនឹង ៤១ភាគរយ នៃចំនួនគោសរុបទូទាំងប្រទេស (១,៣លានក្បាល) បន្ទាប់ពីនេះ នៅតំបន់បឹងទន្លេសាប មាន

គោចំនួន ៩០០.០០០ (២៩ភាគរយ) តំបន់ខ្ពង់រាបនិងជួរភ្នំ មានគោចំនួន ៧០០.០០០ក្បាល និងតំបន់ឆ្នេរ មានប្រមាណ ៣០០.០០០ក្បាល។ ខេត្តកំពង់ស្ពឺ ជាខេត្តដែលមានចំនួនគោច្រើនជាងគេ (៣៦៤.០០០ក្បាល) បន្ទាប់គឺខេត្តតាកែវ (៣៣៦.០០០ក្បាល) និងខេត្តព្រៃវែង (៣១១.០០០)។ ប្រមាណ ៨០ភាគរយនៃសត្វគោ ដែលបានចិញ្ចឹមក្នុងប្រទេសកម្ពុជា ត្រូវបានរាយការណ៍ថាជាពូជក្នុងស្រុក និងមាន ១១ភាគរយ ត្រូវបានរាយការណ៍មកថាជាពូជកូនកាត់ឬនាំចូល។

### ក្រាហ្វិក ៥.៦÷ ចំនួនគោដែលមានក្នុងពេលជំរឿន ២០១៣




### ក្រាហ្វិក ៥.៧÷ ចំនួនក្របីដែលមានក្នុងពេលជំរឿន ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ក្របីមានចំនួនសរុបប្រមាណ ៥១៩.០០០ក្បាល ត្រូវបានរាយការណ៍ ក្នុងនោះ ៤១ភាគរយ នៅតំបន់វាលទំនាប បន្ទាប់មកទៀត ៣៥ភាគរយ នៅតំបន់បឹងទន្លេសាប និង ១៨ភាគរយ នៅតំបន់ខ្ពង់រាបនិងជួរភ្នំ។ នៅថ្នាក់ខេត្ត ដែលមានចំនួនក្របីច្រើនជាងគេគឺ ខេត្តស្វាយរៀង (១០៥.០០០ក្បាល) បន្ទាប់ពីនេះគឺខេត្តពោធិ៍សាត់ (៦១.០០០ក្បាល) និងខេត្តកំពង់ធំ (៥២.០០០ក្បាល)។

## ក្រាហ្វិក ៥.៨÷ ចំនួននិងភាគរយក្របីដែលមានក្នុងពេលជំរឿន ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

គោនិងក្របី ដែលបានចិញ្ចឹមគឺសម្រាប់គោលបំណងសំខាន់ ៣ នៅកម្ពុជាគឺ÷ (ក)- ចិញ្ចឹមដើម្បីលក់ ១,៣លានក្បាល ឬស្មើនឹង៤០ភាគរយ) (ខ)- ចិញ្ចឹមសម្រាប់ជាកម្លាំងអូសទាញ (៣៧ភាគរយ) (គ)- ចិញ្ចឹមសម្រាប់បង្កាត់ពូជនិងចុងក្រោយលក់ (១៧ភាគរយ)។ តាមរបាយការណ៍ ក្របី មានការលំបាកក្នុងការបង្កាត់ពូជ បើប្រៀបធៀបទៅនឹងគោ ពួកគាត់ច្រើនតែរក្សាទុកសម្រាប់ប្រើប្រាស់ជាកម្លាំងអូសទាញ។

សត្វជ្រូកដែលបានចិញ្ចឹម សរុបមានចំនួន ២,២ លានក្បាល ស្មើនឹង ៩៨ភាគរយ នៃចំនួនសរុបបសុសត្វ ដែលបានចិញ្ចឹមក្នុងប្រទេស។ តាមរបាយការណ៍ កសិករនៅតំបន់វាលទំនាប ភាគច្រើនចិញ្ចឹមជ្រូក (៨៩ភាគរយ)។ ជ្រូកប្រមាណ ៧៤ភាគរយ គឺជាពូជជ្រូកក្នុងស្រុក និងប្រមាណ ១៩ភាគរយ គឺសំគាល់ឃើញថា ជាពូជបង្កាត់ឬពូជនាំចូល។ ខេត្តតាកែវ គឺជាខេត្តដែលមានការចិញ្ចឹមជ្រូកច្រើនជាងគេជាលក្ខណៈគ្រួសារ សរុបចំនួន២២៨.០០០ក្បាល។

ជ្រូក ភាគច្រើនគេចិញ្ចឹមសម្រាប់លក់រស់ និងមួយចំនួនតូចគឺរក្សាទុកសម្រាប់ទុកបង្កាត់ពូជ ឬលក់ឱ្យទីសត្វឃាតសម្រាប់កាប់សាច់។

## ក្រាហ្វិក ៥.៩÷ ចំនួនជ្រូកដែលមានតាមរាជធានី-ខេត្ត ក្នុងពេលជំរឿនឆ្នាំ ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## មាន់និងទា

មាន់និងទា ជាប្រភពប្រូតេអ៊ីនដ៏សំខាន់សម្រាប់គ្រួសារកសិកម្ម ភាគច្រើនបសុបក្សីត្រូវបានគេចិញ្ចឹមមាន់ ប្រមាណជា ៤៥លានក្បាល និងទាចំនួន ១១លានក្បាល នៅកំឡុងពេលនៃការធ្វើសម្ភាសន៍។ ខេត្តតាកែវ ជាខេត្តនាំមុខជាងគេ ក្នុងចំណោមខេត្តដ៏ទៃទៀត មានមាន់ចំនួន ៥លានក្បាល ត្រូវបានចិញ្ចឹមជាលក្ខណៈគ្រួសារ។ ខេត្តព្រៃវែង បើតាមរបាយការណ៍ចិញ្ចឹមទា (១,៩លានក្បាល) បន្ទាប់មកគឺខេត្តតាកែវ និងកំពង់ចាម ដែលខេត្តនីមួយៗ មានទាចំនួន ១,៨ លានក្បាល។

មាន់ពេញវ័យ (១០ថ្ងៃ ឬច្រើនជាងនេះ) មានប្រមាណ ៥៧ភាគរយ នៃចំនួនមាន់ទាំងអស់ ដែលបានកត់ត្រាក្នុងពេលធ្វើជំរឿន។ ទាពេលវ័យមាន ៨២ភាគរយ នៃចំនួនទាសរុប។

ក្រាហ្វិក ៥.១០ក÷ ចំនួនបសុបក្សីចិញ្ចឹមដោយគ្រួសារកសិកម្មតាមប្រភេទនិងអាយុ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ក្រាហ្វិក ៥.១០ខ÷ ចំនួនបសុបក្សីផ្សេងៗទៀតក្រៅពីមាន់-ទាតាមប្រភេទនិងអាយុ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

សត្វបក្សីនិងបសុបក្សីផ្សេងទៀត ដែលបានរាយការណ៍តាមរយៈគ្រួសារ គឺរួមបញ្ចូលទាំងសត្វត្រចៀកកាំចំនួន ៧០.០០០ក្បាល (មានច្រើនលើសលប់នៅខេត្តព្រះសីហនុ និងខេត្តកំពត) សត្វត្រូចមានចំនួន ៤៦.០០០ក្បាល (មាន

ច្រើនលើសលប់នៅខេត្តបាត់ដំបង និងរាជធានីភ្នំពេញ) មាន់បារាំងមានចំនួន ១២.០០០ក្បាល និងប្រភេទសត្វស្លាបផ្សេងៗទៀតមានចំនួន ១៨.០០០ក្បាល។

ភាគច្រើននៃគ្រួសារកសិកម្ម (៩០ភាគរយ) បានរក្សាបសុសត្វនិងបសុបក្សីនៅនឹងផ្ទះរបស់ពួកគេ ដោយបានបែងចែកកន្លែងចិញ្ចឹមនៅក្បែរផ្ទះ ឬខាងក្រោមផ្ទះ។ មានតែ ១៤ភាគរយ គ្រួសារដែលបានបែងចែកដី ឬដីដែលមានស្មៅសម្រាប់ចិញ្ចឹមបសុសត្វនិងបសុបក្សី។ មានចំនួនគ្រួសារតិចតួចដែលបានបែងចែងដីដាំដំណាំ សម្រាប់ចិញ្ចឹមបសុសត្វនិងបសុបក្សីរបស់គេ។

## ក្រាហ្វិក ៥.១១÷ បណ្តាខេត្តចិញ្ចឹមមាន់ពី១លានក្បាល ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## ក្រាហ្វិក ៥.១២÷ បណ្តាខេត្តចិញ្ចឹមទាពី១លានក្បាល ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## បសុសត្វនិងបសុបក្សីដែលបានបញ្ចេញ

សត្វដែលបញ្ចេញលក់ ឬបញ្ចេញក្នុងសភាពផ្សេងដូចជា កន្លែងសម្លាប់សត្វនៅទីសត្តឃាត អ្នកកាប់សាច់លក់ ឬរោងចក្រវេចខ្ចប់សាច់ ឬសត្វឱ្យជាអំណោយ សម្រាប់ចេញថ្លៃសេវា ឬហេតុផ្សេងៗ រួមបញ្ចូលទាំងសត្វជាអំណោយក្នុងពិធីបុណ្យ និងក្នុងសមាគមន៍ផ្សេងៗទៀត។ សត្វគោដែលបានបញ្ចេញក្នុងរយៈពេល ១២ខែកន្លងមក មុនពេលធ្វើជំរឿនសរុបមានចំនួន ៤០៦.០០០ក្បាល ស្មើនឹង ៧៨ភាគរយ នៃចំនួនសត្វគោដែលលក់រស់។ តំបន់វាលទំនាបមានប្រមាណ ៤៨ភាគរយ នៃចំនួនសត្វគោដែលបានបញ្ចេញ ២៧ភាគរយ តំបន់បឹងទន្លេសាប និង ១៩ភាគរយ តំបន់ខ្ពង់រាប និងជួរភ្នំ។ ក្រៅពីនេះ សត្វគោលក់រស់ គោងាប់ចំនួន ៦ភាគរយ គោបាត់ចំនួន ៤ភាគរយ (រួមបញ្ចូលទាំងចោរលួច) ៥ភាគរយ កាប់សាច់សម្រាប់ហូបក្នុងគ្រួសារ និងលក់ ៣ភាគរយ ឱ្យជាអំណោយ ឬពិធីមង្គលការ។ល។ និង ៤ភាគរយ បញ្ចេញក្នុងគោលបំណងផ្សេងៗ ដូចជាក្នុងការទូទាត់បំណុល។ល។

ក្រាហ្វិក ៥.១៣÷ ចំនួននិងភាគរយគោបានបញ្ចេញ ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ខេត្តកំពង់ស្ពឺបានរាយការណ៍ពីចំនួនធំបំផុត នៃសត្វគោដែលបានលក់រស់ (៤៤.០០០ក្បាល) បន្ទាប់គឺខេត្តតាកែវ (៤០.០០០ក្បាល) ខេត្តព្រៃវែង (២៩.០០០ក្បាល) ខេត្តសៀមរាប (២៥.០០០ល្បាល) ខេត្តកំពង់ចាម (២២.០០០ក្បាល) ខេត្តកណ្តាល (២២.០០០ក្បាល) និងខេត្តកំពត (២១.០០០ក្បាល)។

ចំនួនក្របីសរុបប្រមាណជា ៦៧.០០០ក្បាល ត្រូវបានបញ្ចេញក្នុងរយៈពេលដូចគ្នា ក្នុងនោះ ៥៥ភាគរយ ត្រូវបានលក់រស់ និងប្រមាណ ៣៥ភាគរយ សងថ្លៃបំណុលគេ និងដោះដូរសម្រាប់ម្ហូបអាហារ។ល។ ខេត្តស្វាយរៀង ជាខេត្តដែលលក់ក្របីរស់មានចំនួនធំបំផុត (៦.០០០ក្បាល) បន្ទាប់គឺខេត្តកំពង់ឆ្នាំង (ប្រមាណជា ៦.០០០ក្បាល) ខេត្តព្រៃវែង (៥.០០០ក្បាល) ខេត្តពោធិ៍សាត់ (៤.០០០ក្បាល) និងខេត្តត្បូងឃ្មុំ (៤.០០០ក្បាល)។

### ក្រាហ្វិក ៥.១៤÷ ចំនួននិងភាគរយក្របីបានបញ្ចេញ ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ប្រមាណជា ១,៣លាន ជ្រូក ត្រូវបានបញ្ចេញក្នុងរយៈពេល ១២ខែ មុនពេលការធ្វើជំរឿន ក្នុងនោះ ៩០ភាគរយ លក់រស់។ ប្រមាណជា ៧ភាគរយ ងាប់ និងសល់ពីនេះកាប់សាច់សម្រាប់បរិភោគ លក់សាច់ ផ្ដល់ជាអំណោយ ឬបាត់បង់ ដោយចោរលួច។ ភាគច្រើនជ្រូក (៤២ភាគរយនៃចំនួនសរុប) ត្រូវបានរាយការណ៍ មាននៅតំបន់វាលទំនាប និងខេត្ត កំពង់ស្ពឺគឺជាខេត្តមួយឈានមុខគេសម្រាប់ការលក់ជ្រូករស់ (២១៤.០០០ក្បាល)។ ខេត្តតាកែវ និងសៀមរាប បាន រាយការណ៍ផងដែរពីការលក់ជ្រូករស់លើសពី ១០០.០០០ក្បាល នៃខេត្តនីមួយៗ។

### ក្រាហ្វិក ៥.១៥÷ ចំនួនជ្រូកបានបញ្ចេញឆ្នាំ ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

### ក្រាហ្វិក ៥.១៦÷ ចំនួននិងភាគរយជ្រូកបានបញ្ចេញឆ្នាំ ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ប្រមាណជា ២៥លាន មាន់ ត្រូវបញ្ចេញក្នុងរយៈពេល ១២ខែដូចគ្នាមុនពេលជំរឿន ក្នុងនោះ មាន់ប្រមាណ ៤៧ភាគរយ លក់រស់នៅទីផ្សារ និងនៅកន្លែងផ្សេងៗដទៃទៀត។ ប្រមាណជា ២២ភាគរយ ត្រូវបានសម្លាប់សម្រាប់បរិភោគ ឬលក់សាច់ ក្រៅពីនេះប្រមាណ ២២ភាគរយ ងាប់ដោយជំងឺ និង ៤ភាគរយ ត្រូវបានបាត់បង់។ ខេត្តកណ្តាលត្រូវបានរាយការណ៍មានចំនួនមាន់លក់រស់ច្រើនជាង (២,២លានក្បាល) ខេត្តកំពង់ស្ពឺ (១,២លានក្បាល) និងខេត្តតាកែវ (១,១លានក្បាល)។

គ្រួសារកសិកម្មនៅខេត្តកំពត បានរាយការណ៍ថា ភាគច្រើនបានសម្លាប់សត្វមាន់ចំនួន៦០០.០០០ក្បាល សម្រាប់បរិភោគ ឬលក់សាច់។ ខេត្តតាកែវ និងខេត្តសៀមរាប មានមាន់ចំនួន ៥០០.០០០ក្បាល នៃខេត្តនីមួយៗ។

ប្រមាណជា ៣,៣លានក្បាលទា ត្រូវបញ្ចេញក្នុងរយៈពេល ១២ខែមុនពេលធ្វើជំរឿន ក្នុងនោះប្រមាណជា ៥០ភាគរយ (ប្រហាក់ប្រហែល ១,៧លានក្បាល) លក់រស់ ១២ភាគរយ ត្រូវបានកាប់សាច់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ឬលក់សាច់ និង ១៨ភាគរយ ងាប់ដោយសារជំងឺឆ្លង។ល។ ខេត្តព្រៃវែង ជាខេត្តដែលមានចំនួនទាលក់រស់ច្រើនជាងគេ (ប្រមាណជា ៥៤០.០០០ក្បាល) និងមានចំនួនទាឆ្លងជំងឺ ច្រើនជាងគេ (១២២.០០០ក្បាល)។ ខេត្តស្វាយរៀង តាមរបាយការណ៍ មានចំនួនទាដែលបានសម្លាប់យកសាច់សម្រាប់ម្ហូបអាហារច្រើនជាងគេ ឬលក់សាច់ (៦៣.០០០ក្បាល)។

## ក្រាហ្វិក ៥.១៧÷ ចំនួននិងភាគរយមាន់បានបញ្ចេញឆ្នាំ ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## ក្រាហ្វិក ៥.១៨÷ ចំនួននិងភាគរយទាបានបញ្ចេញឆ្នាំ ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## សត្វបក្សីមានជំងឺ

ខេត្តព្រៃវែង មានចំនួនមាន់ច្រើនជាងគេដែលងាប់ដោយសារជំងឺ (ប្រមាណជា ៥៧៧.០០០ក្បាល)។ ខេត្តកំពង់ស្ពឺ និងខេត្តសៀមរាបបានរាយការណ៍ថា មានមាន់ច្រើនជាង ៥០០.០០០ក្បាល បានងាប់ដោយសារជំងឺ។ ក្រាហ្វិចទី ៥.១៩ បង្ហាញថា បណ្ដាខេត្តដែលមានចំនួនមាន់ងាប់ច្រើនដោយសារជំងឺ និងសម្លាប់យកសាច់មានដូចខាងក្រោម÷

ក្រាហ្វិក ៥.១៩÷ ចំនួនមាន់បានស្លាប់ដោយសារជំងឺ និងសម្លាប់យកសាច់តាមខេត្តឆ្នាំ ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ក្រាហ្វិក ៥.២០÷ ចំនួននិងភាគរយនៃគ្រួសារទទួលបានសេវាកម្មផ្សព្វផ្សាយពេទ្យសត្វ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## ឧបករណ៍និងសម្ភារៈបរិក្ខា

ប្រមាណជា ១១.០០០គ្រួសារកសិកម្ម តាមរបាយការណ៍ កំពុងប្រើប្រាស់ឧបករណ៍ភ្ញាស់ ឧបករណ៍កំដៅ និងម៉ាស៊ីនភ្លើង ក្នុងការចិញ្ចឹមបសុសត្វនិងបសុបក្សី ក្នុងនោះប្រមាណ ៩០ភាគរយ ប្រើប្រាស់ម៉ាស៊ីនភ្លើងផ្ទាល់ ខ្លួន និង ៩២ភាគរយ ឧបករណ៍ភ្ញាស់ផ្ទាល់ខ្លួន។ ប្រមាណជា ៤០ភាគរយ នៃគ្រួសារកសិកម្ម ទទួលបានសេវាកម្ម ផ្សព្វផ្សាយបសុពេទ្យ ក្នុងការចិញ្ចឹមបសុសត្វនិងបសុបក្សី ៦០ភាគរយ បានទទួលការចាក់វ៉ាក់សាំងឥតគិតថ្លៃ និងបន្ថែមពីនេះ ២៥ភាគរយ បានគ្រប់គ្រងដោយផ្ទាល់ក្នុងការប្រើប្រាស់ថ្នាំ វីតាមីន លើសត្វរបស់ពួកគេ។ល។ មានតែ ៤ភាគរយ នៃគ្រួសារចិញ្ចឹមបសុសត្វបសុបក្សីបានរាយការណ៍ថា ជាសមាជិកភាពនៅក្នុងការចិញ្ចឹមសត្វ ក្នុងក្រុមសហគមន៍ឬសមាគម។ គ្រួសារភាគច្រើនមិនចាត់ទុកថា ជាការបង្កើនការចិញ្ចឹមសត្វជាសមាជិកនៃក្រុម ដោយសារតែខ្វះការយល់ដឹងពីប្រយោជន៍របស់ពួកគេ។

# ជំពូកទី ៦
# ការនេសាទនិងវារីវប្បកម្ម

ការនេសាទនិងវារីវប្បកម្មជាជម្រើសមួយឬសកម្មភាពសេដ្ឋកិច្ចបន្ថែមទៀត សម្រាប់ការជួយឱ្យគ្រួសារកាន់កាប់កសិកម្មនៅប្រទេសកម្ពុជា។ គ្រួសារភាគច្រើនដែលបានចូលរួមនៅក្នុងការនេសាទទាំងនោះ ស្ថិតនៅតំបន់ក្បែរកន្លែងនេសាទជាពិសេសនៅតំបន់បឹងទន្លេសាបនិងតំបន់ឆ្នេរសមុទ្រ និងតាមការរាយការណ៍បង្ហាញថា ៩០ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មទាំងអស់បានចូលរួមក្នុងការនេសាទត្រីសម្រាប់គោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន។

## ការនេសាទត្រី

គោលបំណងនៃជំរឿនបានកំណត់ថាការនេសាទ គឺជាការចាប់ត្រីនិងប្រភេទសត្វផ្សេងៗទៀតដូចជា វារីជាតិ (ខ្យង លៀស គ្រុំ ) សត្វមានសំបករឹង (ក្តាម បង្គា បង្កង) និងសត្វសមុទ្រដែលមានបន្លា នៅក្នុងទឹក ស្ទឹង ទន្លេ ឆ្នេរសមុទ្រ និងប្រភពទឹកផ្សេងទៀត ដោយគ្មានការប្រើទូកនិងឧបករណ៍ដ៏ទៃទៀត។

ចំនួនសរុបនៃគ្រួសារដែលបានចូលរួមក្នុងសកម្មភាពនេសាទ និងវារីវប្បកម្មត្រូវបានរាយកាណ៍ក្នុងតំណាក់កាលគោលនៃការធ្វើជំរឿនមានចំនួន ៥៣១.000គ្រួសារ។ ចំនួននេះត្រូវបានរាយការណ៍ថាសកម្មភាពនេសាទ និងវារីវប្បកម្មធ្វើឡើងក្នុងរយៈពេល ១២ខែកន្លងមកនៅក្នុងតំណាក់កាលគោលនៃជំរឿនក្នុងខែមេសា ឆ្នាំ២០១៣។ ទោះជាយ៉ាងណាក៏ដោយ គ្រួសារដែលបានចូលរួមក្នុងសកម្មភាពនេសាទនិងវារីវប្បកម្ម ដែលបានរាយការណ៍នៅតំណាក់កាលបំពេញបន្ថែមនៅខែមករា ឆ្នាំ២០១៤ តួលេខមានច្រើនជាងគឺ ៦៨0.000គ្រួសារ។ កាលពី ពីរ-បីខែ នៅចុងឆ្នាំ២០១៣ បណ្ដាខេត្តជាច្រើនបានទឹកជន់លិច និងសកម្មភាពកសិកម្មមិនអាចធ្វើបាននៅតាមតំបន់មួយចំនួន។ នេះមានន័យថាគ្រួសារកសិកម្មជាច្រើនបានងាកទៅរកការនេសាទត្រី ដែលជាប្រភពចម្បងសម្រាប់អាហារនិងបង្កើនប្រាក់ចំណូល។

តារាង ៦.១ តួលេខនិងភាគរយនៃគ្រួសារបានចូលរួមនៅក្នុងការនេសាទនិងវារីវប្បកម្ម ឆ្នាំ២០១២-២០១៣

| កម្មភាពនេសាទ/វារីវប្បកម្ម | គ្រួសារសរុប | | ចូលរួមក្នុងនេសាទ | | ចូលរួមក្នុងវារីវប្បកម្ម | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| សរុប | 525 952 | 100.0 | 462 457 | 87.9 | 80 632 | 15.3 |
| សកម្មភាពវារីវប្បកម្មតែឯង | | 1.0 | - | - | 5 282 | 6.6 |
| ការដាំដុះដំណាំរួមជាមួយនឹងវារីវប្បកម្ម / ចិញ្ចឹមបសុសត្វ / សត្វបក្សី | 63 495 | 12.1 | - | - | 63495 | 78.7 |
| ការនេសាទត្រី និងវារីវប្បកម្ម | 2 893 | 0.6 | 2 893 | 0.6 | 2 893 | 3.6 |
| ការរួមបញ្ចូលគ្នា ការនេសាទត្រី វារីវប្បកម្ម ការដាំដុះដំណាំ/ ចិញ្ចឹមបសុសត្វ/ សត្វបក្សី | 8 962 | 1.7 | 8 962 | 1.9 | 8 962 | 1.1 |
| ការនេសាទត្រី រួមជាមួយនឹងដាំដុះដំណាំ / ចិញ្ចឹមបសុសត្វ / សត្វបក្សី | 399 639 | 76.0 | 399 639 | 86.4 | 0 | 0 |
| មានតែការនេសាទត្រីប៉ុណ្ណោះ | 50 963 | 9.7 | 50 963 | 11.0 | 0 | 0 |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣ (តារាងសំណួរគោល) សម្គាល់÷ ទិន្នន័យនេះដកស្រង់ចេញពីកម្រងសំណួរទម្រង់ Aនៃជំរឿនដែលបានចុះបញ្ជីគ្រប់គ្រួសារនៅតំណាក់កាលគោល ក្នុងខែមិនា ឆ្នាំ២០១៣ ដោយប្រើឆ្នាំយោង ក្នុងរយៈពេល១២ខែកន្លងមក។

ចំនួនសរុបគ្រួសារបានចូលរួមនៅក្នុងការនេសាទភាគច្រើន គឺការនេសាទរួមផ្សំជាមួយនឹងការដាំដុះដំណាំ ឬការចិញ្ចឹមបសុសត្វ និងបសុបក្សី ព្រមទាំងសកម្មភាពការងារវារីវប្បកម្មផ្សេងទៀតមានតែ ១១ភាគរយនៃគ្រួសារ ដែលចាប់យកលើការនេសាទត្រីសម្រាប់លក់ជាសកម្មភាពសេដ្ឋកិច្ចចម្បងរបស់ពួកគេ។

គ្រួសារជាច្រើនបានចូលរួមក្នុងការនេសាទ និងសកម្មភាពកសិកម្មដទៃទៀត ច្រើនជាងចំនួនចូលរួមក្នុងសកម្មភាពនេសាទនិងវារីវប្បកម្មផ្សេងទៀត។ ដោយផ្អែកលើចំនួនគ្រួសារ នៅតំបន់វាលទំនាបនិងតំបន់បឹងទន្លេសាបមានគ្រួសារជាច្រើនចូលរួមក្នុងការនេសាទ ច្រើនជាងការនេសាទនៅតំបន់ឆ្នេរសមុទ្រ ដោយសារតែចំនួនគ្រួសារស្ថិតនៅតំបន់ឆ្នេរតិចជាង បើធៀបទៅនឹងតំបន់ផ្សេងទៀត។ ខេត្តព្រៃវែងបានរាយការណ៍ថាមានចំនួនច្រើន នៃគ្រួសារដែលបានចូលរួមក្នុងសកម្មភាពនេសាទ (១៣ភាគរយ ស្មើនឹង ៨២.000គ្រួសារ) នឹងខេត្តផ្សេងទៀតមានប្រមាណជាង ៥0.000 គ្រួសារកសិកម្មបានចូលរួមក្នុងការនេសាទរួមបញ្ចូលមាន: ខេត្តសៀមរាប តាកែវ ស្វាយរៀង និងកំពត។

### ក្រាហ្វិក ៦.១ ចំនួនគ្រួសារកាន់កាប់កសិកម្ម រួមជាមួយការនេសាទ តាមខេត្តក្រុង ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

### ក្រាហ្វិក ៦.២ ភាគរយគ្រួសារកសិកម្មរួមជាមួយការនេសាទ និងគោលបំណងចម្បងនៃការនេសាទ ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

មានជាង៩០ភាគរយនៃគ្រួសារកសិកម្មនៅក្នុងប្រទេសកម្ពុជា បានចូលរួមនៅក្នុងការនេសាទសំខាន់ ដើម្បីបំពេញតម្រូវការគ្រួសារ។ ការនេសាទត្រីជាចម្បងសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារត្រូវបានគេរាយការណ៍ថា នៅក្នុងខេត្តស្ទើរតែទាំងអស់លើកលែងតែនៅតាមបណ្ដាខេត្តឆ្នេរសមុទ្ររួមមានខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកែប។

### ក្រាហ្វិក ៦.៣ ភាគរយគ្រួសារកសិកម្មរួមជាមួយការនេសាទ និងការប្រើឧបករណ៍នេសាទតាមប្រភេទ ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

សំណាញ់គឺជាបច្ចេកទេសាមញ្ញត្រូវបានប្រើភាគច្រើនដោយគ្រួសារកសិកម្មរួមជាមួយការនេសាទមានប្រមាណ ៦០ភាគរយ នៃគ្រួសារដែលប្រើប្រាស់មុងលើនិងមុងរុញ និង៥៥ភាគរយដោយការប្រើសំណាញ់។ សៃយឺននេសាទតូចៗត្រូវបានគេឱ្យប្រើមាន ៤៤ភាគរយនៃគ្រួសារកសិកម្ម បានកំណត់ការនេសាទត្រីនៅក្នុងតំបន់ ជាកន្លែងដែលពួកគេអាចចាប់បានយ៉ាងងាយស្រួល។ ឧបករណ៍នេសាទសិប្បកម្ម ដូចជាលំពែងត្រូវបានប្រើមាន ៣៥ភាគរយ នៃគ្រួសារកសិកម្ម អួននិងសន្ទូចត្រូវបានប្រើផងដែរ។ ការប្រើប្រាស់ទូកនេសាទត្រូវបានរាយការណ៍ថាមានត្រឹមតែ ១៣ភាគរយ នៃគ្រួសារទាក់ទងការនេសាទ។ ការបង្ហាញថាក្នុងរង្វង់ ៨៧ភាគរយ នៃគ្រួសារមិនបានរាយការណ៍នូវអ្វីផ្សេងទៀត នៅក្នុងការប្រើប្រាស់ទូកមួយ។ ទូកមានបីប្រភេទដែលបានប្រើគឺ ទូកប្រពៃណីដោយគ្មានម៉ាស៊ីន ទូកមានម៉ាស៊ីន និងកាណូត ដូចជាក្បូនតាមចំណូលចិត្ត សម្រាប់ការប្រើប្រាស់ទូកជាប្រពៃណី ត្រូវបានគេបង្ហាញនៅក្នុងខេត្តស្ទើរតែទាំងអស់ លើកលែងសម្រាប់អ្នកតំបន់ឆ្នេរសមុទ្រ។

### ក្រាហ្វិក ៦.៤ ភាគរយគ្រួសារកសិកម្មរួមជាមួយសកម្មភាពការនេសាទមានគោលបំណងចម្បង តាមខេត្តក្រុងឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

## វារីវប្បកម្ម

វារីវប្បកម្មត្រូវបានបញ្ចូលក្នុងការធ្វើកសិកម្ម ស្ថិតក្រោមការត្រួតពិនិត្យនៃវប្បកម្ម មានផលិតផលក្នុងទឹកដូចជាត្រី សត្វមានសំបករឹង សារ៉ាយធម្មជាតិ និងធនធានជលផលផ្សេងទៀតនៅក្នុង បឹង ស្ទឹង ទន្លេ សមុទ្រនិងវាលភក់ល្បាប់ ឬសាកសពដទៃទៀតនៃទឹករួមមានការចិញ្ចឹមក្នុងស្រះ ស៊ង និងរុក្ខជាតិសមុទ្រ សារ៉ាយ។ ប្រមាណជា ២៦.000 គ្រួសារដែលមានកសិកម្មរួមជាមួយការអនុវត្តន៍វារីវប្បកម្ម មានត្រឹមតែ ១,២ភាគរយ នៃគ្រួសារការកាន់កាប់កសិកម្មនៅកម្ពុជា។

ប្រមាណ៩០ភាគរយនៃគ្រួសារការកាន់កាប់កសិកម្មទាំងនោះ បានដាក់បញ្ចូលការភ្ញាស់កូនត្រីពូជទៅក្នុងវារីវប្បកម្ម ឬការចិញ្ចឹមសត្វរុក្ខជាតិក្នុងទឹក តាមបែបធម្មជាតិ ដូចជាចិញ្ចឹមតាមស្រះធម្មជាតិ ឬតាមសិប្បនិម្មិត មានតែ៣ភាគរយចិញ្ចឹមក្នុងស៊ង (តាមបែបធម្មជាតិសុទ្ធ ទៅតាមកម្រិតទឹកចុះឡើង នៃទន្លេ បឹង ស្ទឹង និង សមុទ្រ) និង៣ភាគរយ បានចូលរួមក្នុងចិញ្ចឹមក្នុងបែរ (ចិញ្ចឹមក្នុងទ្រុងស្រដៀងគ្នាទៅនឹងការដាក់សំណាញ់ព័ន្ធជុំវិញភ្ជាប់ទៅនិងបង្គោលឈើប្អូនជ្រុងផ្ងាឡើងលើដាក់បណ្តែតក្នុងទឹក)។

ក្រាហ្វិក ៦.៥ ភាគរយតំបន់វារីវប្បកម្ម តាមប្រភេទវារីវប្បកម្ម ឆ្នាំ២០១៣




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ផ្ទៃដីសរុបវារីវប្បកម្មត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន ៣០៤ហិកតា ជាមួយនឹងការចិញ្ចឹមក្នុងស្រះ ដែលបានរួមចំណែកធំមាន ៧៣ភាគរយ ការចិញ្ចឹមត្រីក្នុងស៊ង ១៦ភាគរយ និងការចិញ្ចឹមក្នុងស្រែ ១០ភាគរយ ដែលត្រូវបាន

អនុវត្តតាមវាលស្រែនឹងភ្ញាស់កូនត្រី ក្នុងគោលបំណង ដើម្បីទទួលបានការប្រមូលផលត្រីនៅក្នុងស្រែបន្ថែមទៅលើការប្រមូលផលស្រូវ។ ខេត្តព្រៃវែងបានរាយការណ៍ថា តំបន់ដែលធំជាងគេក្នុងការចិញ្ចឹមត្រីក្នុងស្រះ មាននៅខេត្តស្វាយរៀងនិងកំពត។ ចំនួន៩៤ភាគរយ នៃការចិញ្ចឹមត្រីក្នុងស្រះពាក់ព័ន្ធនិងទឹកសាបទាំងស្រុង ជាពិសេសការចិញ្ចឹមក្នុងបែរ។ មាន៦៤ភាគរយកន្លែងភ្ញាស់កូនត្រីនិងបង្កាត់ពូជត្រូវបានអនុវត្តក្នុងទឹកសាបនិងនៅក្នុងទឹកភ្លាវ (ប្រែបន្តិច) ដើម្បីផ្លាស់ប្តូរពីការចិញ្ចឹមត្រីទៅចិញ្ចឹមក្រពើ។

**តារាង ៦២ ចំនួននិងភាគរយគ្រួសារមានសកម្មភាពវារីវប្បកម្មតាមប្រភេទនៃសកម្មភាពវារីវប្បកម្ម និងប្រភេទនៃការប្រើទឹកឆ្នាំ២០១៣**

| ប្រភេទនៃវារីវប្បកម្ម | ចំនួនសរុបនៃគ្រួសារជាមួយសកម្មភាពវារីវប្បកម្ម | ភាគរយនៃគ្រួសារជាមួយសកម្មភាពវារីវប្បកម្ម តាមប្រភេទនៃទឹក | | |
|---|---|---|---|---|
| | | ទឹកសមុទ្រ | ទឹកភ្លាវ | ទឹកសាប |
| ចិញ្ចឹមក្នុងស្រះ | 24,555 | 1.89 | 3.69 | 94.43 |
| ចិញ្ចឹមក្នុងស៊ង | 839 | 61.03 | | 38.97 |
| ចិញ្ចឹមក្នុងបែរ | 768 | 0.13 | | 99.87 |
| ចិញ្ចឹមក្នុងស្រែ | 155 | | | 100.00 |
| អាងភ្ញាស់/ថែបំប៉ន | 56 | | 35.71 | 64.29 |
| វារីវប្បកម្មផ្សេងៗ | 103 | 34.95 | | 65.05 |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

ការចិញ្ចឹមត្រីភាគច្រើនគឺ ត្រូវបានចិញ្ចឹមនៅក្នុងដីលំនៅដ្ឋានតាមបែបទម្រង់កសិដ្ឋានវារីវប្បកម្ម មានទំហំកសិដ្ឋានជាមធ្យមគឺ ១០០ម៉ែត្រការ៉េ ខណៈដែលនៅតំបន់ខ្លះធំ គិតជាមធ្យមក្នុងមួយកសិដ្ឋានផ្លាស់ប្តូរទៅចិញ្ចឹមបង្គានិងបង្កងមានទំហំ ៥០៥ម៉ែតការ៉េ ជាមធ្យមទំហំ ២៦៥ម៉ែតការ៉េ បានប្រែក្លាយប្រួលទៅចិញ្ចឹមក្តាមនិង ការចិញ្ចឹមក្រពើមានទំហំ ២៩២ម៉ែតការ៉េ។ ខេត្តព្រៃវែងបាននាំមុខគេនៅក្នុងលក្ខខណ្ឌនៃការចិញ្ចឹមបង្គានិងបង្កង និងខេត្តតាកែវបាននាំមុខគេនៅក្នុងលក្ខខណ្ឌនៃចិញ្ចឹមក្តាម។

ជាទូទៅភាគច្រើន នៃការប្រើឧបករណ៍នេសាទ និងអ្នកទាំងនោះ បានរាយការណ៍ថា ការចូលរួមជាមួយវារីវប្បកម្មគឺមានទូក ៤៨ភាគរយ ព្រោះវាមានសារៈសំខាន់ សម្រាប់ការចិញ្ចឹមនិងការប្រមូលផលនៃប្រភេទសត្វក្នុងទឹក ការដឹកជញ្ជូនតាមផ្លូវទឹកដើម្បីស្តុកទុកទៅកាន់ទីផ្សារ ដូចជា ការដាក់ម៉ាស៊ីនបញ្ចូលខ្យល់ មុងការពារនិងការកែច្នៃម្ហូបអាហារ។ មាន១៧ភាគរយគ្រួសារបានចូលរួមនៅក្នុងវារីវប្បកម្ម បានរាយការណ៍ថាការប្រើប្រាស់អគារនិងសំណង់ពិសេសសម្រាប់សកម្មភាពវារីវប្បកម្ម។

សមាជិកគ្រួសារចំនួន ៨៦.000នាក់ មួយចំនួនដែលបានរាយការណ៍ថា បានកំពុងចូលរួមនៅក្នុងសកម្មភាពគ្រួសារវារីវប្បកម្មនៅក្នុងគ្រួសារកាន់កាប់កសិកម្មមានចំនួន ៣១ភាគរយ ដែលធ្វើការពេញម៉ោងជាមួយនឹងវារីវប្បកម្មនិង៨០ភាគរយ នៃចំនួនអ្នកមានអាយុ១៨ឆ្នាំនិងមនុស្សចាស់។ ទោះជាយ៉ាងណា ១៩ភាគរយមានអាយុតិចជាង១៨ឆ្នាំរួមបញ្ចូលទាំង ៩ភាគរយ ដែលនៅក្រោមអាយុ ១៥ឆ្នាំ។ ស្ត្រីមានចំនួនច្រើនជាងបុរសបានបម្រើការងារនៅក្នុងសកម្មភាពវារីវប្បកម្មគ្រួសារមានបុរសចំនួន ៩៤នាក់ ស្ត្រីចំនួន១០០នាក់ ដែលបានចូលរួមនៅក្នុងការងារនេះ។ រៀងរាល់សមាជិកក្នុងគ្រួសារមាន ៤នាក់ ដែលកំពុងធ្វើការងារក្នុងវារីវប្បកម្មមាន១នាក់ជាកម្មករ និងចំនួនសរុបនៃកម្មករ ២១.៨៦១នាក់ដែលបានជួលតាមការរាយការណ៍ថា ៨៤ភាគរយ បានធ្វើការ ២១ម៉ោង ឬតិចជាងនេះក្នុងមួយសប្តាហ៍ និង ៦៤ភាគរយជាបុរស។

ប្រមាណ៣២ភាគរយនៃគ្រួសារកាន់កាប់កសិកម្ម បានរួមជាមួយដំណើរការក្នុងសកម្មភាពវារីវប្បកម្ម ហើយមួយចំនួនបានចូលរួមតាមទម្រង់នៃកម្មវិធីការពារពីសង្គម ទទួលបានការបណ្តុះបណ្តាលដោយឥតគិតថ្លៃមាន ៨១ភាគរយ

ផ្ដល់ប្រឹក្សាទាក់ទងនឹងវារីវប្បកម្មមាន៧៣ភាគរយ ផ្ដល់កូនត្រីពូជ និងប្រាក់កម្ចី១៨ភាគរយ ជាដើម។ ក្នុងរង្វង់៥ភាគរយនៃគ្រួសារបានចូលរួមនៅក្នុងវារីវប្បកម្មមានសមាជិកចូលរួមនៅក្នុងសហគមន៍នេសាទនិងអង្គការវារីវប្បកម្ម។

**តារាង ៦.៣ ចំនួនសមាជិកគ្រួសារនៅក្នុងគ្រួសារមានសកម្មភាពវារីវប្បកម្ម តាម ភេទ អាយុ និង ប្រភេទនៃការចូលរួមឆ្នាំ២០១៣**

| ប្រភេទនៃការចូលរួម | សមាជិកទាំងអស់ | | | |
|---|---|---|---|---|
| | សរុប | 5-14 ឆ្នាំ | 15-17 ឆ្នាំ | 18 ឆ្នាំឡើង |
| កម្ពុជា | | | | |
| សមាជិកគ្រួសារទាំងអស់ធ្វើការងារវារីវកម្មផ្ទាល់ខ្លួន | 86,410 | 7,571 | 8,443 | 70,396 |
| ពេញម៉ោង | 26,851 | 1,136 | 1,875 | 23,840 |
| ក្រៅម៉ោង | 30,685 | 3,258 | 2,890 | 24,537 |
| ម្ដងម្កាល | 28,875 | 3,177 | 3,678 | 22,019 |
| បុរសជាសមាជិកគ្រួសារធ្វើការងារវារីវកម្មផ្ទាល់ខ្លួន | 41,973 | 3,048 | 3,957 | 34,968 |
| ពេញម៉ោង | 16,664 | 855 | 1,122 | 14,687 |
| ក្រៅម៉ោង | 8,745 | 501 | 693 | 7,551 |
| ម្ដងម្កាល | 16,564 | 1,692 | 2,142 | 12,730 |
| ស្ត្រីជាសមាជិកគ្រួសារធ្វើការងារវារីវកម្មផ្ទាល់ខ្លួន | 44,438 | 4,523 | 4,487 | 35,428 |
| ពេញម៉ោង | 10,187 | 281 | 754 | 9,153 |
| ក្រៅម៉ោង | 21,940 | 2,757 | 2,197 | 16,986 |
| ម្ដងម្កាល | 12,311 | 1,485 | 1,536 | 9,289 |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

**តារាង៦.៤ ចំនួនកម្មករឈ្នួល ក្នុងសកម្មភាពគ្រួសារវារីវប្បកម្មនៅកម្ពុជាតាមម៉ោងធ្វើការនិងប្រភេទនៃការចូលរួមឆ្នាំ ២០១៣**

| ប្រភេទការចូលរួម | ឈ្នួលកម្មករទាំងអស់ | | | |
|---|---|---|---|---|
| | សរុប | 21 ម៉ោងឬតិចជាង | 22-49 ម៉ោង | 50 ម៉ោង និងច្រើនជាង |
| កម្មករទាំងអស់ | 21,861 | 18,314 | 2,834 | 713 |
| ពេញម៉ោង | 11,668 | 9,588 | 1,695 | 385 |
| ក្រៅម៉ោង | 6,247 | 5,323 | 619 | 305 |
| ម្ដងម្កាល | 3,946 | 3,403 | 520 | 23 |
| កម្មករបុរស | 13,860 | 12,109 | 1,492 | 259 |
| ពេញម៉ោង | 7,485 | 6,347 | 962 | 176 |
| ក្រៅម៉ោង | 3,630 | 3,339 | 231 | 60 |
| ម្ដងម្កាល | 2,745 | 2,424 | 299 | 22 |
| កម្មករស្ត្រី | 8,001 | 6,205 | 1,342 | 454 |
| ពេញម៉ោង | 4,183 | 3,242 | 733 | 209 |
| ក្រៅម៉ោង | 2,617 | 1,984 | 388 | 245 |
| ម្ដងម្កាល | 1,201 | 979 | 221 | 1 |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣

# ជំពូកទី ៧
# សកម្មភាពសេដ្ឋកិច្ចបន្ថែមនៅក្នុងការកាន់កាប់គ្រួសារកសិកម្ម

គ្រួសារកសិកម្មក្នុងប្រទេសកម្ពុជា តែងមានសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនបន្ថែម នៅក្នុងការកាន់កាប់របស់ពួកគេមានដូចជា សកម្មភាពនានាដែលទាក់ទងនឹងព្រៃឈើ សិប្បកម្ម ជំនួញខ្នាតតូច និងធ្វើការនៅក្នុងវិស័យកសិកម្ម នៅខាងក្រៅនៃការកាន់កាប់របស់ពួកគេ និងការងារនៅក្នុង ញវិស័យសេវាកម្ម។

*ក្រាហ្វិក ៧.១ ភាគរយនៃការកាន់កាប់កសិកម្មចូលរួមក្នុងសកម្មភាពនានាដែលទាក់ទងនឹងព្រៃឈើ តាមតំបន់*




*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣*

ក្នុងចំណោមសរុប ២,១លាននៃការកាន់កាប់គ្រួសារកសិកម្មនៅក្នុងប្រទេសកម្ពុជា មាន៣៨ភាគរយ បានចូលរួមធ្វើសកម្មភាពទាក់ទងនឹងព្រៃឈើ មានដូចជា ការរកអុស រកឫស្សី ធ្វើធ្យូង និងកាប់ឈើក្នុងព្រៃ (ឈើក្រអូបនិង ផ្សេងទៀត)។ សមាមាត្រនៃគ្រួសារមានសកម្មភាពទាក់ទងនឹងព្រៃឈើនេះគឺ ច្រើនជាងគេនៅក្នុង តំបន់បឹងទន្លេសាប (៤៥ភាគរយ) បន្ទាប់មកនៅតំបន់ឆ្នេរ (៤៣ភាគរយ) និងតំបន់ខ្ពង់រាបនិងជួរភ្នំ (៤២ភាគរយ) មានន័យថាជិតពាក់កណ្តាលនៃគ្រួសារកសិកម្មនៅក្នុងតំបន់ទាំងនេះ បានពឹងផ្អែកលើព្រៃឈើដែលស្ថិតនៅក្បែរៗនោះ ដើម្បីជាសកម្មភាពសេដ្ឋកិច្ចបន្ថែម។

ចំនួនគ្រួសារកសិកម្មសរុបដែលបានចូលរួមក្នុងសកម្មភាព ដែលទាក់ទងនឹងព្រៃឈើមាន ៩៧ភាគរយ គឺរកអុស និង/ឬរកឫស្សី និងប្រហែលជា ៣០ភាគរយ បានរកបេះជាផ្លែឈើព្រៃ និងអ្វីដែលអាចហូបបានផ្សេងទៀត ដើម្បីបំពេញបន្ថែមអាហាររបស់ពួកគាត់ ។

ខេត្តព្រៃវែងបាននាំមុខគេ ក្នុងបណ្តាខេត្តផ្សេងទៀតដែលបានរាយការណ៍ថា ចំនួនគ្រួសារដែលបានរកអុសដុត និងការប្រមូលផលឫស្សី (១០៦.០០០ ) ព្រមទាំងរកបេះជាផ្លែឈើព្រៃ និងអ្វីដែលអាចហូបបានផ្សេងទៀត (៤៧.០០០) ផងដែរ។ សកម្មភាពដែលទាក់ទងនឹងការរកអុស និងការប្រមូលផលឫស្សី ក៏បានរាយការណ៍ផងដែរគឺច្រើនជាង ៥០.០០០ គ្រួសារនៅក្នុងបណ្តារខេត្តដូចខាងក្រោម ÷ កំពង់ចាម កំពង់ធំ សៀមរាប កំពង់ស្ពឺ ត្បូងឃ្មុំ កំពត និងតាកែវ។ ខេត្តតាកែវក៏បានរាយការថាមានគ្រួសារចំនួន ៣២.០០០ បានរកបេះជាផ្លែឈើ ព្រៃ និងអ្វីដែលអាចហូបបានផ្សេងទៀត នៅក្នុងព្រៃផងដែរ។

### ក្រាហ្វិក ៧.២ ភាគរយនៃគ្រួសារចូលរួមក្នុងសកម្មភាពនានាដែលទាក់ទងនឹងព្រៃឈើ តាមប្រភេទនៃសកម្មភាព ចែកតាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣*

### ក្រាហ្វិក ៧.៣ ចំនួននៃគ្រួសារកសិកមកម្មចូលរួមក្នុងសកម្មភាពសិប្បកម្ម ចែកតាមតំបន់




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣*

មានប្រហែល ៤ភាគរយនៃគ្រួសារកសិកម្មទាំងអស់ដែលបានចូលរួមនៅក្នុងវិស័យសិប្បកម្ម ដូចជា ត្បាញកន្ត្រក និង កន្ទេល ល្អី (៦០ភាគរយ) និងការផលិតអំបោះ និងរបស់របរសម្លៀកបំពាក់ (៤០ភាគរយ)។ មានចំនួនច្រើនបំផុតនៃគ្រួសារដែលចូលរួមនៅក្នុង ការត្បាញ កន្ត្រក និងកន្ទេល ត្រូវបានគេរាយការណ៍ នៅក្នុងខេត្តតាកែវ កំពង់ចាមនិងខេត្តសៀមរាប។

## អាជីវកម្មខ្នាតតូច

គ្រួសារកសិកម្មក៏ចូលរួមផងដែរនៅក្នុងអាជីវកម្ម ខ្នាតតូច ដើម្បីបង្កើតប្រាក់ចំណូលបន្ថែមទៀត រួមបញ្ចូលទាំងការផលិតឥដ្ឋ និងក្បឿង កាត់ដេរ ការធ្វើពាណិជ្ជកម្មខ្នាតតូច និងការលក់ (កាត ទូរស័ព្ទ ឧបករណ៍ប្រើប្រាស់ក្នុងគ្រួសារ អាហារជាដើម) និងមីក្រូហិរញ្ញវត្ថុក្នុងស្រុកខ្នាតតូចផ្តល់ប្រាក់កម្ចី។ អាជីវកម្មដែលពេញនិយមបំផុតនោះគឺ ពាណិជ្ជកម្មខ្នាតតូចមាន (ប្រមាណជិត ៥០ភាគរយនៃគ្រួសារ) បន្ទាប់មកអាជីវកម្មម្ហូបអាហារ (ការចម្អិនអាហារ ការលក់អាហារទុកបានយូ) ដោយមានប្រមាណជាង ៣០ភាគរយនៃគ្រួសារ។

*ក្រាហ្វិក ៧.៤ ខេត្តចំនួនបួនដែលនាំមុខគេនៃចំនួននៃគ្រួសារកសិកមកម្មចូលរួមក្នុងសកម្មភាពអាជីវកម្ម*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០១៣*

## សកម្មភាពសេដ្ឋកិច្ចផ្សេងទៀត នៃសមាជិកគ្រួសារកសិកម្ម

ប្រមាណ ៧០ភាគរយនៃសមាជិកគ្រួសារកសិកម្មទាំងអស់ ដែលមានអាយុចាប់ពី ៥ឆ្នាំឡើងទៅ បានចូលរួមក្នុងសកម្មភាពនៅក្នុងការកាន់កាប់របស់ពួកគេ ដែលជាសកម្មភាពសេដ្ឋកិច្ចចម្បងរបស់ពួកគេ ដោយមានបុរសលើសពីស្ត្រីនៅចំនួន ៣ភាគរយ។ ជាសមាជិកមួយបន្ថែមទៀត ១,២លាននាក់ក្នុងសមាជិកគ្រួសារ មានអាយុ ៥ឆ្នាំនិងច្រើនជាង ត្រូវបានចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចចម្បង នៅខាងក្រៅការកាន់កាប់របស់ពួកគេមាន ១០ភាគរយ នៅក្នុងវិស័យសេវាកម្ម ដូចជា កម្មករក្នុងស្រុកបម្រើឱ្យគ្រួសារផ្សេងទៀត អ្នករត់គុ បុគ្គលិកបម្រើតាមសណ្ឋាគារ និងភោជនីយដ្ឋាន ៧ភាគរយ ធ្វើការនៅក្នុង ឧស្សាហកម្មផ្សេងទៀតដូចជា ការផលិត ការធ្វើពាណិជ្ជកម្ម ជាដើម និង ៥ភាគរយចូលរួមក្នុងសកម្មភាពកសិកម្ម (នេសាទត្រី ព្រៃឈើសិប្បកម្ម) នៅក្នុងគ្រួសារផ្សេងទៀត។ នៅរាជធានីភ្នំពេញបានរាយការណ៍ថា មានចំនួនច្រើនជាងគេបំផុត (២៤ភាគរយ) នៃសមាជិកគ្រួសារកសិកម្មបានកំពុងធ្វើការនៅក្នុងវិស័យសេវាកម្ម។

បុរសច្រើន (០,៤ភាគរយ) ជាងស្ត្រី ដែលបានធ្វើការងារនៅក្នុងមុខតំណែងវិស័យសេវាកម្មឧស្សាហកម្ម។ ម្យ៉ាងវិញទៀត ស្ត្រីមានចំនួនច្រើន (៦ភាគរយ) ជាងបុរស ដែលត្រូវបានចូលរួមនៅក្នុងផលិតរបស់របរប្រើប្រាស់ និងពាណិជ្ជកម្មឧស្សាហកម្ម។

# ជំពូកទី ៨
# គ្រួសារកសិកម្ម និងប្រជាជន

## គ្រួសារ

តាមការប៉ាន់ស្មានគ្រួសារនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០១៣ គឺមានចំនួនសរុបប្រមាណ ៣,៣ លានគ្រួសារ ដោយយោងទៅលើការធ្វើអង្កេតចន្លោះជំរឿនប្រជាជនរបស់វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៣។ ជំរឿនកសិកម្មបានចាប់ផ្តើមដំណើរការជាក់ស្តែងទៅលើចំនួនគ្រួសារតិចជាង គឺមានចំនួនតែ ២,៦ លានគ្រួសារប៉ុណ្ណោះ ដោយត្រូវបានដកចេញខណ្ឌមួយចំនួនដែលជាទីប្រជុំជននៅរាជធានីភ្នំពេញ និងទាំងតំបន់ដាច់ស្រយាលមួយចំនួនទៀតដែលមន្ត្រីសម្ភាសន៍មិនអាចចូលដល់។ គ្រួសារដែលបានរាយការណ៍ គឺមានចំនួនប្រជាជន ៨,៥លាននាក់ (ប្រមាណ ៦៣ភាគរយ) នៃចំនួនប្រជាជនសរុបក្នុងប្រទេសនៅឆ្នាំ២០១៣ ។

ប្រមាណ៧៧ភាគរយនៃគ្រួសារសរុប ត្រូវបានរាប់បញ្ចូលក្នុងការធ្វើជំរឿនកសិកម្ម បានរាយការណ៍ថា ការចូលរួមក្នុងការដំណាំ ឬការចិញ្ចឹមបសុសត្វនិងបសុបក្សី នៅក្នុងការកាន់កាប់កសិកម្មរបស់ពួកគេ។ យោងតាមការធ្វើជំរឿនកសិកម្មនេះ តំបន់វាលទំនាបមានចំនួន ៤៥ភាគរយនៃចំនួនប្រជាជន ដែលរស់នៅរួមជាមួយនឹងការកាន់កាប់កសិកម្មនៅតំបន់បឹងទន្លេសាបមានចំនួន ៣៣ ភាគរយ នៅតំបន់ឆ្នេរសមុទ្រមាន ៨ភាគរយ និងតំបន់ខ្ពង់រាបនិងជួរភ្នំ មានចំនួន ១៤ភាគរយ។

ក្រាហ្វិក ៨.១ ចំនួននិងភាគរយនៃគ្រួសារដែលកាន់កាប់កសិកម្មចែកតាមតំបន់




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (តំណាក់កាលបំពេញបន្ថែម)ឆ្នាំ ២០១៤

ខេត្តព្រៃវែងជាខេត្តមួយដែលបានរាយការណ៍ថា មានចំនួនការកាន់កាប់កសិកម្មច្រើនជាងគេ ដោយឡែកខេត្តកែបមានចំនួនការកាន់កាប់កសិកម្មតិចជាងគេ។ ជាមួយនោះខេត្ត ព្រៃវែង តាកែវ កណ្តាល កំពង់ស្ពឺ សៀមរាប បាត់ដំបង កំពង់ចាម និងកំពង់ធំ ជាខេត្តនាំមុខគេទាំងប្រាំបីនេះ ដែលមានប្រជាជនច្រើន ស្មើនឹង ៥០០.០០០នាក់ ឬច្រើនជាងជាគ្រួសារកសិកម្ម។ ចំនួនប្រហាក់ប្រហែលគ្នានៃចំនួនបុរសមាន (៥០,១ភាគរយ) និងស្ត្រី (៤៩,៩ភាគរយ) ដែលជាចំនួនមនុស្សនៅក្នុងគ្រួសារកសិកម្ម សូម្បីតែមេគ្រួសារជាបុរស (ចំនួន៥២ភាគរយ) ច្រើនជាងមេគ្រួសារជាស្ត្រី (៤៨ភាគរយ)។ គ្រួសារដែលស្ត្រីជាមេគ្រួសារមានសមាជិកជាស្ត្រីច្រើនជាង (៥៩ភាគរយ ) សមាជិកបុរស (៤១ភាគរយ) ។

### ក្រាហ្វិក ៨.២ ខេត្តនាំមុខគេដែលមានចំនួនប្រជាជនច្រើនក្នុងគ្រួសារកាន់កាប់កសិកម្ម




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (តំណាក់កាលបំពេញបន្ថែម) ឆ្នាំ២០១៤

## ប្រជាជនតាមក្រុមអាយុ

បុរស និងស្ត្រីដែលមានអាយុនៅចន្លោះពី ១០ឆ្នាំ ទៅ ១៩ឆ្នាំ គឺជាក្រុមអាយុដែលមានចំនួនច្រើនជាងបំផុត (ប្រមាណ ២៣ភាគរយ ) នៃចំនួនប្រជាជនទាំងអស់ដែលរស់នៅដោយការកាន់កាប់កសិកម្ម បន្ទាប់មកទៀតក្រុមអាយុពី ២០ ឆ្នាំ ទៅ ២៩ ឆ្នាំ (ប្រមាណ ២០ភាគរយ )។ ចំនួនបុរសច្រើនជាងស្ត្រី ២ភាគរយ នៅចន្លោះអាយុពី ១០ ទៅ ១៩ ឆ្នាំ ប៉ុន្តែមានចំនួនប្រហាក់ប្រហែលគ្នានៅក្រុមអាយុពី ២០ ទៅ ២៩ឆ្នាំ។ ចំនួនសមាជិកនៃគ្រួសារកសិកម្ម ដែលមានអាយុតិចជាង ១០ឆ្នាំ មានប្រហែល ១៥ភាគរយ នៃចំនួនប្រជាជនសរុបក្នុងការកាន់កាប់កសិកម្ម។ ចំនួនភាគរយ នៃបុរស និងស្ត្រីក្នុងគ្រួសារកាន់កាប់សកិកម្ម បានថយចុះក្នុងក្រុមអាយុពី ចន្លោះ ៣០ ទៅ ៣៩ឆ្នាំ ហើយចំនួនបុរស ទៅនឹងស្ត្រី ក៏ថយចុះផងដែរក្នុងក្រុមអាយុនេះ និងបន្តថយចុះជាបន្តបន្ទាប់ក្នុងក្រុមអាយុចាស់ជាង។

### ក្រាហ្វិក ៨.៣ ចំនួនប្រជាជនតាមភេទ និងអាយុក្នុងគ្រួសារកសិកម្ម




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (តំណាក់កាលបំពេញបន្ថែម) ឆ្នាំ២០១៤

សមាជិកគ្រួសារកាន់កាប់កសិកម្មមានអាយុជាមធ្យម ២៨,៨ឆ្នាំ ការកំណត់ត្រាសមាជិកគ្រួសារកាន់កាប់កសិកម្មមានអាយុមធ្យមខ្ពស់ជាងគេ គឺក្នុងខេត្តកំពង់ចាម ៣១,៦ឆ្នាំ ហើយអាយុជាមធ្យមដែលទាបជាងគេបំផុត ២២,៩ឆ្នាំ នៅក្នុងខេត្តមណ្ឌលគិរី។

## អត្រាអ្នកដែលនៅក្នុងបន្ទុកគ្រួសារ

ចំនួន ៧០ភាគរយនៃសមាជិកគ្រួសារកសិកម្មទាំងមេគ្រួសារបុរស ទាំងមេគ្រួសារជាស្ត្រី បានចូលរួមធ្វើការងារក្នុងសកម្មភាពសេដ្ឋកិច្ច។ ភាគរយនៃអ្នកដែលនៅក្នុងបន្ទុកគ្រួសារកសិកម្មគឺមានអាយុតិចជាង ១៥ឆ្នាំ និងអ្នកដែលមានអាយុ ៦៥ឆ្នាំឡើងទៅ ត្រូវបានគណនាស្មើនឹង ១៩ភាគរយ មានន័យថាអត្រាអ្នករស់នៅក្នុងបន្ទុកគ្រួសារទាំងអស់គឺ ០,៣ និងដែលមានចំនួនសមាជិកក្នុងគ្រួសារកសិកម្ម ដែលបានធ្វើសកម្មភាពសេដ្ឋកិច្ច មានច្រើនជាង៤ដងនៃអ្នកដែលរស់នៅក្នុងបន្ទុករបស់គ្រួសារ។

**តារាង ៨.១ អត្រាអ្នកដែលនៅក្នុងបន្ទុកគ្រួសារកាន់កាប់កសិកម្មតាមតំបន់ឆ្នាំ២០១៣**

| ចំនួនក្រុម អាយុ/ តំបន់ | សរុបចំនួនគ្រួសារ | | |
|---|---|---|---|
| | ចំនួន | អត្រាពឹងផ្អែកលើមេគ្រួសា | អាត្រាមនុស្សចាស់នៅក្នុងបន្ទុក ** |
| កម្ពុជា | 8,563,207 | 0.48 | 0.11 |
| តំបន់វាលទំនាប | 3,876,473 | 0.45 | 0.12 |
| តំបន់បឹងទន្លេសាប | 2,842,351 | 0.49 | 0.10 |
| តំបន់ឆ្នេរ | 638,304 | 0.49 | 0.11 |
| តំបន់ខ្ពង់រាប និងភ្នំ | 1,206,079 | 0.54 | 0.09 |

*អាត្រាអ្នកនៅក្នុងបន្ទុកគឺជា អាត្រានៃចំនួនមនុស្ស ដែលមានអាយុតិចជាង ១៥ឆ្នាំ និងអាយុច្រើនជាង ៥៩ឆ្នាំ ធៀបទៅនឹងចំនួនមនុស្សអាយុពី១៥ ទៅ ៥៩ឆ្នាំ។

**អាត្រាមនុស្សចាស់នៅក្នុងបន្ទុកគឺជា អាត្រានៃចំនួនមនុស្ស ដែលមានអាយុច្រើនជាង ៥៩ឆ្នាំ ធៀបទៅនឹងចំនួនមនុស្សអាយុពី១៥ ទៅ ៥៩ឆ្នាំ។

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (តំណាក់កាលបំពេញបន្ថែម)ឆ្នាំ២០១៤

## ទំនាក់ទំនងជាមួយនឹងមេគ្រួសារ

មានត្រឹមតែ៤ភាគរយប៉ុណ្ណោះនៃចំនួនបុរសសរុប ដែលបានរាយការណ៍ថា ជាប្រពន្ធជាមេគ្រួសារ បើប្រៀបធៀបទៅនឹងចំនួន ៣៥ភាគរយ នៃចំនួនប្រជាជនជាស្ត្រី បានរាយការណ៍ថា ប្តីជាមេគ្រួសារនៃការកាន់កាប់កសិកម្ម។

## ការអប់រំ

មានត្រឹមតែ ៩,៤ ភាគរយនៃប្រជាជនសរុបដែលមានអាយុ ៥ឆ្នាំឡើងទៅក្នុងគ្រួសារកសិកម្ម ដែលបានសិក្សាចប់ត្រឹមថ្នាក់ទី ៥ និងមានតែ ៤ភាគរយប៉ុណ្ណោះ ដែលបានរាយការណ៍ថាបានបញ្ចប់សិក្សាត្រឹមថ្នាក់ទី ១២ (រាប់បញ្ចូលទាំងអ្នកមិនបានទទួលវិញ្ញាបនប័ត្រមធ្យមសិក្សាទុតិយភូមិកម្រិតខ្ពស់)។ ចំនួនត្រឹមតែ ០,៦ភាគរយប៉ុណ្ណោះ ដែលបានរាយការណ៍ថា បានទទួលវិញ្ញាបនប័ត្រមធ្យមសិក្សាទុតិយភូមិកម្រិតទាប ហើយ ១.១ភាគរយ បានរាយការណ៍ថា បានទទួលវិញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិកម្រិតខ្ពស់។

ស្រដៀងគ្នានេះដែរ ចំនួនតួលេខដែលបានរាយការណ៍ថា ទទួលបានការអប់រំទទួលត្រឹមកម្រិតបរិញ្ញាបត្រ។ ចំនួន ១០ភាគរយនៃបុរសអាយុ៥ឆ្នាំឡើងទៅ ក្នុងគ្រួសារកសិកម្មបានរាយការណ៍ថា បានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៧ ដូចគ្នានេះដែរ ១០ភាគរយនៃស្ត្រីមានចំនួនដូចគ្នានេះដែរ បានបញ្ចប់ការសិក្សាត្រឹមតែថ្នាក់ទី ២ប៉ុណ្ណោះ។

ជាទូទៅសមាជិកមួយចំនួនតូចនៃគ្រួសារកសិកម្ម ដែលបានបញ្ចប់ការអប់រំខ្ពស់ និងការចូលរួមជាស្ត្រីមានចំនួនតិចជាងបុរស។ ឧទាហរណ៍ ៣ភាគរយនៃស្ត្រីបានបញ្ចាប់នៅកម្រឹតសិក្សាថ្នាក់ទី១២ ប្រៀបធៀបទៅនឹងបុរសមាន ៥ភាគរយ និង ០,៦ ភាគរយនៃស្ត្រីបានសិក្សាដល់ថ្នាក់មហាវិទ្យាល័យ ឬសកលវិទ្យាល័យ បើធៀបទៅនឹងបុរសមាន ០,៩ ភាគរយ ហើយនឹង ០,៤ ភាគរយនៃស្ត្រីបានសិក្សាត្រឹមបឋមភូមិ បើធៀបទៅនឹងបុរស ០,៨ភាគរយ។

## ស្ថានភាពគ្រួសារ

ចំនួន ៥២ភាគរយនៃសមាជិកគ្រួសារកាន់កាប់កសិកម្ម ដែលបានរៀបការ ៦ភាគរយ ជាស្ត្រីមេម៉ាយ ២ភាគរយ បានលែងលះ ឬរស់នៅផ្សេងគ្នា និង ៤០ភាគរយ រស់នៅដោយមិនបានរៀបការ និងមិនបានរស់នៅជាមួយគ្នា។

មេគ្រួសារជាស្ត្រីជាច្រើនទៀតដែលរស់នៅដោយមិនបានរៀបការ ឬរស់នៅជាមួយដៃគូរមានចំនួន ៤២ភាគរយ ប្រៀបធៀបទៅនឹង មេគ្រួសារដែលមិនបានរៀបការ ឬមិនបានរស់នៅជាមួយដៃគូរមាន ៣៩ភាគរយ។ មេគ្រួសារជាស្ត្រីជាច្រើនបានលែងលះ (១៧ភាគរយ ប្រៀបធៀបទៅនឹងបុរសជាមេគ្រួសារមាន ៣ភាគរយ) និងមានស្ត្រីជាមេគ្រួសារជាច្រើនទៀតត្រូវបានលែងលះ ឬបែកបាក់គ្នា ( ៣ភាគរយប្រៀបធៀបទៅនឹងបុរសជាមេគ្រួសារមាន ២ភាគរយ)។

# ជំពូកទី ៩
# សន្តិសុខស្បៀងនៃគ្រួសារកសិកម្ម

ប្រមាណជិត ២លានគ្រួសារ ស្មើនឹង ៩៣ភាគរយ នៃចំនួនគ្រួសារសរុបកាន់កាប់កសិកម្ម ដែលបានឆ្លើយសំណួរទាក់ទងទៅនឹងសន្តិសុខស្បៀងរបស់ពួកគេ។ អាហារចម្បងដែលគេបរិភោគប្រចាំថ្ងៃនោះគឺ÷ (ក) អង្ករនិងគ្រាប់ធញ្ញជាតិផ្សេងទៀត (ខ) បន្លែ (គ)សាច់ និងផលិតផលពីសាច់ (ឃ) ត្រី និងត្រីសមុទ្រផ្សេងទៀត (ង) ផ្លែឈើ (ច)ដំណាំយកមើម (ឆ) សណ្តែកនិងពពួកសណ្តែក ដែលអាចបរិភោគបាន (ជ) ដំណាំប្រភេទយកគ្រាប់។

ប្រមាណជាង ៩៦ ភាគរយនៃចំនួនគ្រួសារដែលបានបរិភោគអង្ករ (អាហារចម្បងរបស់ប្រទេសកម្ពុជា) ៧ ថ្ងៃក្នុងមួយសប្តាហ៍ បរិភោគបន្លែជាមធ្យម ៥ថ្ងៃក្នុងមួយសប្តាហ៍ បរិភោគសាច់ និងផលិតផលពីសាច់ជាមធ្យម ៤ថ្ងៃក្នុងមួយសប្តាហ៍។ មធ្យមនៃការបរិភោគត្រី និងអាហារសមុទ្រផ្សេងទៀត ក៏មាន៤ថ្ងៃដែរក្នុងមួយសប្តាហ៍ គឺស្មើនឹង ៨៤ ភាគរយនៃគ្រួសារកសិកម្មដែលបានឆ្លើយតប។ គ្រួសារកសិកម្មប្រមាណជិត ៧០ភាគរយបានបរិភោគផ្លែឈើ២ថ្ងៃក្នុងមួយសប្តាហ៍ ហើយគ្រួសារដែលបានបរិភោគ ២ដងដែរក្នុងមួយសប្តាហ៍ ដែលជាប្រភេទដំណាំយកមើម ៣៤ភាគរយនៃគ្រួសារ បានបរិភោគសណ្តែក និងពពួកសណ្តែកផ្សេងទៀត និង ១៨ភាគរយបានបរិភោគដំណាំប្រភេទយកគ្រាប់។

យោងលើទស្សនៈវិស័យគ្រួសារកសិកម្ម ចំនួនថ្ងៃជាមធ្យមដែលបានបរិភោគនូវប្រភេទអាហារនីមួយៗ យោងលើភាគរយជាក់ស្តែងនៃគ្រួសារកសិកម្មទាំងអស់ជាតួលេខមធ្យមនៃចំនួនដែលបានបរិភោគអាហារនីមួយៗ។ ហេតុដូចនេះ ចំនួនគ្រួសារកសិកម្មទាំងអស់ដែលបានបរិភោគអង្ករ និងគ្រាប់ធញ្ញជាតិជាមធ្យមមាន ៦,៩ថ្ងៃក្នុងមួយសប្តាហ៍ បរិភោគបន្លែ ៤,៨ដងក្នុងមួយសប្តាហ៍ បរិភោគត្រី ៣,៥ក្នុងមួយសប្តាហ៍ បរិភោគសាច់និងផលិតផលពីសាច់សត្វ ៣,៧ ថ្ងៃក្នុងមួយសប្តាហ៍ ផ្លែឈើ ១,៧ថ្ងៃក្នុងមួយសប្តាហ៍ ដំណាំជាមើម ១ថ្ងៃក្នុងមួយសប្តាហ៍ សណ្តែកនិងពពួកសណ្តែកផ្សេងទៀតដែលបានបរិភោគតែ ០,៧ ថ្ងៃ ដំណាំយកគ្រាប់ដែលបានបរិភោគ ០,៤ ថ្ងៃក្នុងមួយសប្តាហ៍ក្នុងអំឡុងពេលធ្វើអង្កេត។

ក្រាហ្វិក៩.១ ចំនួនថ្ងៃជាមធ្យមក្នុង ១សប្តាហ៍តាមប្រភេទនៃអាហារនីមួយៗ ដែលបានប្រើប្រាស់ជាមធ្យមសម្រាប់បរិភោគរបស់គ្រួសារកាន់កាប់កសិកម្ម




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា(តំណាក់កាលបំពេញបន្ថែម)ឆ្នាំ ២០១៤

**តារាង ៩.២ សមាមាត្រគ្រួសាររាយការណ៍ថាបានបរិភោគប្រភេទអាហារ នៃចំនួនថ្ងៃជាមធ្យម ក្នុងរយៈពេល៧ថ្ងៃកន្លងមកអំឡុងពេលធ្វើជំរឿន**

| ប្រភេទអាហារសំខាន់ៗ | ចំនួនភាគរយនៃគ្រួសារក្នុងប្រទេសកម្ពុជា | ចំនួនថ្ងៃជាមធ្យមដែលបានបរិភោគក្នុងរយៈពេល ៧ ថ្ងៃកន្លងមក | | | | |
|---|---|---|---|---|---|---|
| | | ប្រទេសកម្ពុជា | តំបន់វាលទំនាប | តំបន់បឹងទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ខ្ពង់រាបនិងជួរភ្នំ |
| អង្ករ និងគ្រាប់ធុញ្ញជាតិ | 99.9 | 7 | 7 | 7 | 7 | 7 |
| បន្លែ (ស្លឹក, ផ្លែ និងបន្លែផ្សេងៗទៀត) | 96.4 | 5 | 5 | 5 | 5 | 5 |
| ត្រី និងអាហារសមុទ្រ | 96.0 | 4 | 4 | 5 | 5 | 4 |
| សាច់ និងផលិតផលពីសាច់ (ស៊ុត ។ល។) | 83.7 | 4 | 4 | 4 | 4 | 3 |
| ផ្លែឈើ | 69.3 | 2 | 3 | 2 | 3 | 2 |
| ដំណាំជាមើម | 46.0 | 2 | 2 | 2 | 3 | 2 |
| សណ្តែក និងពពួកសណ្តែកផ្សេងទៀត | 34.3 | 2 | 2 | 2 | 3 | 2 |
| ដំណាំប្រភេទគ្រាប់ដែលអាចហូបបាន | 18.2 | 2 | 2 | 2 | 2 | 2 |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ នៃជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៣

ចំនួនគ្រួសារក្នុងតំបន់បឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រដែលបានបរិភោគត្រី និងអាហារសមុទ្រ ១ថ្ងៃបន្ថែមទៀត (៥ថ្ងៃក្នុងមួយសប្តាហ៍) ជាមធ្យមបើប្រៀបធៀបគ្រួសារក្នុងតំបន់ផ្សេង។ ចំនួនគ្រួសារក្នុងតំបន់ខ្ពង់រាបនិងជួរភ្នំដែលបានបរិភោគសាច់និងផលិតផលពី សាច់មានចំនួនតិចជាងចំនួនមធ្យម (៣ថ្ងៃក្នុងមួយសប្តាហ៍) បើប្រៀបធៀបទៅនឹងគ្រួសារក្នុងតំបន់ផ្សេង។ គ្រួសារក្នុងតំបន់ឆ្នេរសមុទ្របានបរិភោគផ្លែឈើបន្ថែមទៀតក្នុងមួយសប្តាហ៍ (៣ថ្ងៃ) បើប្រៀបធៀបនឹងគ្រួសារក្នុងតំបន់ផ្សេង។

ប្រភេទអាហារដែលបានបរិភោគក្នុងរយៈពេល ១២ខែក្នុងអំឡុងពេលសម្ភាសន៍ ដែលទទួលបានមកមានពីរប្រភេទគឺៈ (ក) ផលិតដោយខ្លួនឯង (ពីកសិកម្ម ការនេសាទ និងព្រៃឈើ ) ហើយនឹង (ខ) អាហារទិញពីផ្សារ ឬអាហារផ្សេងៗទៀត។

ក្រាហ្វិក៩.២ ចំនួនភាគរយនៃគ្រួសារដែលរាយកាយណ៍ពីការបរិភោគនូវប្រភេទអាហាសំខាន់ៗក្នុងរយៈពេល៧ថ្ងៃ តាមប្រភពនៃអាហារ




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា(តំណាក់កាលបំពេញបន្ថែម)ឆ្នាំ ២០១៤

គ្រួសារដែលបានបរិភោគប្រភេទអាហារទាំង ៨ប្រភេទរួមមាន ៨៣ភាគរយនៃគ្រួសារកសិកម្ម ដែលបានរាយកាណ៍ថា បានបរិភោគបាយនិងគ្រាប់ធញ្ញជាតិផ្សេងៗទៀត ពីការប្រមូលផល ក្នុងនោះមានរយៈពេល ៧ថ្ងៃក្នុងពេលធ្វើជំរឿន។ ១៦ភាគរយ បានរាយការណ៍ថា បានទិញអង្ករនិងគ្រាប់ធញ្ញជាតិពីផ្សារ និងពីអ្នកលក់។ ហេតុនេះហើយ ភាគច្រើននៃការបរិភោគគ្រប់គ្រាន់នៃគ្រួសារកសិកម្ម បានមកពីការទិញអង្ករនិងគ្រាប់ធញ្ញជាតិផ្សេងទៀត ហើយពួកគេក៏បានទិញនូវប្រភេទអាហារសំខាន់ៗ ដែលពួកគេមិនបានផលិត ឬមិនអាចផលិតទៅតាមបរិមាណដែលត្រូវការ។ ទាក់ទងនិងប្រភេទអាហារនៃគ្រួសារមួយចំនួនបានមកពីអំណោយ ពីកាខ្ចី ឬការដឹកជញ្ជូនជាមួយគ្រួសារផ្សេងទៀត ឬបានមកពីការឧបត្ថម្ភផ្សេងៗ។ គ្រួសារទាំងនោះ ក៏បានលក់ស្រូវអង្ករ និងគ្រាប់ធុញ្ញជាតិ ដើម្បីទិញអាហារមកធ្វើជាម្ហូបផ្សេងៗ ហើយក៏បានលក់ដូរដូចជាសំលៀកបំពាក់ និងទីជំរកផ្សេងទៀត។

ភាគរយចំនួនច្រើននៃគ្រួសារកសិកម្ម ដែលបានទិញសាច់និងផលិតផលពីសាច់ ក៏ដូចជាត្រី អាហារសមុទ្រនៅក្នុងផ្សារនិងកន្លែងលក់ផ្សេទៀត។ ប្រជាជនដែលរស់នៅក្នុងតំបន់បឹងទន្លេសាប នឹងតំបន់ឆ្នេរសមុទ្រមានឱកាសច្រើនក្នុងការបរិភោគស្បៀងអាហាររបស់ពួកគេដែលបានផលិត ដោយផ្ទាល់ដូចជា ត្រី និងអាហារសមុទ្រច្រើនជាងគ្រួសារក្នុងតំបន់ផ្សេងទៀត។

## សន្តិសុខស្បៀង

“សន្តិសុខស្បៀងជាតម្រូវការចំបាច់សម្រាប់ប្រជាជនទាំងអស់ ស្បៀងអាហារទាំងនោះបានមកពីធម្មជាតិ ហើយមួយចំនួនទៀតបានហូរចូលទៅក្នុងវិស័យសេដ្ឋកិច្ច ដើម្បីផ្គត់ផ្គង់នូវតម្រូវការស្បៀងអាហារឱ្យបានគ្រាប់គ្រាន់ និងសម្រាប់ទ្រទ្រង់សកម្មភាពប្រចាំថ្ងៃ និងចំពោះសុខភាពជីវិត”។ (និយមន័យនេះ ត្រូវបានដាក់បញ្ចូលនៅឆ្នាំ១៩៩៦ ដោយកិច្ចប្រជុំកំពូលរបស់អង្គការស្បៀងអាហារពិភពលោក)។

ប្រមាណ ១៦ភាគរយ ឬស្មើនឹង ៣៣១,០០០នៃគ្រួសារ ដែលបានរាយការណ៍ថា បានទទួលរងនូវការកង្វះខាតស្បៀងក្នុងអំឡុងរយៈពេល ១២ខែ នៅពេលធ្វើសម្ភាសន៍ជំរឿនបំពេញបន្ថែម។ ចំនួន ៨០នៃតួលេខក្នុងការកង្វះខាតស្បៀងរយៈពេល ១ ខែ ចំនួន ៣៨ភាគរយស្ថិតក្នុងអសន្តិសុខស្បៀងរយៈពេលពី ២ ទៅ ៣ ខែនិងចំនួន ២៤ភាគរយមានអសន្តិសុខស្បៀងរយៈពេលច្រើនជាង ៣ខែ។

ក្រាហ្វិក ៩.៣ ចំនួនភាគរយនៃគ្រួសារកសិកម្មដែលទទួលរងនូវការកង្វះស្បៀងសម្រាប់អំឡុងពេលនីមួយៗដែលបានរាយការណ៍




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា (តំណាក់កាលបំពេញបន្ថែម)ឆ្នាំ ២០១៤

គ្រួសារក្នុងតំបន់ឆ្នេរសមុទ្រ និងតំបន់ខ្ពង់រាបនិងជួរភ្នំ មានចំនួនតួលេខច្រើនពីការកង្វះខាតស្បៀងនៅរយៈពេល ២ ទៅ ៣ខែ។ គ្រួសារដែលខ្វះខាតស្បៀងរយៈពេលច្រើនជាង ៣ ខែនៅ តំបន់ខ្ពង់រាបនិងជួរភ្នំ ក៏មានតួលេខច្រើនដែរ (២៨ភាគរយនៃគ្រួសារទាំងអស់ដែលខ្វះខាតស្បៀង)។ ដោយយោងទៅតាមគ្រួសារក្នុងតំបន់វាលទំនាប (២៥ភាគរយនៃគ្រួសារដែលរងនូវការខ្វះខាតស្បៀង)។ ខេត្តរតនគិរី និងខេត្តកណ្តាលដែលមានតួលេខគ្រួសារច្រើនជាងគេបំផុត (ប្រមាណជាង ៤០ភាគរយ ) ដែលរងនូវការខ្វះខាតស្បៀងច្រើនជាងរយៈពេល ៣ខែ។

## ហេតុផលមួយចំនួននៃអសន្តិសុខស្បៀង

ចំនួន ៨០ភាគរយនៃគ្រួសារកសិកម្ម ដែលបានរងនូវកង្វះខាតស្បៀង បណ្តាលមកពីតម្លៃផលិតផលទាប ចំពោះការខ្វះខាតស្បៀងអាហាររបស់ពួកគេ។ ស្ទើរតែ ៣៩ភាគរយ បានបណ្តាលមកពីការបំផ្លិចបំផ្លាញនូវដំណាំរបស់ពួកដោយសារមានភ្លៀងធ្លាក់ខ្លាំង គ្រោះរាំងស្ងួត សត្វល្អិត និងបញ្ហាបម្រែបម្រួលអាកាសធាតុ ក្នុងអំឡុងរយៈពេល ១២ខែ នៅពេលធ្វើជំរឿន។ ប្រមាណ ២៣ភាគរយ បណ្តាលមកពីតម្លៃស្បៀងអាហារ មានតម្លៃថ្លៃខ្ពស់នៅលើទីផ្សារលក់ចេញ។ មូលហេតុផ្សេងទៀតពីការរងនូវកង្វះស្បៀងរួមបញ្ចូលទាំងជំងឺ ការតម្លើងថ្លៃដោយអ្នកលក់ នៃការកាន់កាប់កសិកម្ម បណ្តាលឱ្យផលិតផលមានកំណត់ ហើយភាពបាត់បង់ការងារក៏បណ្តាលឱ្យថវិកាមានកំណត់ក្នុងការទិញស្បៀងអាហារ។

ក្រាហ្វិក ៩.៥ ចំនួនភាគរយនៃគ្រួសារដែលរាយការណ៍ពីកង្វះខាតស្បៀងអាហារក្នុងអំឡុងពេលធ្វើជំរឿន




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ ជំរឿនកសិកម្មនៅកម្ពុជា(តំណាក់កាលបំពេញបន្ថែម)ឆ្នាំ ២០១៤

គ្រួសារកសិកម្មដែលបានរាយការណ៍នូវកង្វះខាតស្បៀងមានចំនួន ៨៩ ភាគរយ ( ២៩៥,០០០ ) របៀបដោះស្រាយនូវបញ្ហាទាំនេះដោយរួមបញ្ចូលបញ្ហាដំបូង (រាយការណ៍ចំនួន ៥០ បានប្រើប្រាស់កំលាំងពលកម្ម ដើម្បីប្រមូលផលនៅពេលក្រោយ។ បញ្ហាទី ២ គឺ បញ្ជូនសមាជិកគ្រួសារទៅស្វែងរកការងារ ឬការកាន់កាប់កសិកម្មដែលជាប្រភពនៃចំណូលខាងក្រៅ ។ ការលក់ដូរ ឬការមិនមែនជាម្ហូបអាហារ ចិញ្ចឹមសត្វ និងបសុបក្សី សិប្បកម្ម ជាដើម គឺជាមធ្យោបាយមួយទៀត ដែលបានឆ្លើយតបទៅគ្រួសារកសិកម្មកង្វះស្បៀង។ សម្រាប់គ្រួសារក្រីក្រដែលគ្មានមធ្យោបាយបែបនេះជំនួយដោយតំរូវការត្រូវបានស្វែងរកពីសាច់ញាតិរស់នៅក្នុងមូលដ្ឋាន ឬដែលរស់នៅបរទេស និងការទទួលយកជំនួយពីគ្រឹះស្ថានផ្សេងទៀតប្រសិនបើមាន។